# ឯកសារបណ្តុះបណ្តាល

# ការគ្រប់គ្រងគ្រោះទឹកជំនន់តាមសហគមន៍

# សំរាប់  គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ



រៀបចំនៅក្រោមផ្នែកទី៤  នៃកម្មវិធីគ្រប់គ្រង  និងកាត់បន្ថយគ្រោះទឹកជំនន់របស់គណៈកម្មការទន្លេមេគង្គ

គាំទ្រទុនពី  នាយកដ្ឋានជំនួយមនុស្សធម៌គណៈកម្មការអឺរ៉ុប (ECHO)

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ............................................................ ១

**ផ្នែកទី១: យន្តការស្ថាប័ន និង រចនាសម្ពន្ធ័គ្រប់គ្រង របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

ក. សមាសភាព ............................................................ ៤

ខ. បេសកកម្ម ............................................................ ៥

គ. មុខងារ និង ភារកិច្ច ............................................................ ៥

ឃ. អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ............................................................ ៥

ង. រចនាសម្ពន្ធ័ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ............................................................ ៧

**យន្តការស្ថាប័ន និង រចនាសម្ពន្ធ័គ្រប់គ្រង របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង (PCDM)** ............ ៨

ក. សមាសភាព ............................................................ ៨

ខ. តួនាទី និង ការទទួលខុសត្រូវ ............................................................ ៨

គ. លេខាធិការដ្ឋាន អចិន្ត្រៃយ៍ ............................................................ ៩

ឃ. តួនាទី និង ភារកិច្ចរបស់លេខាអចិន្ត្រៃយ៍ មានដូចតទៅ : ............................................................ ៩

ង. ក្រុមប្រតិបត្តិការ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ............................................................ ៩

ច. រចនាសម្ព័ន្ធ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (ខេត្តកណ្តាល) ............................................................ ១០

**យន្តការស្ថាប័ន និង រចនាសម្ពន្ធ័គ្រប់គ្រង របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ (DCDM)** ...... ១១

ក. សមាសភាព ............................................................ ១១

ខ. តួនាទី និងការទទួលខុសត្រូវ ............................................................ ១១

គ. លេខាធិការដ្ឋាន អចិន្ត្រៃយ៍ ............................................................ ១២

ឃ. តួនាទី និង ភារកិច្ចរបស់លេខាអចិន្ត្រៃយ៍ មានដូចតទៅ : ............................................................ ១២

ង. ក្រុមប្រតិបត្តិការ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ ............................................................ ១២

ច. រចនាសម្ព័ន្ធ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ ............................................................ ១៣

**យន្តការស្ថាប័ន និង រចនាសម្ព័ន្ធគ្រប់គ្រង របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ (CCDM)** ....... ១៤
ក- អំពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ........ ១៤
ខ- រចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ........ ១៤
គ-ភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់........ ១៥
ឃ- ក្បាលម៉ាស៊ីនដឹកនាំ និងតួនាទីការទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន គ.គ.ម.ឃ-សង្កាត់........ ១៦
១.ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់........ ១៦
២. អនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់........ ១៧
៣. លេខាធិការដ្ឋាន :........ ១៧
៤. ក្រុមសន្តិសុខ និងរុករកសង្គ្រោះ........ ១៧
៥. ក្រុមសុខភាព និងអនាម័យ........ ១៨
៦. ក្រុមឆ្លើយតប និង ព័ត៌មាន :........ ១៨
ង-រចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ឃុំ........ ២០

## ផ្នែកទី២: ការយល់ដឹងពីមូលដ្ឋានគ្រឹះពីគ្រោះមហន្តរាយ

I. មុខសញ្ញាបង្កគ្រោះមហន្តរាយ ........ ២២
១. និយមន័យ........ ២២
២. ប្រភេទមុខសញ្ញាបង្កគ្រោះមហន្តរាយ........ ២២
២.១ ទឹកជំនន់........ ២២
ក. ទឹកជំនន់នៅតាមដងទន្លេ........ ២៣
ខ. ទឹកជំនន់ឡើងរហ័ស........ ២៣
២.២. គ្រោះរាំងស្ងួត ........ ២៣
ក. គ្រោះរាំងស្ងួតខាងឧត្តុនិយម ........ ២៥
ខ. គ្រោះរាំងស្ងួតខាងជលសាស្ត្រ........ ២៥
គ. គ្រោះរាំងស្ងួតខាងកសិកម្ម........ ២៥
២.៣. ជំងឺរាតត្បាត........ ២៦
២.៤ ខ្យល់ព្យុះ........ ២៦
២.៥ ភ្លើងឆេះព្រៃ និង អគ្គីភ័យ ........ ២៧

II. ភាពងាយរងគ្រោះ.................................................................................................................................២៨
១. និយមន័យ.........................................................................................................................................២៨
២. មូលហេតុនៃភាពងាយរងគ្រោះ..............................................................................................................២៨
III. គ្រោះមហន្តរាយ.................................................................................................................................២៩
១. និយមន័យ.........................................................................................................................................២៩
២. គ្រោះមហន្តរាយនៅកម្ពុជា...................................................................................................................២៩
៣. ទំនាក់ទំនងរវាងមុខសញ្ញាបង្កគ្រោះថ្នាក់ និង ភាពងាយរងគ្រោះ បង្កបានជាគ្រោះមហន្តរាយ.................... ៣១

**ផ្នែកទី៣: ការយល់ដឹងពីការគ្រប់គ្រងគ្រោះមហន្តរាយ**.......................................................................................៣៤
១.និយមន័យ..........................................................................................................................................៣៤
២. ដំណាក់កាលនៃការងារគ្រប់គ្រងគ្រោះមហន្តរាយ.......................................................................................៣៤
ក. ដំណាក់កាលមុនគ្រោះមហន្តរាយ.............................................................................................................៣៥
ខ. ដំណាក់កាលក្នុងពេលគ្រោះមហន្តរាយ....................................................................................................៣៧
គ. ដំណាក់កាលក្រោយពេលគ្រោះមហន្តរាយ.................................................................................................៣៩

**ផ្នែកទី៤: ការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់**
១. តើអ្វីទៅជាការប៉ាន់ប្រមាណលើ មុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព?.............................៤២
២. តើធាតុសំខាន់ៗរបស់ **HVCA** មានអ្វីខ្លះ?..........................................................................................៤២
ក. ការប៉ាន់ប្រមាណលើមុខសញ្ញាគ្រោះមហន្តរាយ........................................................................................៤២
ខ. ការប៉ាន់ប្រមាណភាពងាយរងគ្រោះ..........................................................................................................៤២
គ. ការប៉ាន់ប្រមាណលើសមត្ថភាព...............................................................................................................៤៣
ឃ. ជំហាននៃការអនុវត្ត **HVCA**..................................................................................................................៤៣
ង. តើយើងត្រូវធ្វើការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះមហន្តរាយតាមរបៀបណា?............................................... ៤៤
ច. តើយើងត្រូវធ្វើការប៉ាន់ប្រមាណភាពងាយរងគ្រោះតាមរបៀបណា?.............................................................. ៤៥
ឆ. តើយើងត្រូវធ្វើការប៉ាន់ប្រមាណសមត្ថភាពរីធនធានតាមរបៀបណា?............................................................. ៤៦

**ផ្នែកទី៥: កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍**

១. តើអ្វីគឺជាការត្រៀមបង្ការគ្រោះមហន្តរាយ? ....... ៤៩
២. ហេតុអ្វីបានជាចាំបាច់ត្រូវយកចិត្តទុកដាក់លើការងារត្រៀមបង្ការគ្រោះមហន្តរាយ? ....... ៥០
៣. អ្វីជាផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ? ....... ៥១
៤. តើផែនការត្រៀមបង្ការគ្រោះទឹកជំនន់មានផលប្រយោជន៍អ្វីខ្លះ ? ....... ៥១
៥. ប្រសិទ្ធិភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ....... ៥២
៦. តើអ្នកណាជាអ្នកពាក់ព័ន្ធនៅក្នុងការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ? ....... ៥៥
៧. ហេតុអ្វីយើងចាំបាច់ត្រូវអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍ ? ....... ៥៧
៨. ដំណើរការអនុវត្តន៏កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍ ....... ៥៧
**ក. តើត្រូវធ្វើយ៉ាងណាដើម្បីអោយសហគមន៍មួយអាចក្លាយទៅជាសហគមន៍ ដែលអាចត្រៀមខ្លួនរួច ជាស្រេចចំពោះព្រឹត្តិការណ៍គ្រោះមហន្តរាយដែលកើតឡើង?** ....... ៥៧

**ផ្នែកទី៦: វិធានការគន្លឹះ សំរាប់ការងារត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យទឹកជំនន់តាមសហគមន៍**

**មេរៀនទី ៦.១: ប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់នៅតាមសហគមន៍** ....... ៦១
១. និយមន័យ ....... ៦១
២. បណ្តាញជាតិសំរាប់ព្យាករណ៏ និង ផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ ....... ៦១
៣. ដំណាក់កាលនៃការព្យាករណ៏ និង ការផ្តល់ពតិមានជាមុន ....... ៦៣
៣. កម្មវិធីផ្តល់ពតិមានជាមុនពីទឹកជំនន់តាមសហគមន៏ ....... ៦៤
ក. គំរោងផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់អនុវត្តដោយគណៈកម្មការទន្លេមេគង្គ ....... ៦៤
ខ. គំរោងប្រព័ន្ធផ្តល់ពតិមានជាមុនពីទឹកជំនន់របស់អង្គការប្រឆាំងគ្រោះអត់ឃ្លាន **(ACF)** ....... ៦៦
គ. គំរោងប្រព័ន្ធផ្តល់ពតិមានជាមុនពីទឹកជំនន់ របស់អង្គការអុកស្វាមអង់គ្លេស (OGB) ....... ៦៧
ឃ. ការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធផ្តល់ពតិមានជាមុនពីទឹកជំនន់នៅថ្នាក់សហគមន៏ ....... ៦៧

**មេរៀនទី ៦.២: ការជម្លៀស និងការគ្រប់គ្រងទីកន្លែងជម្លៀស** ....... ៦៩
ក. និយមន័យ ....... ៦៩
ខ. ចំណុចសំខាន់ៗ ដែលត្រូវយកចិត្តទុកដាក់នៅពេលការជម្លៀស : ....... ៦៩

គ. ការគ្រប់គ្រងទឹកន្លែងជម្លៀស : ........ ៧០
ឃ. មុខងារ និងការទទួលខុសត្រូវរបស់គណៈកម្មការនានា: ........ ៧១

**មេរៀនទី ៦.៣: តួនាទីរបស់ស្ត្រីលើសកម្មភាពចូលរួមត្រៀមបង្ការគ្រោះទឹកជំនន់** ........ ៧៣
**មេរៀនទី ៦.៤: ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រង បញ្ជីធនធាន និងសំភារៈសារពើភណ្ឌ** ........ ៧៤
១. សារៈសំខាន់នៃការគ្រប់គ្រងធនធាន ........ ៧៤
២. ប្រភពធនធាន ........ ៧៥
ក. ធនធានតាមផ្ទះសម្បែង ថ្នាក់ភូមិ និងថ្នាក់ឃុំ : ........ ៧៥
ខ. ធនធាននៅថ្នាក់ស្រុក : ........ ៧៦
គ. ធនធាននៅថ្នាក់ខេត្ត : ........ ៧៧
ឃ. ធនធាននៅថ្នាក់ជាតិ : ........ ៧៨

**មេរៀនទី ៦.៥: ការគ្រប់គ្រងសុខភាពសាធារណៈ** ........ ៨០
១ និយមន័យ ........ ៨០
២. វិធានការណ៍នានាសំរាប់ត្រៀមបង្ការ និង កាត់បន្ថយគ្រោះថ្នាក់ ........ ៨១
ក- វិធីបង្ការកុំអោយលង់ទឹក: ........ ៨១
ខ- វិធីបង្ការសត្វពស់ចឹក: ........ ៨១
គ- វិធីបង្ការជំងឺឆ្លងផ្សេងៗ និង ជំងឺកង្វះអាហារូបត្ថម្ភ: ........ ៨២
ឃ- វិធីបង្ការជំងឺលើទារក(ក្រោមអាយុ ៥ឆ្នាំ) នៅពេលទឹកជំនន់: ........ ៨២
ង- ការត្រៀមសំភារៈប្រើប្រាស់ និងស្បៀងអាហារផ្សេងៗ ........ ៨៣
ច- របៀបថែរក្សាទឹកស្អាតសំរាប់បរិភោគ: ........ ៨៣
៣. បទដ្ឋានសំខាន់ៗដែលត្រូវយកមកគិតគូរសំរាប់បំរើឱ្យស្ថានភាពសុខភាព និងជីវភាពរបស់សហគមន៍ក្នុងពេលមានគ្រោះទឹកជំនន់ ........ ៨៤

**ផ្នែកទី៧: ការធ្វើសមាហរណកម្ម កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់**
១. អ្វីទៅជាផែនការអភិវឌ្ឍន៍ឃុំ និងផែនការវិនិយោគឃុំ-សង្កាត់? ........ ៨៧
ក. និយមន័យ

ខ. ទិដ្ឋភាពរួម ........ ៨៧
គ. គោលបំណង........ ៨៧
ឃ. គោលគំនិតសំខាន់ៗ ........ ៨៨
ង. ការធ្វើសមាហរណកម្មលើវិស័យអាទិភាពទាំង០៥ របស់ឃុំ-សង្កាត់ ទៅក្នុងការងារ គ្រប់គ្រងគ្រោះមហន្តរាយ:........ ៨៩
ច. ការងារគ្រប់គ្រងគ្រោះមហន្តរាយ: ........ ៩១

គំរោងវិនិយោគឃុំទាក់ទិននឹងការកាត់បន្ថយគ្រោះទឹកជំនន់ សំរាប់អនុវត្តក្នុងឆ្នាំ២០០៨ ស្ថិតក្នុងស្រុកគោលដៅទាំង០៤ នៃខេត្តកណ្តាល និងព្រៃវែង របស់ ADPC ........ ៩៤
២. អនុសាសន៍ផ្សេងៗ លើការធ្វើសមាហរណកម្ម: ........ ៩៧

# សេចក្តីផ្តើម

ឯកសារបណ្តុះបណ្តាល ស្តីពី **ការគ្រប់គ្រងគ្រោះទឹកជំនន់តាមសហគមន៍ សំរាប់ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ** ត្រូវបានបង្កើតឡើងផ្អែកលើការប៉ាន់ប្រមាណលើតំរូវការរបស់ អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ដើម្បីធ្វើឱ្យប្រសើរឡើងនូវការធ្វើផែនការត្រៀមបង្ការទឹកជំនន់នៅ ក្នុងប្រទេសកម្ពុជា ឡាវ និង វៀតណាម ។ ឯកសារមេរៀននេះ នឹងជួយដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយថ្នាក់ស្រុក និងខេត្តនៃបណ្តាប្រទេសនៅតាមមាត់ទន្លេទាំងនេះក្នុងការបង្កើតនិងអនុវត្តលើ **កម្មវិធីត្រៀមបង្ការទឹកជំនន់** ។ ម្យ៉ាងទៀត ឯកសារនេះអាចប្រើប្រាស់ជាសៀវភៅមគ្គុទេសក៏នេះ សំរាប់ធ្វើការបណ្តុះ បណ្តាលដល់មន្ត្រីគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ជាតិ អ្នកអនុវត្តការងារផ្ទាល់ ក៏ដូចជា អង្គការ NGOs ដើម្បីកសាងសមត្ថភាពរបស់ពួកគេ ក្នុងការចូលរួមអនុវត្តលើវិធានការត្រៀមបង្ការគ្រោះទឹកជំនន់ ។

ឯកសារនេះបង្កើតឡើងដោយ **មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី** ហៅកាត់ថា (ADPC) តាមរយៈអ្នកឯកទេសផ្ទៃក្នុងរបស់ខ្លួន មេរៀនបណ្តុះបណ្តាលនានា និងឯកសារយោងមួយចំនួន ទៀតស្តីពីទឹកជំនន់ ក៏ដូចជាមានការចូលរួមផ្តល់យោបល់ពីមន្ត្រីជំនាញសំខាន់ៗមកពី លេខាធិការដ្ឋានគណៈកម្មការ ទន្លេមេគង្គ (MRCs) គណៈកម្មការជាតិទន្លេ មេគង្គ (NMCs) ការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយជាតិ (NDMO) និងគណៈកម្មាធិការ-ការិយាល័យថ្នាក់ស្រុកនិងខេត្ត នានា ក្រោយពីមានកិច្ចពិគ្រោះយោបល់ កម្មវិធីបណ្តុះបណ្តាលថ្នាក់ជាតិ និងថ្នាក់ខេត្ត ជាច្រើនលើក និងតាមរយៈដំណើរការបង្កើត កម្មវិធីត្រៀមបង្ការ ទឹកជំនន់ជាក់ស្តែងនៅតាមខេត្ត និងតាមស្រុក នៅតាមបណ្តាប្រទេសដីសណ្តទន្លេមេគង្គក្រោម ជាពិសេស ប្រទេស កម្ពុជា និងប្រទេសឡាវ ។ ឯកសារមេរៀននេះ ក៏ជាលទ្ធផលមួយនៃផ្នែកទាំង០៤ របស់កម្មវិធីកាត់បន្ថយនិង គ្រប់គ្រងគ្រោះទឹកជំនន់ (FMMP) របស់គណៈកម្មការទន្លេមេគង្គ (MRC) ផងដែរ ។ ADPC សហការជាមួយ MRC បាននឹងកំពុងអនុវត្តគំរោងកម្មវិធីទាំង០២ខាងលើ សំដៅពង្រឹងសមត្ថភាពដល់អាជ្ញាធរថ្នាក់ខេត្តនិង ស្រុក ។

- *ការពង្រឹងការគ្រប់គ្រងគ្រោះទឹកជំនន់ (FEMS)* ផ្អែកទី៤ នៃកម្មវិធីគ្រប់គ្រងនិងកាត់បន្ថយ ទឹកជំនន់របស់ MRCចាប់តាំងពីខែកញ្ញា ២០០៤ ដោយមានការឧបត្ថម្ភថវិកាពីអង្គការ GTZ ។
- ការកសាងសមត្ថភាពសំរាប់កម្មវិធីធ្វើផែនការ និងអនុវត្តការត្រៀមបង្ការទឹកជំនន់នៅថ្នាក់ខេត្តនិងស្រុក នៅតាមដីសណ្តទន្លេមេគង្គក្រោម ចាប់តាំងពីឆ្នាំ២០០៣ ស្ថិតក្នុង០៣ដំណាក់កាល ។ ដំណាក់កាលទី ១: ពីឆ្នាំ ២០០៣-២០០៤ ដំណាក់កាលទី ២: ពីឆ្នាំ២០០៥-២០០៦ និង ដំណាក់កាលទី ៣: ពីឆ្នាំ២០០៧-

២០០៨ ក្រោមជំនួយឧបត្ថម្ភថវិកាពី ECHO សំរាប់អនុវត្ត ផែនការសកម្មភាពនៅ អាស៊ីខាងត្បូងភាគឈៀងខាងកើតរបស់ DIPECHO ។

នៅក្នុងកំឡុងពេលនៃការប្រតិបត្តិគំរោងកម្មវិធីខាងលើ មេរៀនសំរាប់ការបណ្តុះបណ្តាលមួយ ត្រូវបានបង្កើតឡើងនៅក្នុង ឆ្នាំ២០០៣ ដើម្បីកសាងសមត្ថភាពអាជ្ញាធរមូលដ្ឋានថ្នាក់ខេត្ត និងស្រុក ស្តីពីការរៀបចំធ្វើផែនការ និងការអនុវត្តន៏កម្មវិធី ត្រៀមបង្ការ ទឹកជំនន់។ មេរៀនបណ្តុះបណ្តាល គឺរៀបចំឡើង ផ្អែកលើចំណុចខ្លាំង និងមេរៀនដែលទទួលបានកន្លងមក គួបផ្សំជាមួយគំនិតផ្តួចផ្តើម ពីការគ្រប់គ្រងគ្រោះ មហន្តរាយនៅក្នុងតំបន់ និងបានមកពីតំបន់អាស៊ីភាគខាងត្បូងផ្សេងទៀត។ រវាងខែកញ្ញាឆ្នាំ២០០៣ ដល់ ខែកក្កដា ឆ្នាំ២០០៤ ក្រោមដំណាក់កាលទី១ របស់គំរោងកម្មវិធី MRC- ADPC ECHO ការបណ្តុះបណ្តាល ថ្នាក់ជាតិសរុបចំនួន ០២ លើក: លើកទី១ រៀបចំនៅក្នុងប្រទេសកម្ពុជា (ចំនួន ៤ ខេត្ត) និង លើកទី២ រៀបចំនៅ ប្រទេសវៀតណាម (ចំនួន ២ ខេត្ត) សុទ្ធតែបានប្រើប្រាស់ឯកសារមេរៀននេះ សំរាប់ធ្វើការបណ្តុះបណ្តាល ។ បន្ថែមលើនេះទៅទៀត សិក្ខាសាលាថ្នាក់ជាតិចំនួន ០២លើកទៀត (មួយលើកធ្វើនៅប្រទេសថៃ និងមួយលើក ទៀតធ្វើនៅប្រទេសឡាវ) ស្តីពីការធ្វើផែនការ ត្រៀមបង្ការទឹកជំនន់ ត្រូវបានធ្វើឡើង ហើយមេរៀនបណ្តុះ បណ្តាលត្រូវបានកែលំអឡើងវិញ។ នៅក្នុងកំឡុងពេលដំណាក់កាលទី ៣ របស់គំរោងកម្មវិធី MRC-ADPC ECHO រវាងឆ្នាំ២០០៥-២០០៦ មេរៀនបណ្តុះបណ្តាល ត្រូវបានយកមកប្រើប្រាស់នៅក្នុងលក្ខ័ណ្ឌ និងភាសា ជាក់លាក់របស់ប្រទេសចំនួន ០៣ ហើយជាសរុបការបណ្តុះបណ្តាលថ្នាក់ខេត្តចំនួន ៣ ត្រូវបានធ្វើឡើងនៅក្នុង ប្រទេសកម្ពុជា វៀតណាម និងឡាវ ហើយដំណើរការធ្វើផែនការត្រៀមបង្ការ ទឹកជំនន់ថ្នាក់ស្រុកមួយ ត្រូវបាន ធ្វើចប់សព្វគ្រប់នៅខេត្តក្រចេះ។

នៅក្រោមគំរោងកម្មវិធី MRC-ADP-GTZ ឯកសារមេរៀននេះ ត្រូវបានប្រើប្រាស់សំរាប់ធ្វើការបណ្តុះបណ្តាលជាច្រើនវគ្គនៅ តាមបណ្តាខេត្ត ដែលឧបត្ថមថវិកាគាំទ្រគំរោងសំរាប់ដំណាក់កាលទី២ ដោយ ECHO ។ ក្រោយមកឯកសារនេះ ត្រូវបានកែប្រែទៅជា សៀវភៅមគ្គុទេសក៏សំរាប់បំរើឱ្យការងារប្រតិបត្តិជាក់ស្តែង ស្តីពី *"ការត្រៀមបង្ការទឹកជំនន់សំរាប់អាជ្ញាធរមូលដ្ឋានក៏រិតស្រុក និខេត្ត នៅតាមបណ្តាប្រទេសដីសណ្តរទន្លេមេគង្គ "*។ នៅឆ្នាំ ២០០៥-២០០៦កន្លងទៅនេះ ឯកសារសារមេរៀនពង្រាងនេះ ត្រូវបានប្រើប្រាស់ សំរាប់បើកវគ្គហ្វឹកហ្វឺនពី កម្មវិធីត្រៀមបង្ការទឹកជំនន់ថ្នាក់ខេត្តចំនួន ០២លើក និង ថ្នាក់ស្រុកចំនួន ០៤លើក នៅក្នុងប្រទេសកម្ពុជា ក្រោមគំរោងកម្មវិធីរបស់ MRC-ADPC-GTZ។ សិក្ខាសាលា និងការបណ្តុះបណ្តាល ស្តីពីដំណើរការធ្វើផែនការ ត្រៀមបង្ការទឹកជំនន់ថ្នាក់ខេត្ត នៅតាមស្រុកនិងឃុំគោលដៅទាំងអស់ស្ថិតក្នុង ខេត្តព្រៃវែង ខេត្តកណ្តាល និង ខេត្តក្រចេះ ក៏នៅបានប្រើប្រាស់នូវឯកសារពង្រាងនេះ ដែរ។

# ផ្នែកទី ១
# យន្តការស្ថាប័ន និង រចនាសម្ពន្ធ័គ្រប់គ្រង របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ នៅកម្ពុជា

# យន្តការស្ថាប័ន និង រចនាសម្ព័ន្ធគ្រប់គ្រង របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ

នៅក្នុង ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជា (RGC) បានផ្តួចផ្តើមគំនិត រៀបចំអោយមានគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ហៅកាត់ថា (NCDM)។ បន្ទាប់មកនៅឆ្នាំ២០០២ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ត្រូវបានបង្កើតឡើង យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលមានសមាជិក ដូចខាងក្រោម :

## គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)

( **ព្រះរាជក្រឹត្យលេខ** នស/រកត/០២០២/០៤០ ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០២ )

### ក. សមាសភាព

| | |
|---|---|
| ១. នាយករដ្ឋមន្ត្រី | ប្រធាន |
| ២. មន្ត្រីជាន់ខ្ពស់ (Senior Minister) | អនុប្រធានទី១ |
| ៣. មន្ត្រីជាន់ខ្ពស់ (Senior Minister) | នុប្រធានទី២ |
| ៤. រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥. រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៦. រដ្ឋមន្ត្រីទទួលបន្ទុកការិយាល័យក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧. រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៨. រដ្ឋមន្ត្រី ក្រសួងកិច្ចការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៩. រដ្ឋមន្ត្រី ក្រសួងបរិស្ថាន | សមាជិក |
| ១០. រដ្ឋមន្ត្រី ក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| ១១. រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និង នេសាទ | សមាជិក |
| ១២. រដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៣. រដ្ឋមន្ត្រី ក្រសួងសុខាភិបាល | សមាជិក |
| ១៤. រដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១៥. រដ្ឋមន្ត្រី ក្រសួងឧស្សាហាកម្ម រ៉ែ និង ថាមពល | សមាជិក |
| ១៦. រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងការស្តារយុវនីតិសម្បទា | សមាជិក |

| | |
|---|---|
| ១៧. រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| ១៨. រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៩. រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី | សមាជិក |
| ២០. តំណាងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | សមាជិក |
| ២១. តំណាងប្រធានកាកបាទក្រហមជាតិកម្ពុជា | សមាជិក |
| ២២. រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |

## ខ. បេសកកម្ម

ដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយ នៅព្រះរាជាណាចក្រកម្ពុជា ។

## គ. មុខងារ និង ភារកិច្ច

១. ធ្វើការសំរបសំរួលជាមួយក្រសួង ស្ថាប័ន របស់រាជរដ្ឋាភិបាល ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល សហគមន៍អន្តរជាតិ និងសប្បុរសជនក្នុងស្រុក ដើម្បីគៀងគរជំនួយសំរាប់ឆ្លើយតប សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ ។

២. ផ្តល់យោបល់ជូនរាជរដ្ឋាភិបាល ដាក់ចេញគោលការណ៍ គោលនយោបាយសំខាន់ៗ សេចក្តី ប្រកាស ដើម្បីត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ ព្រមទាំងវិធានការណ៍ឆ្លើយតប សង្គ្រោះបន្ទាន់ ការធ្វើអន្តរាគមន៍ជំលៀសប្រជាជនទៅទីសុវត្ថិភាព។

៣. ផ្សព្វផ្សាយការងារគ្រប់គ្រងគ្រោះមហន្តរាយដល់សហគមន៍ និងពង្រឹងខ្សែបណ្តោយពីថ្នាក់ជាតិ ក្រសួង ស្ថាប័នរាជរដ្ឋាភិបាលមានការពាក់ព័ន្ធ រហូតដល់ខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ ព្រមទាំងបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីបង្កើនសមត្ថភាពការងារគ្រប់គ្រងគ្រោះមហន្តរាយ អោយកាន់តែរឹងមាំ និងមានប្រសិទ្ធិភាព ។

៤. លើកសំណើជូនរាជរដ្ឋាភិបាលអំពីការត្រៀមបំរុងទូវមូលនិធិ សំភារៈ ប្រេងឥន្ទនៈ មធ្យោបាយ ធនធានមនុស្ស ដើម្បីត្រៀមបង្ការ និងធ្វើអន្តរាគមន៍ឆ្លើយតបសង្គ្រោះបន្ទាន់ និងស្តារឡើង វិញមុនពេល ក្នុងពេល និងក្រោយពេលកើតមានគ្រោះមហន្តរាយដើម្បីភាពម្ចាស់ការជាមុន។

## ឃ. អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ គ្រប់គ្រង និង ដឹកនាំនាយកដ្ឋានចំនួន ៥ ដូចខាងក្រោម :

១. នាយកដ្ឋាន រដ្ឋបាល និង ហិរញ្ញវត្ថុ

២. នាយកដ្ឋាន ពតិមាន និង ទំនាក់ទំនង

៣. នាយកដ្ឋាន ឆ្លើយតបសង្គ្រោះបន្ទាន់ និង ស្តារឡើងវិញ

៤. នាយកដ្ឋាន ត្រៀមរៀបចំ និង ស្តារឡើងវិញ

៥. នាយកដ្ឋាន សំរបសំរួលការងាររុករក ឧបទ្ទវហេតុយន្តហោះ និង នាវា។

## ➢ តួនាទី និង ការទទួលខុសត្រូវៈ

អគ្គលេខាធិការដ្ឋានមានភារកិច្ច និង ការទទួលខុសត្រូវដូចតទៅ :

0 ធានានិរន្តភាព និង មុខងាររបស់រដ្ឋបាលគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។

១ រៀបចំស្រាវជ្រាវទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ ភ្លើងឆេះព្រៃ រោគរាតត្បាតនៅក្នុងតំបន់ប្រឈម និងគ្រោះថ្នាក់ផ្សេងៗ ដោយការរៀបចំធ្វើផែនការត្រៀមបង្ការ និងឆ្លើយតបគ្រោះអាសន្ន ។

២ ណែនាំគណៈកម្មាធិការខេត្ត-ក្រុង ស្រុក ឃុំ គ្រប់គ្រងគ្រោះមហន្តរាយ និងសហគមន៏ជំនួយសង្គ្រោះ អំពីការងារ និងជំនាញបច្ចេកទេស ដែលជាមូលដ្ឋានប្រមូលទិន្នន័យគ្រោះមហន្តរាយ និងការប៉ាន់ប្រមាណតំរូវការ និង រៀបចំកម្មវិធីស្តារនិតិសម្បទា និងការសាងសង់ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត ដោយសហការជាមួយ

៣ ស្ថាប័ន ភ្នាក់ងារអង្គការសហប្រជាជាតិ អន្តរជាតិ និងអង្គការពាក់ព័ន្ធនានា។

៤ រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសសំរាប់មន្ត្រីដែលបំរើមុខងារគ្រប់គ្រងគ្រោះមហន្តរាយនៅតាមខេត្ត ក្រុង ស្រុក ឃុំ និងជំនួយសង្គ្រោះសហគមន៏ ទាំងក្នុង និង ក្រៅប្រទេស។

៥ សំរបសំរួលការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ទីភ្នាក់ងារអង្គការសហប្រជាជាតិអង្គការ ជាតិ និងអង្គការអន្តរជាតិ ដើម្បីជំលៀសប្រជាជនដែលងាយរងគ្រោះទៅកាន់ទីកន្លែងសុវត្ថិភាព និងផ្តល់ឱ្យពួក គេនូវសន្តិសុខ ការអប់រំជាសាធារណៈ ការឆ្លើយតបគ្រោះអាសន្ន និងកម្មវិធីផ្សេងៗ។

៦ ផ្តល់យោបល់អំពីឯកសារពាក់ព័ន្ធទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ និង លិខិតយល់ព្រម ។ បូកសរុបរបាយ-ការណ៏ និង ដាក់ជូនទៅគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ។

## ១. រចនាសម្ព័ន្ធ របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM)



ឧបសម្ព័ន្ធទី ១

# យន្តការស្ថាប័ន និង រចនាសម្ព័ន្ធគ្រប់គ្រង
# របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង (PCDM)

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ត្រូវបានរៀបចំឡើង យោងតាមព្រះរាជក្រឹតលេខ ៣០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៩ មេសា ឆ្នាំ ២០០២ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុងត្រូវបានរៀបចំឡើង ដែលមានសមាសភាព រចនាសម្ព័ន្ធ និង តួនាទី-ភារកិច្ច ដូចខាងក្រោម :

## ក. សមាសភាព

| | |
|---|---|
| ១. អភិបាល ខេត្ត | ជាប្រធាន |
| ២. អភិបាលរងខេត្តទាំងអស់ | ជាអនុប្រធាន |
| ៣. ប្រធាន មន្ទីរ និង អង្គភាព | ជាសមាជិក |
| ៤. នាយខុទ្ទកាល័យខេត្ត | ជាលេខាអចិន្ត្រៃយ៍ និងជំនួយការ ។ |

## ខ. តួនាទី និង ការទទួលខុសត្រូវ

១. អនុវត្តគោលនយោបាយជាតិ ស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។

២. រៀបចំធ្វើការណែនាំនិងគាំទ្រដល់សកម្មភាពគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ។

៣. ផ្តល់យោបល់ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយជាតិ ចំពោះសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ កាកបាទក្រហមកម្ពុជា ការឧបត្ថម្ភរបស់អង្គការជាតិ និងអន្តរជាតិ ដែលចូលរួមទប់ស្កាត់ ត្រៀមបង្ការ សង្គ្រោះបន្ទាន់ និងស្តារឡើងវិញ ។

៤. ធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយជាតិ ស្តីពីការខូចខាត និងធ្វើសំណើសុំឧបត្ថម្ភថវិកា សំភារៈបរិក្ខារ មធ្យោបាយ និងកំលាំងអន្តរាគមន៍ សំរាប់ដោះស្រាយក្នុងពេល មានគ្រោះមហន្តរាយ ។

៥. អនុវត្តកម្មវិធីបណ្តុះបណ្តាលពង្រឹងជំនាញបច្ចេកទេសដល់មន្ត្រីរាជការក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ និងអនុវត្តកម្មវិធីអប់រំ ជាសាធារណៈនៅក្នុងសហគមន៍ ។

**គ. លេខាធិការដ្ឋាន អចិន្ត្រៃយ៍**

ដើម្បីធានាបាននូវនិរន្តរភាពការងារជាប្រចាំ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង បានរៀបចំអោយមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមាននាយខុទ្ទការល័យសាលាខេត្ត-ក្រុង ជាប្រធាន និង ប្រធានមន្ទីរ-អង្គភាពពាក់ព័ន្ធជាសមាជិក។

**ឃ. តួនាទី និង ភារកិច្ចរបស់លេខាអចិន្ត្រៃយ៍ មានដូចតទៅ :**

**ង. ក្រុមប្រតិបត្តិការ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត_ក្រុង**

ក្រោមការដឹកនាំរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង និមួយ ៗ បានរៀបចំអោយមានក្រុមប្រតិបត្តិការ ចំនួន ០៤ ដើម្បីជាជំនួយការអោយ លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៅក្នុងការប្រតិបត្តិការងារ

១. ក្រុមប្រតិបត្តិការរុករកសង្គ្រោះ និង សន្តិសុខ

២. ក្រុមសុខភាព អនាម័យ និង ទឹកស្អាត

៣. ក្រុមគ្រប់គ្រងពត៌មាន និង ផ្សព្វផ្សាយ

៤. ក្រុមឆ្លើយតប និង សង្គ្រោះ

## ច. រចនាសម្ព័ន្ធ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត (ខេត្តកណ្ដាល)



**ឧបសម្ព័ន្ធទី ១**

# យន្តការស្ថាប័ន និង រចនាសម្ព័ន្ធគ្រប់គ្រង
# របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខណ្ឌ (DCDM)

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌបានបង្កើតឡើង យោងតាមព្រះរាជក្រឹតលេខ ៣០ អ.ន.ក្រ.បក ចុះថ្ងៃទី ០៩ មេសា ឆ្នាំ ២០០២ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ និង ផ្អែកតាមដីការបង្គាប់របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ។

## ក. សមាសភាព

| | |
|---|---|
| ៥. អភិបាលស្រុក | ជាប្រធាន |
| ៦. អភិបាលរងស្រុក ០១ រូប | ជាអនុប្រធាន |
| ៧. កងកំលាំងប្រដាប់អាវុធទាំង០៣ប្រភេទ និងការិយាល័យជុំវិញស្រុក | ជាសមាជិក |
| ៨. ប្រធានមន្ទីរសាលាស្រុក ជាលេខាអចិន្ត្រៃយ៍ និងប្រធានការិយាល័យចំនួន ០៣រូប | ជាជំនួយការ ។ |

## ខ. តួនាទី និងការទទួលខុសត្រូវ

១. អនុវត្តគោលការណ៍ ដែលទាក់ទងទៅនឹងការងារគ្រប់គ្រងគ្រោះមហន្តរាយ ។

២. ទំនាក់ទំនង និងផ្តល់ព័ត៌មានទាន់ពេលវេលា ជូន គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត-ក្រុង ។

៣. ត្រៀមបង្ការទប់ទល់គ្រប់កាលៈទេសៈ ។

៤. សហប្រតិបត្តិការ នៅពេលកើតមានគ្រោះមហន្តរាយ ។

៥. ជួយសង្គ្រោះបន្ទាន់ និងការស្តារឡើងវិញ ។

៦. ធ្វើផែនការ កម្មវិធីជំនាញ លើកគំរោងស្នើសុំជាថវិកា សំភារៈ មធ្យោបាយ និងធ្វើរបាយការណ៍ជូនទៅគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត-ក្រុង ។

៧. ដឹកនាំដោយផ្ទាល់កិច្ចប្រតិបត្តិការក្នុងពេលមានគ្រោះមហន្តរាយ រួមមានៈ ជំនួយសង្គ្រោះ ការជំលៀស ការផ្តល់ទីជំរក និង ផ្តល់ជំនួយសុខាភិបាល... ។

៨. ទំនាក់ទំនងនិងអំពាវនាវដល់កាកបាទក្រហមកម្ពុជា អង្គការមនុស្សធម៌ជាតិ-អន្តរជាតិ សមាគមនានា ដើម្បីចូលរួមជួយសហការឧបត្ថម្ភដល់ការការងារគ្រប់គ្រងគ្រោះមហន្តរាយ ។

**គ. លេខាធិការដ្ឋាន អចិន្ត្រៃយ៍**

ដើម្បីធានាបាននូវនិរន្តរភាពការងារជាប្រចាំ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ បានរៀបចំអោយមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដែលមានប្រធានការិយាល័យសាលាស្រុក-ខ័ណ្ឌ ជាប្រធាន និង ប្រធានការិយាល័យ-អង្គភាពពាក់ព័ន្ធជាសមាជិក។

**ឃ. តួនាទី និង ភារកិច្ចរបស់លេខាអចិន្ត្រៃយ៍ មានដូចតទៅ :**

**ង. ក្រុមប្រតិបត្តិការ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក_ខ័ណ្ឌ**

ក្រោមការដឹកនាំរបស់លេខាធិការដ្ឋានអចិន្ត្រៃយ៍ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ និមួយ ៗ បានរៀបចំអោយមានក្រុមប្រតិបត្តិការ ចំនួន ០៤ ដើម្បីជាជំនួយការអោយ លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៅក្នុងការប្រតិបត្តិការងារ

៥. ក្រុមប្រតិបត្តិការរុករកសង្គ្រោះ និង សន្តិសុខ

៦. ក្រុមសុខភាព អនាម័យ និង ទឹកស្អាត

៧. ក្រុមគ្រប់គ្រងពតិមាន និង ផ្សព្វផ្សាយ

៨. ក្រុមឆ្លើយតប និង សង្គ្រោះ

ខាងក្រោមនេះ គឺជារចនាសម្ពន្ធ័ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក (DCDM)

## ច. រចនាសម្ព័ន្ធ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក_ខណ្ឌ



# យន្តការស្ថាប័ន និង រចនាសម្ព័ន្ធគ្រប់គ្រង
# របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ (CCDM)

## ក- អំពីការរៀបចំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ

មេឃុំ-ចៅសង្កាត់ត្រូវចេញដីកាសំរេចបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់របស់ខ្លួន ដែលមាន សមាសភាពដូចមាន :

| | | |
|---|---|---|
| ១. | មេឃុំ ឬ ចៅសង្កាត់ | ប្រធាន |
| ២. | ជំទប់ទី១ ឬ ចៅសង្កាត់រងទី១ | អនុប្រធាន |
| ៣. | ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ | សមាជិក |
| ៤. | ប្រធានកម្រងសាលាបឋមសិក្សា | សមាជិក |
| ៥. | ប្រធានមណ្ឌលសុខភាពឃុំ-សង្កាត់ | សមាជិក |
| ៦. | ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ | សមាជិក |
| ៧. | ភ្នាក់ងារសុខភាពសត្វឃុំ-សង្កាត់ | សមាជិក |
| ៨. | អ្នកស្ម័គ្រចិត្តកាកបាទក្រហម | សមាជិក |
| ៩. | ព្រឹទ្ធាចារ្យក្នុងឃុំ | សមាជិក |
| ១០. | ប្រធានភូមិគ្រប់ភូមិ | សមាជិក |
| ១១. | ស្មៀន | លេខាអចិន្ត្រៃយ៍ |

**បញ្ជាក់:** សមាសភាពខាងលើ គឺជាការចង្អុលបង្ហាញនៅពេលចេញដីកា ត្រូវកំណត់ឈ្មោះបុគ្គលទទួលខុសត្រូវឱ្យបានច្បាស់លាស់។

## ខ- រចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់មានរចនាសម្ព័ន្ធដូចតទៅ :

១. លេខាធិការដ្ឋានដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្មៀនឃុំ និងមានបុគ្គលិកជំនួយការមួយចំនួនតាមការចាំបាច់។

២. ក្រុមសន្តិសុខ រុករកសង្គ្រោះ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ជាប្រធាន និង ប្រធានកម្រងសាលាបឋមសិក្សាជាអនុប្រធាន ដោយមាននគរបាលឃុំ-សង្កាត់ គ្រូ និងសិស្សស្ម័គ្រចិត្តចូលរួមជាកំលាំងប្រតិបត្តិការ។

៣. ក្រុមសុខភាព អនាម័យ ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយប្រធានមណ្ឌលសុខភាពឃុំ (ក្នុងលក្ខណៈដែល ឃុំដែលពុំទាន់មានមណ្ឌលសុខភាពត្រូវយកអនុប្រធានមណ្ឌលសុខភាពពីឃុំរួមគ្នាមកទទួលគ្រប់គ្រង)

ភ្នាក់ងារសុខភាពសត្វជាអនុប្រធាន និង ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារ ជា អនុប្រធាន ដោយមានគ្រូពេទ្យឃុំ ភ្នាក់ងារសុខភាពសត្វភូមិ និងអ្នកស្ម័គ្រចិត្តជាកំលាំង ប្រតិបត្តិការ ។

៤. ក្រុមឆ្លើយតបនិងព័ត៌មាន ដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយអ្នកស្ម័គ្រចិត្តកាកបាទក្រហម ជាប្រធាន ព្រឹទ្ធាចារ្យក្នុងឃុំ ជាអនុប្រធាន និងអ្នកស្ម័គ្រចិត្ត ជាកំលាំងប្រតិបត្តិការ ។

## គ_ភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ_សង្កាត់

- អនុវត្តគោលនយោបាយដែលទាក់ទងទៅនឹងការគ្រប់គ្រងគ្រោះមហន្តរាយ
- កសាងផែនការត្រៀមបង្ការកាត់បន្ថយគ្រោះថ្នាក់ ត្រៀមរៀបចំដើម្បីការពារអាយុជីវិត មនុស្ស-សត្វ សន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាព ផលិតផល កសិកម្ម សេវាសាធារណៈ បរិស្ថាន និង អនុវត្តដើម្បីកាត់បន្ថយគ្រោះ ភ័យ នៅពេលមានមុខសញ្ញាគ្រោះថ្នាក់ពីធម្មជាតិ និងពីមនុស្សកើតឡើង ។
- សម្របសម្រួលផែនការខាងលើជាមួយគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ
- រៀបចំបង្កើត និង គ្រប់គ្រងទីសុវត្ថិភាព
- រៀបចំគោលការណ៍ណែនាំ អនុវត្ត និងគាំទ្រសកម្មភាពគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍
- ជាសេនាធិការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយនិង ផ្តល់យោបល់ពីសកម្មភាពរបស់ស្ថាប័នពាក់ព័ន្ធ សមាគមជាតិ ភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលរួមចំណែកក្នុងការងារកាត់បន្ថយគ្រោះមហន្តរាយ និង ភាពងាយរងគ្រោះនៅ មុនពេល ក្នុងពេល និងក្រោយពេលមានគ្រោះមហន្តរាយ ។
- រៀបចំចងក្រងក្រុមប្រតិបត្តិការសំរាប់ធ្វើសកម្មភាព រួមមាន :
  - ១. ក្រុមសន្តិសុខ និង រុករកសង្គ្រោះ
  - ២. ក្រុមសុខភាព និងអនាម័យ
  - ៣.ក្រុមឆ្លើយតប និង ពតិមាន
- ជ្រើសរើសអ្នកស្ម័គ្រចិត្តចូលរួមបំពេញការងារក្នុងក្រុមទាំង០៣
- រៀបចំកម្មវិធីបណ្តុះបណ្តាលដល់ក្រុមប្រតិបត្តិការទាំង០៣លើ ជំនាញទទួលខុសត្រូវ ព្រមទាំងអប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់មូលដ្ឋានសហគមន៍ពីគ្រោះភ័យនៃគ្រោះមហន្តរាយ មុខសញ្ញាគ្រោះថ្នាក់ វិធានការគ្រប់គ្រងគ្រោះភ័យ ។
- លើកគំរោងប្រើប្រាស់ថវិកា សំភារៈ បរិក្ខារ មធ្យោបាយប្រើប្រាស់ និងកំលាំង សំរាប់ធ្វើសកម្មភាពតាមដំណាក់នីមួយៗនៃការគ្រប់គ្រងគ្រោះមហន្តរាយដើម្បីដាក់ស្នើតាមលំដាប់ថ្នាក់របស់ខ្លួន និងអង្គការនានា ។

- ធ្វើរបាយការណ៍ជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ អំពីស្ថានភាពដែលនឹងអាចកើតមាន និង កើតមានមុខសញ្ញាគ្រោះថ្នាក់នៅមូលដ្ឋានសហគមន៍របស់ខ្លួន។
- ធ្វើរបាយការណ៍អំពីសភាពការណ៍គ្រោះមហន្តរាយជូនគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក-ខ័ណ្ឌ ។
- ផ្តល់ពត៌មានដល់ថ្នាក់លើរបស់ខ្លួនអំពីការកើតឡើងនូវមុខសញ្ញាគ្រោះថ្នាក់ឱ្យបានលឿន និង បន្ទាន់បំផុត។
- ធ្វើការប្រជុំ១ខែម្តងជាទៀងទាត់ ដើម្បីត្រួតពិនិត្យសកម្មភាពរបស់ក្រុមទាំង០៣ និង ដោះស្រាយបញ្ហាដែលកើតមានរបស់ក្រុមទាំង០៣ តាមការកោះអញ្ជើញរបស់ប្រធាន និងក្នុងលក្ខណៈមានគ្រោះអាសន្ន ត្រូវមានការកោះអញ្ជើញប្រជុំបន្ទាន់។

## ឃ_ ក្បាលម៉ាស៊ីនដឹកនាំ និងតួនាទីការទទួលខុសត្រូវរបស់ប្រធាន អនុប្រធាន គ.គ.ម.ឃ_សង្កាត់ លេខាធិការដ្ឋាន និង ក្រុមប្រតិបត្តិការ

### ១.ប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ_សង្កាត់

**អាណត្តិប្រធាន** : មេឃុំ ចៅសង្កាត់ ជាប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ មិនអាចយកអ្នកផ្សេងធ្វើជាប្រធានបានឡើយ ហើយមិនអាចបញ្ឈប់ពីមុខតំណែងប្រធានមុនអាណត្តិរបស់ខ្លួនជាមេឃុំ ឬចៅសង្កាត់នោះដែរ។

**តួនាទីរបស់ប្រធាន** :

- ដឹកនាំ និង សម្រេចកិច្ចការរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់ ក្នុងនាមជាប្រធាន និងក្នុងក្របខ័ណ្ឌជាមេឃុំ និងចៅសង្កាត់ រួមទាំងការចុះហត្ថលេខាលើការបង្កើតគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ក្រុមប្រតិបត្តិការទាំង០៣ ការណែនាំ ការប្រកាសប្រាប់ឱ្យដឹងមុនពីគ្រោះអាសន្ននៅក្នុងឃុំ-សង្កាត់របស់ខ្លួន និង លិខិតកោះអញ្ជើញប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់។
- ដឹកនាំការប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់។
- ធ្វើសហប្រតិបត្តិការ និង ដឹកនាំការអនុវត្តន៍គំរោងកម្មវិធីការងារគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយនៅមូលដ្ឋានសហគមន៍ជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងដៃគូនានា ដែលត្រូវអនុវត្តនៅក្នុងឃុំ-សង្កាត់របស់ខ្លួន។
- ដឹកនាំការងារប្រចាំថ្ងៃរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់របស់ខ្លួន។
- ដឹកនាំការងារបណ្តុះបណ្តាលសំរាប់សកម្មភាពត្រៀមបង្ការនិងត្រៀមរៀបចំ ឆ្លើយតបគ្រោះអាសន្ន និង ការស្តារការស្ថាបនាឡើងវិញដោយបញ្ជ្រៀបការគ្រប់គ្រងគ្រោះភ័យនៃគ្រោះមហន្តរាយទៅក្នុងការអភិវឌ្ឍន៍សហគមន៍ មូលដ្ឋាន។

## ២. អនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ-សង្កាត់

**អាណត្តិអនុប្រធាន** : ជំទប់ទី១ ចៅសង្កាត់រងទី១ ជាអនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ឃុំ-សង្កាត់ មិនអាចយកអ្នកផ្សេងធ្វើជាអនុប្រធាន ហើយមិនអាចបញ្ឈប់ពីមុខតំណែងអនុប្រធានមុនអាណត្តិរបស់ខ្លួនជាជំទប់ទី១ និងចៅសង្កាត់រងទី១នោះដែរ ។

**តួនាទីរបស់អនុប្រធាន** : ជួយការងារប្រធាន និង ជំនួសប្រធាននៅពេលប្រធានអវត្តមាន ។

## ៣. លេខាធិការដ្ឋាន :

ត្រូវបានបង្កើតឡើងដើម្បីជាសេនាធិការឱ្យប្រធាន និងអនុប្រធានគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំក្នុងការបូកសរុបសភាពការណ៍បង្កបង្កើនផល គ្រោះមហន្តរាយ និងសកម្មភាពរបស់ក្រុមទាំង៣ដើម្បីរាយការណ៍ជូនថ្នាក់បន្តបន្ទាប់ដែលទទួលការងារគ្រប់គ្រងគ្រោះមហន្តរាយ ហើយមានតួនាទីទទួលខុសត្រូវលើការងារ :

-ទទួល និង ផ្តល់ពតិមានបន្ទាន់ពីមុខសញ្ញាគ្រោះថ្នាក់ និងគ្រោះអាសន្នផ្សេងៗដោយមនុស្ស និងធម្មជាតិ
-ទទួលរបាយការណ៍ និង គ្រប់គ្រងទុកដាក់ឯកសារ
-បូកសរុបសភាពការណ៍ និង តាមដានត្រួតពិនិត្យវាយតំលៃ
-ធ្វើកំណត់ហេតុប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំ ។

## ៤. ក្រុមសន្តិសុខ និងរុករកសង្គ្រោះ

ត្រូវបានបង្កើតឡើងដើម្បីរៀបចំ ត្រៀមបង្ការមុខសញ្ញាគ្រោះថ្នាក់ដែលបង្កឡើងដោយមនុស្ស និងធម្មជាតិ ធ្វើប្រតិបត្តិការនៅពេលមានគ្រោះអាសន្ន រំដោះប្រជាជនចេញពីគ្រោះថ្នាក់ ជម្លៀសប្រជាជន ការពារសន្តិសុខសុវត្ថិភាព ពន្លត់អគ្គីភ័យ រុករក និងសង្គ្រោះអ្នករងគ្រោះ ព្រមទាំងមានតួនាទីទទួលខុសត្រូវដូចខាងក្រោម :

-កសាងផែនការរៀបចំកំលាំង មធ្យោបាយ សំភារៈសំរាប់បំរើការរុករកនិងសង្គ្រោះ និងសន្តិសុខសណ្តាប់ធ្នាប់ ។
-អប់រំ ផ្សព្វផ្សាយ និង ពន្យល់ដល់ប្រជាពលរដ្ឋក្នុងឃុំអំពីវិធានការត្រៀមបង្ការ កាត់បន្ថយគ្រោះថ្នាក់ ត្រៀមរៀបចំសំរាប់កាត់បន្ថយគ្រោះអាសន្ន និងគ្រោះភ័យផ្សេងៗ ព្រមទាំងខ្លឹមសារ និងសញ្ញាប្រកាសអាសន្ន និងសកម្មភាព ត្រូវអនុវត្ត ។
-កំណត់ការផ្តល់សញ្ញាពីលំនៅដ្ឋានមួយទៅលំនៅដ្ឋានមួយដើម្បីងាយស្រួលពេលមានគ្រោះអាសន្នកើតឡើង ។
-ថែរក្សាទុកដាក់ឱ្យបានល្អនូវឧបករណ៍ មធ្យោបាយប្រកាសអាសន្ន ( មេក្រូ ជួង ត្រដោក ស្គ ចង្កៀង) ធានាថាប្រើប្រាស់បាន ។
-រៀបចំផែនទីមុខសញ្ញាគ្រោះថ្នាក់ ទីសុវត្ថិភាព និងគំនូសបង្ហាញផ្លូវពីកន្លែងមានប្រជាពលរដ្ឋរស់នៅ ទៅកាន់កន្លែងជម្លៀស ហើយនឹងមានបញ្ជីប្រជាជនដែលអាចត្រូវជម្លៀស ។
-កន្លែងដែលកំណត់ទុកសំរាប់ជម្លៀសគឺធានាអាចប្រើប្រាស់បាន មានសុវត្ថិភាព និង ធ្វើផែនការជម្លៀសបង្កើតវិធីសាស្ត្រក្នុងការជម្លៀសឱ្យមានប្រសិទ្ធភាពតាមផែនការ ។
-ការពារសន្តិសុខ កន្លែងស្នាក់នៅបណ្តោះអាសន្នរបស់ជនរងគ្រោះ និង ការពារមិនឱ្យមានការបន្លំចូលលួច ប្លន់ ព្រមទាំងថែរក្សា ការពារទ្រព្យសម្បត្តិផ្ទះសម្បែងប្រជាពលរដ្ឋបានចោលបណ្តោះអាសន្នទៅទីសុវត្ថិភាព ។

-ត្រួតពិនិត្យការចេញចូលនៅតំបន់កើតហេតុ និងទីសុវត្ថិភាព។
-ដាក់ផ្លាកសញ្ញាតំបន់គ្រោះថ្នាក់ និងសញ្ញាសំគាល់ និងសញ្ញាហាមឃាត់ផ្សេងៗ។
-ផ្តល់កំលាំងការពារក្បួនដឹកជញ្ជូនសំភារៈ បរិក្ខារ និងប្រតិភូដែលចូលមកបំពេញការងារនៅតំបន់រងគ្រោះ។
-រៀបចំកំលាំងប្រតិបត្តិការដំណាក់កាលដំបូងសំរាប់ពន្លត់អគ្គិភ័យ។
-ផ្សព្វផ្សាយវិធានការផ្សេងៗដែលជាលក្ខណៈត្រៀមបង្ការនូវឃថាហេតុនៃមុខសញ្ញាគ្រោះថ្នាក់ដោយមនុស្ស តាមមធ្យោបាយដែលអាចធ្វើបាន។
-ដឹកនាំបុគ្គលិកសង្គ្រោះ និង សំរបសំរួល ធ្វើការបណ្តុះបណ្តាលជំនាញផ្នែកសង្គ្រោះបឋម និងជួយសង្គ្រោះ។

## ៥. ក្រុមសុខភាព និងអនាម័យ

ត្រូវបានបង្កើតឡើងដើម្បីធ្វើប្រតិបត្តិការការពារអាយុជីវិតប្រជាជន តាមរយៈ ការគាំពារសុខភាព ស្រាវជ្រាវរកប្រភពនៃជំងឺ និង ការពារជំងឺឆ្លងទាំងមនុស្ស សត្វ ជំងឺរាតត្បាត ជម្លៀសអ្នកជំងឺនៅតាមកន្លែងមន្ទីរពេទ្យសង្គ្រោះបន្ទាន់ ហើយមានតួនាទីទទួលខុសត្រូវដូចខាងក្រោម :

-អប់រំ ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងពីការថែរក្សាសុខភាព ការទទួលទានចំណីអាហារ ការត្រៀមបង្ការមុខសញ្ញាគ្រោះថ្នាក់ដែលបង្កដោយមនុស្ស និងធម្មជាតិ
-បណ្តុះបណ្តាលជំនាញផ្នែកសង្គ្រោះបឋម ថែទាំសុខភាព អនាម័យដល់សហគមន៍
-អប់រំផ្សព្វផ្សាយការយល់ដឹងជាសាធារណៈដល់ប្រជាពលរដ្ឋក្នុងឃុំអំពីរោគសញ្ញាផ្សេងៗនៃជំងឺសត្វ ការការពារ ការព្យាបាលជំងឺសត្វ ការសំអាតអនាម័យទ្រុងសត្វ និងអនាម័យខ្លួនប្រាណមនុស្ស ការបរិភោគចំអិន សាច់សត្វ
-រិះរកវិធីសាស្រ្តសំរាប់ណែនាំដល់ប្រជាពលរដ្ឋឱ្យចេះជួយខ្លួនឯង និងប្រើប្រាស់អ្វីដែលមានក្នុងមូលដ្ឋាន ដើម្បីឆ្លើយតបពេលមានជួបគ្រោះអាសន្នកើតឡើង
-ត្រួតពិនិត្យ និង ក្តាប់ជាប់ជាប្រចាំនូវស្ថិតិសត្វចិញ្ចឹមនៅក្នុងឃុំ
-ចាក់ថ្នាំបង្ការជំងឺសត្វ
-ត្រួតពិនិត្យមិនឱ្យមានការទិញលក់សត្វឈឺ និងសត្វស្លាប់ដោយជំងឺ និងការដឹកជញ្ជូនសត្វនៅក្នុងរង្វង់ឃុំ។
-ពង្រឹងបទបញ្ជាអនាម័យ អនុវត្តផែនការត្រួតពិនិត្យតំបន់កខ្វក់ ការចាក់សំរាម
-ត្រួតពិនិត្យស្ថានភាពអនាម័យរបស់សហគមន៍ អណ្តូងទឹក ស្រះទឹក និងការប្រើប្រាស់ទឹក
-កំណត់ទីកន្លែង អាគារដែលអាចប្រើប្រាស់ជាមូលដ្ឋានធ្វើស្នាក់ការពេទ្យពេលមានគ្រោះអាសន្នកើតឡើង និង គ្រប់គ្រងព្យាបាលដល់អ្នកជំងឺស្រាល

## ៦. ក្រុមឆ្លើយតប និង ព័ត៌មាន :

ត្រូវបានបង្កើតឡើងដើម្បីធ្វើប្រតិបត្តិការផ្តល់ព័ត៌មានអំពីមុខសញ្ញាគ្រោះថ្នាក់ដោយធម្មជាតិ និងដោយមនុស្សដែលកើតឡើងនៅមូលដ្ឋានឃុំ-សង្កាត់ ទាក់ទង និងតម្រូវការរបស់ប្រជាពលរដ្ឋដែលរងគ្រោះ និង ធ្វើការចែក

ផ្សាយព័ត៌មាន បង្ហាញហេតុផល ព្រមទាំងធ្វើការអំពាវនាវរកជំនួយ ផ្ដល់ជំនួយដល់ក្រុមរងគ្រោះ អនុវត្តគំរោងពលកម្ម ហើយមានតួនាទីទទួលខុសត្រូវដូចខាងក្រោម :

-សហការជាមួយអង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល កសាងគំរោងត្រៀមបង្ការគ្រោះមហន្តរាយតាម បែបរចនាសម្ព័ន្ធ និងមិនមែនរចនាសម្ព័ន្ធ

-រៀបចំទីសុវត្ថិភាពឱ្យមានលក្ខណៈសមស្របអាចស្នាក់នៅបាន

-ស្រង់ចំនួនប្រជាជនរងគ្រោះដែលជម្លៀសទៅរស់នៅតាមទីសុវត្ថិភាព

-ផ្ដល់ការស្នាក់នៅដល់ប្រជាជនរងគ្រោះ រៀបចំជំរកបណ្ដោះអាសន្ន ឬនៅតាមគេហដ្ឋានដែលម្ចាស់គេអនុញ្ញាត

-គ្រប់គ្រងសំភារៈជំនួយសង្គ្រោះដូចជាអង្ករ ស្បៀងអាហារ...

-របាយការណ៍ពីស្ថានភាពជនរងគ្រោះ និងសកម្មភាពផ្ដល់ជំនួយ វាយតំលៃការខូចខាត និងសេចក្ដីត្រូវការ ។

-តាមដានត្រួតពិនិត្យសុខុមាលភាពរបស់ប្រជាជនរស់នៅក្នុងទីសុវត្ថិភាព ។

-ចែកចាយអំណោយសំភារៈសង្គ្រោះបន្ទាន់ ។

-ដាស់សតិអារម្មណ៍ និងបំផុសស្មារតីលើកទឹកចិត្ត ។

-ស្វែងរកបញ្ហាផ្សេងៗ និង ព្យាយាមដោះស្រាយបញ្ហា ។

-រៀបចំផ្ដល់ឱកាសរកការងារដល់ជនរងគ្រោះ ដូចជា: កម្មវិធីស្បៀងពលកម្ម និងប្រាក់ពលកម្ម ផ្ដល់មីក្រូ ឥណទាន ជាដើម ។

ខាងក្រោមនេះ គឺជារចនាសម្ពន្ធ័ របស់គណៈកម្មាធិការគ្រ ប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំ (CCDM):

## ង_រចនាសម្ព័ន្ធរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ឃុំ



# ផ្នែកទី ២

## ការយល់ដឹងពីមូលដ្ឋានគ្រឹះពីគ្រោះមហន្តរាយ

# ការយល់ដឹងពីមូលដ្ឋានគ្រឹះពីគ្រោះមហន្តរាយ

## I. មុខសញ្ញាបង្កគ្រោះមហន្តរាយ

### ១. និយមន័យ

មុខសញ្ញាបង្កគ្រោះមហន្តរាយ គឺជាព្រឹត្តិការណ៍ ទាំងឡាយដែលកើតឡើង ហើយអាចនឹងបង្កនូវការគំរាមកំហែងដល់អាយុជីវិតរបស់មនុស្ស សត្វ ទ្រព្យសម្បត្តិ និង ជីវភាពរស់នៅ នៅកន្លែងដែលកើតហេតុ ។

មុខសញ្ញាបង្កគ្រោះថ្នាក់ខ្លះ កើតឡើងដោយសារ ធម្មជាតិ ដូចជា ខ្យល់ព្យុះ ការរញ្ជួយដី និង បន្ទុះភ្នំភ្លើងជាដើម និង មុខសញ្ញាបង្កគ្រោះថ្នាក់ខ្លះទៀតបង្កដោយ មនុស្ស ដូចជា ការកើនឡើងជាតិ ពុលក្នុងបរិស្ថាន ការកាប់បំផ្លាញព្រៃឈើ សង្គ្រាមស៊ីវិល ការផលិតជាតិ គីមីជាដើម ។

មុខសញ្ញាបង្កគ្រោះថ្នាក់សំខាន់ ៧ ដែលប្រទេសកម្ពុជា កំពុងជួបប្រទះ មានដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ជំងឺរាតត្បាតតាមរដូវកាល និង ខ្យល់ព្យុះ។

### ២. ប្រភេទមុខសញ្ញាបង្កគ្រោះមហន្តរាយ

#### ២.១ ទឹកជំនន់

តំបន់វាលទំនាបនៃទន្លេមេគង្គ ទន្លេសាប និង ដៃរបស់វា ជាតំបន់ដែលងាយរងគ្រោះ និង ប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយទឹកជំនន់ប្រចាំឆ្នាំ ។ ទឹកជំនន់បាននាំមកនូវផលពីរយ៉ាង គឺផលវិជ្ជមាន និង ផលអវិជ្ជមាន។ ផលវិជ្ជមាននៃទឹកជំនន់មានដូចជា ផ្តល់នូវធនធានធម្មជាតិដ៏សំបូរបែបសំរាប់ ប្រជាជនប្រកបរបរចិញ្ចឹមជីវិត និងការរស់នៅ ឧទាហរណ៍ ធ្វើអោយដីមានសំណើម និង មានជីជាតិគ្រប់ គ្រាន់សំរាប់ការដាំដំណាំកសិកម្មលូតលាស់ និង ផ្តល់នូវផលយ៉ាងច្រើន , ផ្តល់នូវធនធានមច្ឆាជាតិ និង ប្រព័ន្ធអេកូឡូហ្ស៊ីសំរាប់ការរស់នៅរបស់ពពួកសត្វជីវចំរុះ។ ទន្ទឹមនឹងផលវិជ្ជាមាន ទឹកជំនន់ ក៏តែងតែបង្កនូវផល ផលប៉ះពាល់អវិជ្ជមានជាប្រចាំដល់ មនុស្ស សត្វ ហេដ្ឋារចនាសម្ព័ន្ធ ដំណាំកសិកម្ម និង ជាឧបសគ្គរារាំង ដំណើរការអភិវឌ្ឍន៍នានា ជាពិសេស ការអភិវឌ្ឍន៍សហគមន៍ដែលប្រឈមមុខ នៅតាមដងទន្លេមេគង្គ ទន្លេសាប និង ដៃរបស់វា។

➢ **ប្រភេទទឹកជំនន់**

**ក. ទឹកជំនន់នៅតាមដងទន្លេ**

ទឹកជំនន់នៅតាមដងទន្លេ គឺជាបាតុភូតធម្មជាតិដែលកើតតាមរដូវ ជាពិសេសនៅក្នុងរដូវវស្សា ដែលខ្យល់មូសុងបាននាំមកនូវទឹកភ្លៀងយ៉ាងច្រើនហូរចាក់ចូលទៅក្នុងអាងទន្លេ បឹង ព្រែក និង អាងស្តុកទឹកនានា ហើយធ្វើអោយផ្ទៃនៃអាងស្តុកទឹកទាំងអស់នេះពេញ និង ហៀរលិចតំបន់ទំនាប ដែលមានទីតាំងនៅជុំវិញទន្លេ និងដៃរបស់វា។ ទឹកជំនន់ទន្លេ គេចាត់ជាទឹកជំនន់ដែលមានល្បឿនយឺត ដោយសារវាកើតឡើងយឺតៗ អាស្រ័យទៅតាមបរិមាណទឹកភ្លៀង។ ទឹកជំនន់ប្រភេទនេះ មានរយៈពេលយូរ ឬ ឆាប់ វាអាស្រ័យស្ថានភាពដី និង ស្ថានភាពភូមិសាស្ត្រ ។ តំបន់ខ្លះមានរយៈពេល មួយសប្តាហ៍ ឬច្រើនជាងនេះ និង តំបន់ខ្លះមានរយៈពេលដល់រាប់ខែក៏មាន។ តំបន់ដែលប្រឈមមុខ និង ទទួលរងការប៉ះពាល់ទឹកជំនន់ប្រភេទនេះ វាអាចធ្វើអោយបាត់បង់ និង ខូចខាតដំណាំកសិផល ហេដ្ឋារចនាសម្ពន្ធ័ សេវាកម្ម ដូចជាផ្លូវថ្នល់ តំណផ្លូវដែក និងការផ្គត់ផ្គង់អគ្គីសនី ។ល។



**ខ. ទឹកជំនន់ឡើងរហ័ស**

ទឹកជំនន់ឡើងរហ័សបណ្តាលមកពីមានភ្លៀងធ្លាក់ដោយគំហុកនៅតំបន់ខាងលើ ជាពិសេស មានភ្លៀងយ៉ាងច្រើនជាប់ៗគ្នាជាច្រើនថ្ងៃនៅតាមជួរភ្នំខ្ពស់ៗ បណ្តាលអោយមានទឹកហូរយ៉ាងគំហុកចុះតាមជ្រោះ និង ជ្រលងភ្នំចុះមកតំបន់វាលរាប ធ្វើអោយមានទឹកហូរហៀរពាសពេញតំបន់វាលរាប ។ ដោយសារតែមានទឹកហូរកំហុកក្នុងរយៈពេលខ្លី ជាហេតុធ្វើអោយយើងពិបាកក្នុងការធ្វើការទស្សន៍ទាយ ឬ ធ្វើការព្យាករណ៍ទុកជាមុនបាន។ កំលាំងទឹកហូរអាចធ្វើអោយប៉ើងរថយន្ត ផ្ទាំងថ្ម គាស់រំលើងឫសឈើ បំផ្លាញអាគារ ជាពិសេស វាអាចបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ (ស្ពាន ផ្លូវថ្នល់ ទំនប់ .....) បានយ៉ាងងាយបំផុត។

**២.២. គ្រោះរាំងស្ងួត**

## ពន្ធុវិទ្យាវិទ្យា



ប្រទេសកម្ពុជា ជាប្រទេសមួយស្ថិតនៅក្នុងតំបន់ត្រូពិចដែលមានរដូវពីរ គឺៈ រដូវវស្សា ជារដូវខ្យល់មូសុង ចាប់ពីខែឧសភា ដល់ ចុងខែតុលា ហើយរដូវប្រាំងចាប់ពីខែវិច្ឆិកា ដល់ ខែមេសា ។ ផ្ទៃដីប្រទេសកម្ពុជា ជាវាល ទំនាបស្ទើរតែទាំងអស់ លើកលែងតែនៅទិសនិរតីដែលមានភ្នំ និង នៅទិសឧត្តរគឺជា "ផ្ទៃដីសំរាប់ដាំដំណាំស្រូវ និង ដាំដើមឈើ ហើយដែលគ្របដណ្តប់ដោយទឹកទន្លេមេគង្គ និង ទន្លេសាប" ។

នៅក្នុងប្រទេសកម្ពុជា ប្រភេទគ្រោះរាំងស្ងួតសំខាន់ដែលមានការព្រួយបារម្ភជាងគេចំពោះថ្នាក់ជាតិនោះ គឺភាពរាំងស្ងួតនៅលើដីនៃកសិកម្ម ដែលជាទីកន្លែងខ្វះសំណើមដីគ្រប់គ្រាន់សំរាប់ដំណាំលូតលាស់ ដែលបណ្តាល មកពីមានភ្លៀងធ្លាក់តិចនៅពេលរដូវភ្លៀង និងរបាយទឹកភ្លៀងមិនទៀងទាត់នៅពេលរដូវដាំដំណាំ ។ នៅតាម តំបន់ជនបទ ភ្លៀងធ្លាក់ ប្រចាំឆ្នាំ គឺជាកត្តាកំនត់មួយនៃផលិតភាពខាងដំណាំស្រូវ និង សន្តិសុខស្បៀង។

ប្រភពធនធាននៃទឹកភ្លៀងនៅក្នុងប្រទេសកម្ពុជា គឺជាខ្យល់មូសុងដែលបក់មកពីទិសនិរតី ។ ផ្ទៃដីកសិកម្ម ភាគច្រើនលាតសន្ធឹងនៅក្នុងតំបន់ដែលទទួលរងឥទ្ធិពលភ្លៀងនៃខ្យល់មូសុងនេះ ដែលនៅតាមជួរភ្នំក្រវាញ និង ភ្នំដំរី នៅទិសនិរតីនៃប្រទេស ។ ក្រៅពីជួរភ្នំទាំងនេះ ទឹកភ្លៀងធ្លាក់ជាមធ្យម គឺ ៤.០០០ មីលីម៉ែត្រក្នុងមួយឆ្នាំ ។ បន្ទាប់ពីភ្លៀងខ្យល់មូសុងនេះឆ្លងកាត់ភ្នំទាំងនេះរួចមក ភ្លៀងធ្លាក់ជាមធ្យមប្រចាំឆ្នាំក្នុងកំរិតពី១.២៥០ ទៅ ១.៧៥០ ម.ម លើ តំបន់កសិកម្មសំខាន់ទាំងនោះ ។ ប៉ុន្តែភ្លៀងធ្លាក់ប្រចាំឆ្នាំបានថយចុះនៅ ៥០% នៅពេលដែល មានគ្រោះរាំងស្ងួត និង កើនឡើងបាន ៤០% នៅពេលមានទឹកជំនន់ខ្លាំង ។ តំបន់ដែលក្តៅបំផុតនៅក្នុងប្រទេស កម្ពុជា គឺនៅទិសអាគ្នេយ៍ និង ទិសពាយ័ព្យ ដែលទទួលទឹកភ្លៀងធ្លាក់ជាមធ្យមតិចជាង ៤៧០មម នារដូវវស្សា ។

ដោយតំបន់កសិកម្មដំណាំស្រូវប្រហែលជា ៨០% ត្រូវពឹងផ្អែកទាំងស្រុងទៅលើទឹកភ្លៀង ទើបប្រហែល ជាកត្តាទឹកភ្លៀងដែលធ្លាក់មិនទៀតទាត់អាចបណ្តាលអោយមានគ្រោះរាំងស្ងួតនៃការធ្វើកសិកម្មនេះនៅពេលដាំដុះក្នុងរដូវ ភ្លៀង។ គ្រោះរាំងស្ងួតខាងកសិកម្មនៅក្នុងប្រទេសកម្ពុជា មិនមែនជាបញ្ហាមួយពេលរដូវប្រាំងនោះទេ ព្រោះថាទឹកភ្លៀងធ្លាក់ជាមធ្យមនៅរដូវប្រាំងគឺមានតិចបំផុតទៅហើយ ហើយដំណាំដែលពឹងលើទឹកភ្លៀងនោះ វាលូតលាស់ជាធម្មតា ។ ដូចនេះ វាជាការធម្មតាទៅហើយ ដែលដំណាំដាំដដែល។ តែងតែជួបប្រទះនឹងទឹកជំនន់ ផង និង ភាពរាំងស្ងួតផង អំឡុងពេលនៃការលូតលាស់របស់វា ។

នៅក្នុងឆ្នាំ ២០០៤-២០០៥ នៅពេលដែលរដូវភ្លៀងផុតមុនរដូវ គ្រានោះបានបង្ករឱ្យមានបញ្ហាយ៉ាង ធំដល់ការដាំដុះដំណាំស្រូវ ដែលធ្វើអោយប្រទេសកម្ពុជាមានមនុស្សរដល់ទៅ ២ លាននាក់បានរងការគំរាមកំហែង ដោយខ្វះស្បៀងអាហារ ។ មិនត្រឹមតែរដូវភ្លៀងនាឆ្នាំ ២០០៤ បានឈប់ភ្លៀងមុនរដូវប៉ុណ្ណោះទេ ក៏ប៉ុន្តែរដូវភ្លៀង

នៅឆ្នាំ២០០៥ ថៃមទាំង មិនឃើញមានធ្លាក់មកផងដែរនៅក្នុងខែឧសភា ដូចដែលបានគិត ដែលបានពន្យាពេលដក់ការដាំដុះដំណាំស្រូវ ដែលប្រជាជនចំនួន ៨៥% ពឹងពឹងអាស្រ័យលើ ។ ដីស្រែចំការនៅក្នុងប្រទេសរហូត ដល់ទៅ ៣០% មានការប៉ះពាល់ ដែលរួម មានផ្ទៃដីចំនួន ៥០០.០០០ ហិចតានៃដីដាំស្រូវ (ស្មើប្រហែលនឹង ២៥% នៃផ្ទៃដីដាំដំណាំសរុប)ដែលត្រូវការជំនួយ ស្បៀងអាហារពីអន្តរជាតិចំពោះតំរូវការបែបនេះ ។

➢ **ប្រភេទផ្សេងៗនៃគ្រោះរាំងស្ងួត**

### ក. គ្រោះរាំងស្ងួតខាងឧត្តុនិយម

តែងតែទាក់ទងនឹងការថយចុះខ្លាំងនៃទឹកភ្លៀងជាធម្មតានៅក្នុងតំបន់មួយ និង កំរិតអង្សាជាមូលដ្ឋានឡើងខ្ពស់(បើប្រៀបធៀបនឹងកំរិតអង្សាកំដៅជាមធ្យម) និង រយៈពេលនៃការឡើងកំដៅ ។ អត្ថន័យនៃគ្រោះរាំងស្ងួតខាងឧត្តុនិយម គឺជាការកំនត់ទៅតាមតំបន់ ។ នៅក្នុងប្រទេសឥណ្ឌា គ្រោះរាំងស្ងួតខាងឧត្តុនិយម ជាការកើតឡើងនៅពេលដែលតំបន់មួយបានទទួលទឹកភ្លៀងតាមរដូវតិចជាង៧៥%នៃកំរិតជាមធ្យមក្នុងរយៈពេលយូរ ។ ចំនែកឯនៅក្នុងប្រទេសហ្វីលីពីនវិញ តំបន់មួយដឹងថា កំពុងទទួលរងគ្រោះរាំងស្ងួតនោះ គឺនៅពេលដែលទឹកភ្លៀង មានកំរិតស្មើនឹង ៤០% ក្រោមកំរិតមធ្យមនៃរយៈពេល ៣ ខែជាប់គ្នា បើប្រៀបធៀបទៅនឹងស្ថិតិទឹកភ្លៀង ប្រចាំខែកន្លងទៅ នៅក្នុងតំបន់នោះ ។

### ខ. គ្រោះរាំងស្ងួតខាងជលសាស្ត្រ

សំដៅលើការវិវត្តហួតដែលគួរអោយកត់សំគាល់ទៅលើផ្ទៃទឹក (ទន្លេ បឹង ស្ទឹង និង អាងស្តុកទឹក ) និង សំដៅលើការមិនមានទីរ៉ូទឹកនៅក្រោមផ្ទៃដី ។ ភាពកើតមានជារឿយៗ និង ភាគច្រើននៃគ្រោះរាំងស្ងួត ខាងជលសាស្ត្រ គឺតែងតែកំនត់លើទីជំរាល ឬ កំរិតដែនផ្ទៃទឹកទន្លេ ។ ប្រសិនបើ ទឹកហូរជាក់លាក់នៃកំឡុងពេលណាមួយដែលយើងបានកំនត់នោះមានការធ្លាក់ចុះនៅក្រោមកំរិតអប្បបរមាមួយនោះគ្រោះរាំងស្ងួតខាងជលសាស្ត្រ ពិតជាកំពុង កើតមានឡើងហើយ ។

### គ. គ្រោះរាំងស្ងួតខាងកសិកម្ម

កើតមានឡើងនៅពេលដែលគ្មានសំនើមដីគ្រប់គ្រាន់ និង មានទឹកភ្លៀងមិន គ្រប់គ្រាន់សំរាប់ដាំដំណាំ ។ វាជាឥទ្ធិពលមកពីគ្រោះរាំងស្ងួតខាងឧត្តុនិយម និង ជលសាស្ត្រ ទៅលើដំណាំដែលមិនមានសំណើមគ្រប់គ្រាន់

ក្នុងការថែទាំទិន្នផល និង ការលូតលាស់ជាមធ្យមនៃដំណាំ ។ ឥទ្ធិពលនៃគ្រោះរាំងស្ងួតខាងកសិកម្ម មានភាពពិបាកក្នុងការវាស់វែង ដោយសារតែភាពសាំញ៉ាំនៃការលូតលាស់របស់ដំណាំ និង ការកើតមាននៃកត្តានានា ដូចជាដំណាំមានសត្វល្អិតចង្រៃ សំបូររុក្ខជាតិគ្មានប្រយោជន៍ គុណភាពដីអន់ថយ និង ដំណាំមានតំលៃចុះថោក ។



## ២.៣. ជំងឺរាតត្បាត

ប្រទេសកម្ពុជា ធ្លាប់មានការរាតត្បាតដោយជំងឺផ្សេង ៗ ដូចជា ជំងឺអាសន្នរោគ, ជំងឺគ្រុនចាញ់, គ្រុនឈាម ,ជំងឺសើស្បែក (កមរមាស់) និង ពេលបច្ចុប្បន្ននេះ ប្រឈមមុខនឹងមេរោគជំងឺផ្តាសាយបក្សី (H5N1) ។ តាមរបាយការណ៏បានអោយដឹងថា ប្រទេសកម្ពុជាធ្លាប់ទទួលការប៉ះពាល់ដោយជំងឺគ្រុនចាញ់យ៉ាងធ្ងន់ធ្ងរនៅក្នុងតំបន់ អាស៊ី ។ ដោយសារតែមានការខ្វះខាតសេវាកម្មព្យាបាលសុខាភិបាលនៅតាមតំបន់ជនបទ ធ្វើអោយការព្យាបាលជំងឺរាតត្បាតនេះមិនអាចបំរើបានគ្រប់គ្រាន់ដល់ប្រជាជនដែលទទួលរងការប៉ះពាល់ ។

ទាក់ទងនឹងមេរោគជំងឺផ្តាសាយបក្សី (H5N1) វិញ បានកើតឡើងនៅពេលបច្ចុប្បន្ននេះ បានគំរាមកំហែងដល់ប្រជាជននៅតាមជនបទដាច់ស្រយាលនៅភាគខាងត្បូងនៃប្រទេសកម្ពុជា ។ ចាប់ពីឆ្នាំ ២០០៤ មក ប្រទេសកម្ពុជាទទួលរងការប៉ះពាល់ដោយមេរោគជំងឺផ្តាសាយបក្សី (H5N1) តាមតួលេខ ឆ្នាំ ២០០៥ និង ២០០៦ មានមនុស្សស្លាប់ដោយមេរោគនេះចំនួន ៦ នាក់ហើយ ឆ្លងពីសត្វមកមនុស្ស។ ការរាតត្បាតនេះ នៅតែបន្តជាពិសេស នៅតាមតំបន់មួយចំនួននៅតាមព្រំដែនប្រទេសវៀតណាម និង ថៃឡង់ដ៏ ។

## ២.៤ ខ្យល់ព្យុះ

ខ្យល់ព្យុះ និង ខ្យល់មួសុង ជាមុខសញ្ញាបង្កគ្រោះមហន្តរាយមួយដែរ តែមិនត្រូវបានចាត់ថា ជាមុខសញ្ញាបង្កគ្រោះមហន្តរាយធ្ងន់ធ្ងរទេ ពីព្រោះទីតាំងប្រទេសនេះមានលក្ខណៈអំណោយផលល្អ ដោយមានជួរភ្នំព័ទ្ធជុំវិញ ជារនាំងបាំងខ្យល់ពីប្រទេសនានានៅក្នុងតំបន់ ។ ទោះបីយ៉ាងណាក៏ដោយមានតំបន់ខ្លះទទួលរងការប៉ះពាល់ដោយសារខ្យល់ព្យុះ

នៅក្នុងរដូវវស្សានៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង ។ នៅឆ្នាំ ១៩៩៧ តំបន់មួយចំនួននៅតាមតំបន់មាត់សមុទ្រទទួលរងការប៉ះពាល់ដោយខ្យល់ព្យុះមួយឈ្មោះថា លីនដា ខ្យល់ព្យុះនេះបានបោកបក់ប៉ះចំកោះប៉ូឡូវៃ្វធ្វើអោយមាន ការប៉ះពាល់ដល់ទូកនេសាទចំនួន ៨១គ្រឿង និងប៉ះពាល់ដល់មនុស្សជាច្រើនគ្រួសារ ។ នៅឆ្នាំ ១៩៩៩ មានព្យុះពីរបានប៉ះតំបន់មួយចំនួននៅទីក្រុងភ្នំពេញ និង ខេត្តកណ្តាល ធ្វើអោយប៉ះពាល់ដល់ផ្ទះចំនួន ៥០០ខ្នង ។ នៅឆ្នាំ ២០០១ ខេត្ត និងក្រុងមួយចំនួនទទួលរងការប៉ះពាល់ ធ្វើអោយផ្ទះចំនួន ៧៤៣ ខ្នងទទួលរកងការខូចខាត។



## ២.៥ ភ្លើងឆេះព្រៃ និង អគ្គីភ័យ

ភ្លើងឆេះព្រៃតែងតែកើតមានឡើងនៅតំបន់ភ្នំ នៅក្នុងរដូវប្រាំងចាប់ពីខែមិនា រហូតដល់ ឧសភា ជារៀងរាល់ឆ្នាំ។ រដូវនេះ ជារដូវក្តៅបណ្តាលអោយស្លឹកឈើជ្រុះ និង រុក្ខជាតិតូចៗងាប់ ដែលជាហេតុធ្វើអោយងាយនឹងទទួលរងការឆេះ។ នៅពេលបច្ចុប្បន្នដោយសារតែមានអាកាសធាតុប្រែប្រួល និង ដោយសារការគ្រប់គ្រង និង ការប្រើប្រាស់ដីមិនបានល្អ វានឹងអាចធ្វើអោយភ្លើងឆេះព្រៃនៅកម្ពុជា កាន់តែមានភាពធ្ងន់ធ្ងរ និង អាចមានការគំរាមកំហែងដល់ព្រៃឈើ ធនធានធម្មជាតិ និង សត្វព្រៃផ្សេង ៗ។

បញ្ហាអគ្គិភ័យជាបញ្ហាធ្ងន់ធ្ងរដែលតែងតែកើតឡើងនៅតាមតំបន់ទីប្រជុំជននិងតាមតំបន់ជាយក្រុងធំៗ។ ការកើតឡើងនៃអគ្គីភ័យតែងតែមានការរាលដាលធ្ងន់ធ្ងរ ដោយសារតែតំបន់ទីប្រជុំជន និង តំបន់ជាយក្រុងដែលប្រឈមនឹងមុខសញ្ញានេះ មានការខ្វះខាតសំភារៈ និង ឧបករណ៍ពន្លត់ភ្លើង និង ខ្វះខាតធនធានមនុស្សដែលមាន ចំណេះ និង សមត្ថភាពគ្រប់គ្រាន់ក្នុងការប្រតិបត្តិការ។ តាមរបាយការណ៏របស់គណៈកម្មាធិការជាតិគ្រប់គ្រង គ្រោះមហន្តរាយបានអោយដឹងថា នៅឆ្នាំ ២០០១ មានករណីអគ្គីភ័យចំនួន ៤៦លើក ធ្វើអោយឆេះផ្ទះចំនួន ៣. ៣១៦ខ្នង និងធ្វើអោយបាត់បង់អាយុជីវិតមនុស្សចំនួន ៥ នាក់ និង រករបួសចំនួន ២០ នាក់ ។



## II. ភាពងាយរងគ្រោះ

### ១. និយមន័យ

ភាពងាយរងគ្រោះ គឺជាវិសាលភាព (ទំហំ) ឬ ជាលក្ខណៈរបស់បុគ្គល សហគមន៍ ហេដ្ឋារចនាសម្ព័ន្ធ សេវាកម្ម រឺ លក្ខណៈភូមិសាស្ត្រណាមួយដែលវាអាចនឹង ទទួលការរងគ្រោះ ឬត្រូវខូចខាត រឺ អាក់ខានដោយសារ ឥទ្ធិពលនៃមុខសញ្ញាបង្កគ្រោះថ្នាក់ ដែលបានកើតឡើង នៅពេលណាមួយ ។

### ២. មូលហេតុនៃភាពងាយរងគ្រោះ

លក្ខខណ្ឌសេដ្ឋកិច្ចសង្គមរបស់ប្រទេសកម្ពុជា នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានភាពល្អប្រសើរ និង មានការរីកចំរើនគួរអោយកត់សំគាល់ ។ ទោះបីយ៉ាងណាក៏ដោយ ក៏ប្រទេសនេះ ជាប្រទេសមួយដែលស្ថិតក្នុង ចំណោម ប្រទេសកំពុងអភិវឌ្ឍន៍តិចតួច បន្ទាប់ពីចេញផុតពីសង្គ្រាមស៊ីវិល និង អស្ថេរភាពនយោបាយដ៏យូរប្រមាណ ៣០ ឆ្នាំ ។ អាត្រាមរណភាព និង កង្វះអាហារបំប៉នរបស់កុមារមានកំរិតខ្ពស់ ជាពិសេស កុមារស្ថិនៅ ក្នុងគ្រួសារប្រជាជនដែល មានកំរិតជីវភាពរស់នៅក្រោមបន្ទាត់ភាពក្រីក្រ ។

ប្រជាជនដែលរស់នៅតំបន់ប្រឈមមុខនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយ ទឹកជំនន់ និង រាំងស្ងួត ពួកគេមាន សមត្ថភាព និង លទ្ធភាពតិចតួចក្នុងការដោះស្រាយ និង ប្រឆាំងតបនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយ ដែលគេកំពុង ប្រឈមមុខ ដោយសារតែភាពក្រីក្ររបស់គេ ដែលជាបុព្វហេតុបង្កនូវភាពងាយរងគ្រោះរបស់គេ ។ ទន្ទឹមនេះគ្រោះ មហន្តរាយក៏ជាបុព្វហេតុធំមួយដែលនៃភាពក្រីក្ររបស់ប្រជាជនដែលរស់នៅតំបន់ប្រឈមមុខនឹង មុខសញ្ញាបង្កគ្រោះ មហន្តរាយ ។

គ្រួសារ និង សហគមន៍ អាចក្លាយជាភាពងាយ រងគ្រោះនៅពេលដែលគេកំពុងប្រឈមមុខសញ្ញាបង្ក គ្រោះថ្នាក់ដែលមាន ហើយអាចនឹងទទួលរងគ្រោះដោយសារ មុខសញ្ញាបង្កគ្រោះថ្នាក់នោះទៀតផង នៅពេល ដែលវា កើតឡើង។ តែស្ថានភាពងាយរងគ្រោះនេះមានលក្ខណៈ ខុសៗគ្នាពីតំបន់មួយទៅតំបន់មួយផ្សេងទៀត ។ **ឧទាហរណ៏** ដូចជា គ្រួសារដែលរស់នៅតាមមាត់ទន្លេងាយ រងគ្រោះចំពោះមុខសញ្ញាបង្កគ្រោះថ្នាក់ទឹកជំនន់ទន្លេ និង មុខសញ្ញាផ្សេងទៀត ដែលកើតមកពីគ្រោះទឹកជំនន់ ។ តែចំពោះគ្រួសារដែលរស់នៅតំបន់ខ្ពង់រាប គឺមិនងាយ រងគ្រោះដោយសារទឹក ជំនន់ទន្លេទេ តែវាអាចងាយ រងគ្រោះដោយសារមុខសញ្ញាបង្កគ្រោះមហន្តរាយណាផ្សេង ដែលតែងតែកើតឡើង នៅតំបន់នោះ ។

គ្រួសារ រឺ សហគមន៍គឺ អាចនឹងមានស្ថានភាពងាយរងគ្រោះផ្សេងៗគ្នាជាច្រើន ។ ចំពោះគ្រួសារដែលរស់នៅតាមតំបន់មាត់ទន្លេ គឺជាឧទាហរណ៍មួយអំពីភាពងាយរងគ្រោះផ្នែក រូបវន្ត (រូបរាង)។ សហគមន៍ នឹងកាន់តែងាយរងគ្រោះ ផ្នែកសង្គមកាន់តែខ្លាំង នៅពេលដែលមិនមានការដឹកនាំ រឺគ្មានការសហការគ្នា រវាងអ្នកមានទីលំនៅក្នុងសហគមន៍ ព្រោះថាគេមិនអាចជួយគ្នាបាននៅពេលមានគ្រោះមហន្តរាយកើតឡើង។ សកម្មភាពប្រកបមុខរបរចិញ្ចឹមជីវិតមួយចំនួនអាចនឹងងាយទទួលរងផលប៉ះពាល់ដោយសារមុខសញ្ញាបង្កគ្រោះថ្នាក់ជាង សកម្មភាពផ្សេងៗ ទៀតនៅក្នុងសហគមន៍ ដែលបណ្តាលឱ្យមានភាពងាយរងគ្រោះ ផ្នែកសេដ្ឋកិច្ចកាន់តែច្រើន។ ម្យ៉ាងវិញទៀតភាពងាយរងគ្រោះផ្នែកអត្តចរិក និង ឥរិយាបថនឹងកើតមានឡើងទៅលើក្រុមមនុស្ស ដែលគេមានជំនឿថាគេមិនអាចដោះស្រាយ រឺធ្វើអ្វីបានទាំងអស់ដើម្បីទប់ទល់នឹងផលប៉ះពាល់ដោយសារមុខសញ្ញាបង្កគ្រោះ ថ្នាក់។

សង្គម សហគមន៍ រចនាសម្ព័ន្ធសហគមន៍ សេវាកម្មទាំងឡាយ រឺ សកម្មភាពផ្សេងៗទៀតដែលងាយរងគ្រោះត្រូវបានគេហៅម្យ៉ាងទៀតថា ***ធាតុដែលប្រឈមមុខ នឹងគ្រោះថ្នាក់នៃមុខសញ្ញាគ្រោះថ្នាក់។*** យើងគួរកត់សំគាល់ផងដែរថា ភាពងាយរងគ្រោះគឺតែងប្រែប្រួល និង ផ្លាស់ប្តូរពីពេលមួយទៅពេលមួយទៀតជានិច្ច។

## III. គ្រោះមហន្តរាយ

### ១. និយមន័យ

យើងអាចកំនត់អត្ថន័យ ពាក្យថា ***គ្រោះមហន្តរាយ*** ជាការធ្វើអោយអាក់ខានដ៏ធ្ងន់ធ្ងរនៃដំណើរការសង្គម ដែលបណ្តាលឱ្យមានការបាត់បង់យ៉ាងច្រើនដល់អាយុជីវិតមនុស្ស សត្វ ខូចខាតទ្រព្យសម្បត្តិ និង បរិស្ថាន ហើយវាមានទំហំធំធេងដែលមិនអាចឱ្យសហគមន៍ទប់ទល់បានដោយខ្លួនឯង ។ គ្រោះមហន្តរាយត្រូវបានគេចាត់ ប្រភេទដោយផ្អែកទៅតាមរូបភាពផ្សេង ៗ គ្នាដូចជា តាមរយៈល្បឿននៃការកើត ឡើងរបស់វា(លឿនឬយឺត) ឬ ដោយផ្អែកលើបុព្វហេតុរបស់វា (បង្កឡើងដោយ មនុស្ស ឬ ធម្មជាតិ)។

### ២. គ្រោះមហន្តរាយនៅកម្ពុជា

ទន្លេមេគង្គ ជាអាយុជីវិតរបស់ប្រជាជនកម្ពុជា ។ ទន្លេមេគង្គ និង ដៃរបស់វា និង ទឹកភ្លៀងដ៏ច្រើនលើសលប់ជាហេតុធ្វើអោយមានទឹកជំនន់ប្រចាំឆ្នាំ ប៉ះពាល់មកលើតំបន់ដែលមានផ្ទៃក្រលាប្រហែល ១៧.១០០ គីឡូ ម៉ែត្រ ឬស្មើនឹង ២៥ ភាគរយនៃផ្ទៃដីទំនាបនៃអាងទន្លេមេគង្គ ។ ភ្លៀងធ្លាក់ខ្លាំង នៅរដូវវស្សា និង ការកាប់បំផ្លាញព្រៃឈើបានធ្វើអោយមានទឹកជំនន់លឿន។ ជាញឹកញាប់លំហូរទឹកទន្លេ មេគង្គមានភាពខ្ពស់ជាងច្រាំង ទន្លេដោយសារតែមានភ្លៀងធ្លាក់ខ្លាំងមានទឹកហូរមកចាក់ក្នុងអាងទន្លេបានធ្វើអោយមានទឹកជំនន់នៅតាមបណ្តា

ខេត្តដែលមានទីតាំងនៅតាមតំបន់ទំនាប ។ តំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់ នៅជុំវិញភ្នំពេញ និង តំបន់មួយភាគធំចុះទៅព្រំដែនប្រទេសវៀតណាម មានផ្ទៃដីប្រមាណ ៧.០០០ គីឡូម៉ែត្រក្រលា ។ ខេត្តដែលប្រឈមមុខនឹងគ្រោះទឹកជំនន់ទន្លេមេគង្គរួមមាន ខេត្តស្ទឹងត្រែង ក្រចេះ កំពង់ចាម កណ្តាល ព្រៃវែង និង ស្វាយរៀង ។

ទឹកជំនន់នៅឆ្នាំ ២០០០ ត្រូវបានគេរាយការណ៍ថា មានសភាពធ្ងន់ធ្ងរជាងគេ នៅក្នុងរយៈពេលជាង ៧០ ឆ្នាំ ។ របាយការណ៍ផ្លូវការនេះ រៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០០ បានអោយដឹងថា មានមនុស្សស្លាប់ចំនួន ៣៤៧ នាក់ ( ក្នុងនោះ ៨០ ភាគរយ ជាកុមារ ) ប្រជាជនចំនួយ ៧៥០ ៦១៨ គ្រួសារស្មើនឹងមនុស្សចំនួន ៣.៤៤៨.៦២៩ នាក់ នៅក្នុង ២១ ខេត្ត និងក្រុង បានទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយទឹកជំនន់ ក្នុងនោះប្រជាជនចំនួន ៨៥.០០០ គ្រួសារស្មើនឹង មនុស្សចំនួន ៣៨៧.០០០នាក់ បានជំលៀសទៅស្នាក់នៅបណ្តោះអាសន្ននៅលើទីទួលសុវត្ថិភាព ។ លើសពីនោះទៀត ផ្ទះចំនួន ៣១៧.៩៧៥ ខ្នងទទួលរងការប៉ះពាល់ ក្នុងនោះ ៧.០៦៨ ខ្នងត្រូវខូចខាតទាំងស្រុង ។ ដំណាំកសិកម្ម និង ដំណាំផ្សេង ៗ ទៀតចំនួន ៦៨៨ ០២១ ហិចតា ត្រូវទទួលរង ការប៉ះពាល់ និង ខូចខាត។ ផ្អែកតាមរបាយការណ៍របស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ គណៈរដ្ឋមន្ត្រីបានប៉ាន់ស្មាន និង វាយតំលៃពីផលប៉ះពាល់ និង ការខូចខាតសរុបអស់ប្រហែល ១៥៧ លានដុល្លា អាមេរិក ។ នៅឆ្នាំ ២០០១ ផលប៉ះពាល់ដោយទឹកជំនន់នៅក្នុងប្រទេសកម្ពុជាត្រូវបានគេវាយតំលៃថាអស់ប្រហែល ៣៦ លានដុល្លាអាមេរិក និង ទឹកជំនន់ ឆ្នាំ ២០០២ មានប្រជាជនចំនួនប្រហែល ១.៥ លាន និង ផ្ទៃដីកសិកម្មចំនួន ៦.០០០ហិចតា ត្រូវបានទទួលការប៉ះពាល់ ។

គេទទួលស្គាល់ថា នៅក្នុងអាងទន្លេមេគង្គ ទឹកជំនន់បានកើតឡើងផ្ទួន ៗ បានធ្វើអោយសំបូរត្រី និង ជីវៈចំរុះនៅក្នុងតំបន់អាចផ្តល់ទឹក ផ្លូវនាវាចរ និង ធ្វើអោយដីកសិកម្មមានជីជាតិ ។ ទាក់ទងនឹងតំបន់ដីសើម នៅតាមទំនាបជាប្រភពសំខាន់សំរាប់ជីវភាពរស់នៅរបស់ប្រជាជនរាប់លាននាក់សំរាប់ប្រកបរបរចិញ្ចឹមជីវិតនៅ តាមតំបន់ដីសើមនេះ ។

ទន្ទឹមគ្នានេះ ទឹកជំនន់ទន្លេមេគង្គបានបង្កអោយមានការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ និង រំខាតដល់សកម្មភាព អភិវឌ្ឍន៍សង្គម និង ការបង្កបង្កើតផលរបស់ប្រជាជននៅតាមតំបន់អាងទន្លេមេគង្គនេះផងដែរ។ ដូច្នេះ សកម្មភាព និង វិធានការកាត់បន្ថយផលប៉ះពាល់គ្រោះទឹកជំនន់គួរត្រូវបានរៀបចំធ្វើ ដូចជា ការអន្តរាគមន៍ ជាក់ស្តែង ការរៀបចំគោលនយោបាយ និង ការរៀបចំផែនការ ដើម្បីទាញយកផលប្រយោជន៍ពីទឹកជំនន់ ដើម្បីធានាការអភិវឌ្ឍន៍ប្រកបដោយ និរន្តរភាពនៅក្នុងប្រទេស ។ ដូចគ្នានេះដែរ ដើម្បីកាត់បន្ថយផលប៉ះពាល់លើអាយុជីវិត និង ទ្រព្យសម្បត្តិរបស់ប្រជាជន។ សកម្មភាព និង វិធានការដែលបានធ្វើកន្លងមកទាក់ទងនឹងការងារគ្រប់គ្រងគ្រោះទឹកជំនន់ គឺផ្តោតសំខាន់តែលើការងារប្រតិបត្តិការជំនួយសង្គ្រោះបន្ទាន់ តែការងារត្រៀម បង្ការ និង កាត់បន្ថយគ្រោះទឹកជំនន់ ជាការងារចាំបាច់ត្រូវធ្វើ និង យកចិត្តទុកដាក់បំផុត ដូចពាក្យចាស់លោកថា "

ការពារប្រសើរជាងព្យាបាល ” ពេលពេលណាដែលទឹកជំនន់បាននាំមកនូវផលប្រយោជន៍ជូនប្រជាជន។ តាមបទពិសោធន៍ពីអតីតកាលបានបង្ហាញអោយយើងដឹងថា ការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានដែលពាក់ព័ន្ធ និងការចូលរួមជាភាគទានជាធនធានដែលអាចមានដើម្បីធ្វើអោយការអនុវត្តន៍កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់នៅតាមមូលដ្ឋាន វាអាចជួយអោយប្រជាជនអាចដោះស្រាយបានយ៉ាងមានប្រសិទ្ធិភាព និង ទាន់ពេលវេលាទៅនឹង គ្រោះទឹកជំនន់តាមរយៈវិធានការណ៍នានា

***តារាង ១ : របាយការណ៍ពីផលប៉ះពាល់ដោយគ្រោះមហន្តរាយនានា នៅកម្ពុជា.***

| ប្រភេទគ្រោះមហន្តរាយ | ឆ្នាំ | ស្លាប់ (នាក់) | គ្មានជំរក (គ្រួសារ) | ប៉ះពាល់ (គ្រួសារ) | សរុបអ្នករងគ្រោះ (គ្រួសារ) |
|---|---|---|---|---|---|
| ទឹកជំនន់ | ១៩៩១ | ១០០ | ២៥០ ០០០ | ៦៥០ ០០០ | ៩០០ ០០០ |
| ជំងឺ: គ្រុនចាញ់ រាគរូស អាសន្នរោគ... | ១៩៩២ | ៥០ | | ៣៨០ ៤០០ | |
| ទឹកជំនន់ | ១៩៩៤ | ៥០៦ | ២៩០០០ | ២៩ ០០០ | |
| រាំងស្ងួត | ១៩៩[illegible] | | | ២ [illegible] | ២ [illegible] |

***តារាង ២ : របាយការណ៍នៃការប៉ាន់ប្រមាណផលប៉ះពាល់ដោយគ្រោះមហន្តរាយនានា គិតជាទឹកប្រាក់ នៅកម្ពុជា.***

| | |
|---|---|
| ***ឆ្នាំ២០០០ :*** | *សរុបជាទឹកប្រាក់ ១៥០ លានដុល្លារសហរដ្ឋអាមេរិក* |
| ***ឆ្នាំ២០០១ :*** | *សរុបជាទឹកប្រាក់ ៣៦ លានដុល្លារសហរដ្ឋអាមេរិក* |
| ***ឆ្នាំ២០០២ :*** | *- រាំងស្ងួត: ២១,៥០០,០០០ ដុល្លារសហរដ្ឋអាមេរិក* |
| | *- ទឹកជំនន់ ១២,៤៥០,០០០ ដុល្លារសហរដ្ឋអាមេរិក* |

## ៣. ទំនាក់ទំនងរវាងមុខសញ្ញាបង្កគ្រោះថ្នាក់ និង ភាពងាយរងគ្រោះ បង្កបានជាគ្រោះមហន្តរាយ

ការកើតឡើងនូវមុខសញ្ញាបង្កគ្រោះថ្នាក់ រឺ បាតុភូតធម្មជាតិដូចជា ទឹកជំនន់ រាំងស្ងួត និង ខ្យល់ព្យុះ គឺមិនមែនជាព្រឹត្តិការណ៍គ្រោះមហន្តរាយនោះទេ ។ មុខសញ្ញាបង្កគ្រោះថ្នាក់ គឺជា ***ព្រឹត្តិការណ៍ធ្ងន់ធ្ងរ*** ដែលអាច ក្លាយ ឬ ក៏បង្កឱ្យមានព្រឹត្តិការណ៍គ្រោះមហន្តរាយ។ **ឧទាហរណ៍** មានដូចជាខ្យល់ព្យុះ ការបាក់ ឬ រអិលផ្ទាំងដី ឧបទ្ទេវហេតុឧស្សាហកម្មផ្សេងៗ។ ប្រសិនបើព្រឹត្តិការណ៍នៃមុខបង្កគ្រោះថ្នាក់ មិនបានបង្កធ្វើអោយការខូចខាត

ធ្ងន់ធ្ងរដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ វិស័យកសិកម្ម និងសកម្មភាពសង្គមផ្សេងៗទេ ព្រឹត្តិការណ៍នោះ ក៏មិនអាចចាត់ទុកជាគ្រោះមហន្តរាយបានដែរ ។

គ្រោះមហន្តរាយកើតឡើងបាននៅពេលមានកក្តាទាំងពីរនេះកើតឡើងរួមជាគ្នា ។ **លក្ខខណ្ឌដែលគ្មាន សុវត្ថិភាព ឬ ភាពងាយរងគ្រោះ** គឺជាស្ថានភាពដែលមនុស្ស និង ទ្រព្យសម្បត្តិប្រឈមមុខទៅនឹងគ្រោះថ្នាក់នៃ គ្រោះមហន្តរាយ ។ សភាពនេះ ធ្វើឱ្យសហគមន៍ងាយរងគ្រោះទៅនឹងមុខសញ្ញាបង្កគ្រោះមហន្តរាយ ។




- ទឹកជំនន់
- រាំងស្ងួត
- រអិលផ្ទាំងដី
- ព្យុះ

***បរិស្ថានមិនល្អ***

- ទីតាំងដែលគ្រោះថ្នាក់
- សំនង់ និង ហេដ្ឋារចនាសម្ព័ន្ធចាស់ និង ទ្រុឌទ្រោម

***សេដ្ឋកិច្ចមិនរឹងមាំ***

- ជីវភាពរស់នៅក្រីក្រ
- កំរិតប្រាក់ចំណូលទាប

- *ស្ពានបាក់ និង ខូចខាត*
- *ផ្លូវខូចខាត និង ដាច់*
- *ដំណាំកសិកម្ម ខូចខាត និង ប៉ះពាល់*
- *មនុស្ស និង សត្វស្លាប់ និង មានជំងឺ*
- *សំណង់សាធារណៈខូចខាត*

# ផ្នែកទី ៣
# ការយល់ដឹងពីការគ្រប់គ្រងគ្រោះមហន្តរាយ

# ការយល់ដឹងពីការគ្រប់គ្រងគ្រោះមហន្តរាយ

## ១.និយមន័យ

ការគ្រប់គ្រងគ្រោះមហន្តរាយគឺជាបណ្តុំនៃវិធានការ និង សកម្មភាព ដែលគេរៀបចំឡើង ដើម្បី អនុវត្ត សំដៅ ត្រៀមបង្ការ ការពារ កាត់បន្ថយ ឆ្លើយតប និង ស្តារ ឬ ជួសជុលឡើងវិញ ចំពោះ គ្រោះមហន្តរាយណាមួយដែលបានកើតឡើង។ គេអាចនិយាយបានម្យ៉ាងទៀតថា ការគ្រប់គ្រងគ្រោះមហន្តរាយគឺ សំដៅលើរាល់សកម្មភាពទាំងអស់ដែលធ្វើឡើងនៅមុនពេល ក្នុងពេល និង ក្រោយពេលគ្រោះមហន្តរាយ ដើម្បីកាត់បន្ថយការ បាត់បង់អាយុជីវិត ការខូចខាតទ្រព្យសម្បត្តិ និង ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ។

## ២. ដំណាក់កាលនៃការងារគ្រប់គ្រងគ្រោះមហន្តរាយ




**នៅមុនពេលគ្រោះមហន្តរាយ**

- ការត្រៀមបង្ការ
- ការកាត់បន្ថយ
- ការការពារ

**ក្នុងពេលគ្រោះមហន្តរាយ**

- ឆ្លើយតប និង ការសង្គ្រោះ
- ការព្យាករណ៍
- ការផ្តល់ពត៌មានជាមុន

**ក្រោយពេលគ្រោះមហន្តរាយ**

- ការស្តារឡើងវិញ
- ការសាងសង់ឡើងវិញ
- ការអភិវឌ្ឍន៍

## ក. ដំណាក់កាលមុនគ្រោះមហន្តរាយ

### ➢ ការការពារ

ការការពារគឺជាសកម្មភាពការងារដែលគេធ្វើឡើង ដើម្បីការពារជាអចិន្ត្រៃយ៍ ចំពោះការគំរាមកំហែងដោយមុខសញ្ញាគ្រោះថ្នាក់ដើម្បីកាត់បន្ថយកំលាំង ឬ ភាពញឹកញាប់នៃព្រឹត្តិការណ៍ដែលជាមុខសញ្ញាគ្រោះថ្នាក់ សំដៅកុំឱ្យវាក្លាយជាព្រឹត្តិការណ៍គ្រោះមហន្តរាយបាននោះទេ ។ សកម្មភាពនៃការ ការពាររួមមានសកម្មភាពដែលរៀបចំឡើង ក្នុងគោលបំណង ឃាយាំងការកើតឡើងនៃព្រឹត្តិការណ៍នៃគ្រោះថ្នាក់ ឬ ដើម្បី ការពារកុំឱ្យកើតមានព្រឹត្តិការទាំងនេះ ដែលជាហេតុនាំឱ្យ មានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់សហគមន៍ និង ហេដ្ឋារចនា សម្ព័ន្ធផ្សេងៗ ។

***ឧទាហរណ៍ :*** ការគ្រប់គ្រង ទឹកជំនន់ការរៀបចំ ច្បាប់នៃការប្រើប្រាស់ដីធ្លី កម្មវិធីកាត់បន្ថយភាពក្រីក្រ ការផ្តល់អោយតំរូវការជាមូលដ្ឋាន ការការពារសុខភាព និង ការផ្តល់ការអប់រំ។ សកម្មភាពនៃការការពារនិងការកាត់បន្ថយគឺត្រូវបានភ្ជាប់ភ្ជាប់ទៅលើការងារអភិវឌ្ឍន៍ ។

### ➢ ការកាត់បន្ថយ

ជាវិធានការដែលធ្វើឡើងនៅមុនពេល និងក្នុងពេល មានមុខសញ្ញាគ្រោះថ្នាក់បានកើតឡើង សំដៅកាត់បន្ថយនូវផលប៉ះពាល់អាយុជីវិត មនុស្ស សត្វ ហេដ្ឋារចនាសម្ព័ន្ធ វិស័យកសិកម្ម ដំណើរការសង្គមផ្សេងៗ បរិស្ថាន និង សង្គម ។ សកម្មភាពទាំងនេះ គឺរួមបញ្ចូល ទាំងវិធានការទាំងឡាយ ដែលអាចអនុវត្ត ដើម្បីកាត់បន្ថយឥទ្ធិពលដែលបង្កដោយមុខសញ្ញាគ្រោះថ្នាក់ ។ ដូច្នេះ ការកាត់បន្ថយ គឺជាការបន្ថយ ទំហំនៃការខូចខាតដោយ មុខសញ្ញាគ្រោះថ្នាក់ ហើយវិធានការនេះ យើងអាចធ្វើបាន ទៅតាមរូបភាពពីរ ដូចជា :

- ***វិធានការតាមបែបហេដ្ឋារចនាសម្ព័ន្ធ*** ដូចជា : ការសាងសង់ទំនប់ និង ការសាងសង់ផ្ទះដែលមានសុវត្ថិភាពតាក់តែងច្បាប់ ( ឧ. ការដាក់កំរិតប្រជា ជនមិនអោយទៅសាងសង់ផ្ទះនៅលើ ទំនប់) ។
- ***វិធានការតាមបែបមិនហេដ្ឋារចនាសម្ព័ន្ធ*** មានដូចជា : ការបណ្តុះបណ្តាលរៀបចំចងក្រងក្រុមអ្នកស្ម័គ្រចិត្តសំរាប់សង្គ្រោះ ការយល់ដឹងជាសាធារណៈ សុវត្ថិភាព ស្បៀង កម្មវិធីនិងការស្វែងរកការគាំទ្រ នៅលើការដោះស្រាយបញ្ហា (Advocacy) ។

### ➢ ការត្រៀមបង្ការ

ការត្រៀមបង្ការគ្រោះមហន្តរាយគឺជាវិធានការ និង សកម្មភាពផ្សេងៗដែលគេត្រូវអនុវត្តសំដៅត្រៀម រៀបចំជាមុនដើម្បីធានាថារាល់សកម្មភាព ឬ វិធានការ ដ៏មាន ប្រសិទ្ធិភាពឡាយត្រូវបានអនុវត្តយ៉ាង ត្រឹមត្រូវ

នៅពេលមានមុខសញ្ញា គ្រោះថ្នាក់កើត ឡើង ។ការត្រៀមបង្ការគ្រោះមហន្តរាយគឺដើម្បី កាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយដោយ ការរៀបចំ ការឆ្លើយតបនិងធ្វើសកម្មភាពផ្សេងៗ ទៀតតាមលំដាប់លំដោយដើម្បីអន្តរាគមន៍ភ្លាមៗ ឱ្យទាន់ពេល វេលានៅពេលមុខសញ្ញាគ្រោះថ្នាក់ កើតឡើង ***ឧទាហរណ៍:*** ការពង្រឹងសមត្ថភាពគឺដើម្បីធ្វើការប្រកាសអាសន្នជាមុន ការស្រាវជ្រាវនិងសង្គ្រោះ ការជំលៀស និង ប្រតិបត្តិការផ្តល់អំណោយសង្គ្រោះ ការរៀបចំនិងការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះមហន្តរាយ ស្តុកសំភារៈនិងការផ្គត់ផ្គង់ ការទំនាក់ទំនងបន្ទាន់ ការបណ្តុះបណ្តាលក្រុមសង្គ្រោះតូចៗ សមយុទ្ធពីការរៀបចំក្រុម សង្គ្រោះ ការផ្សព្វផ្សាយឱ្យមានការយល់ដឹងជាសាធារណៈពីគ្រោះមហន្តរាយ ។ ដូច្នេះ ការងារត្រៀមបង្ការគ្រោះមហន្តរាយមានសកម្មភាពសំខាន់ ៧ ដូចខាងក្រោម :

- **ការផ្សព្វផ្សាយ និងបង្កើនការយល់ដឹងជាសាធារណៈ**

ការត្រៀមបង្ការគ្រោះមហន្តរាយគឺត្រូវទាមទានូវការងារផ្សព្វផ្សាយឱ្យមានការយល់ដឹងជាសាធារណៈជាច្រើនបែប ។ ដំណើរការធ្វើផែនការសកម្មភាព នឹងមានប្រសិទ្ធភាពទៅបានដរាបណាអ្នកទទួលផល ទាំងនោះ បានដឹងនូវអ្វីដែលគេត្រូវធ្វើនៅមុនពេល ក្នុងពេលមាន និង ក្រោយពេលមានគ្រោះមហន្តរាយ។ ហេតុនេះហើយ ផ្នែកសំខាន់មួយទៀតនៃផែនការសកម្មភាពសំរាប់ត្រៀមបង្ការគ្រោះមហន្តរាយ គឺការផ្តល់ចំណេះដឹងទៅដល់អ្នក ដែលនឹងទទួលការគំរាមកំហែងដោយមុខសញ្ញាគ្រោះថ្នាក់។ គួរតែធ្វើការផ្សព្វផ្សាយឱ្យមានការយល់ដឹងច្បាស់ លាស់ពីវិធានការសំរាប់ការត្រៀមបង្ការគ្រោះមហន្តរាយដែល អនុវត្តតាមរូបភាព ជាក្រុមគ្រួសារផ្ទាល់ និងសហគមន៍ផងដែរ ។ ប្រជាជនជាពិសេសអ្នកដែលរស់នៅក្នុងតំបន់ដែលប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ គួរតែបានដឹង ច្បាស់លាស់ផងដែរអំពី ផែនការសកម្មភាពសំរាប់ត្រៀមបង្ការគ្រោះមហន្តរាយក្នុងសហគមន៍ គេ និងសកម្មភាព ផ្សេងៗទៀតដែលត្រូវធ្វើដើម្បីឱ្យពួកគេ អាចចូលរួមក្នុងដំណើរការអនុវត្តផែនការនេះ ។

- **ការបណ្តុះបណ្តាល និងការពង្រឹងសមត្ថភាព**

វាមានសារៈសំខាន់ណាស់ដែលត្រូវធ្វើការបណ្តុះបណ្តាល និង ពង្រឹងសមត្ថភាពដល់ស្ថាប័ន និងក្រុមទទួលខុសត្រូវលើការគ្រប់គ្រងគ្រោះមហន្តរាយនៅគ្រប់លំដាប់ថ្នាក់ ។ការបណ្តុះបណ្តាលមិនមែនជាការងារដែលត្រូវធ្វើតែម្តងហើយចប់នោះទេ ។ ការរៀបចំវគ្គបណ្តុះបណ្តាលបំប៉នឡើងវិញ ក៏ជាការងារដែលមាន សារៈសំខាន់ផងដែរ។

ការបណ្តុះបណ្តាលគួរតែត្រូវធ្វើឡើងនៅតាមមធ្យោបាយផ្សេងៗដែលអាចធ្វើបានហើយគេត្រូវធ្វើការបណ្តុះបណ្តាលពីជំនាញការងារនិមួយៗទៅដល់ក្រុមការងារជាក់លាក់និមួយៗដែលទទួលខុសត្រូវក្នុងការអនុវត្តផែនការត្រៀមបង្ការ គ្រោះមហន្តរាយ។



## ខ. ដំណាក់កាលក្នុងពេលគ្រោះមហន្តរាយ

### ➢ ការឆ្លើយតប និងសង្គ្រោះបន្ទាន់

ការឆ្លើយតប និង ការសង្គ្រោះបន្ទាន់វាពាក់ពន្ធ័នឹងសកម្មភាពចាំបាច់ផ្សេងៗ ក្នុងការងារ ស្រាវជ្រាវ និងរុករកសង្គ្រោះ ដើម្បីស្រោចស្រង់អាយុជីវិត និង បំពេញតំរូវការជាមូលដ្ឋានរបស់អ្នករងគ្រោះ ដូចជា ការជម្លៀស ការផ្តល់ពតិមានជាមុន ការផ្តល់ជំរក ទឹកស្អាត ស្បៀងអាហារ និងការថែទាំសុខភាព។ ការងារឆ្លើយតបគឺរួមបញ្ចូលទាំង សេវាកម្ម និង សកម្មភាពទាំងអស់ដែលត្រូវ អនុវត្តដើម្បីជួយដល់ប្រជាជន ដែលរងគ្រោះក្រោយគ្រោះមហន្តរាយកើតឡើង ***ឧទាហរណ៍ :*** ការស្រាវជ្រាវ និង ការសង្គ្រោះអ្នករងគ្រោះ ការផ្តល់ស្បៀងអាហារ និង សំភារៈផ្សេងៗ សុខភាពបន្ទាន់ អន្តរាគមន៍ជួយសំរួលដល់ការលំបាករបស់អ្នក រងគ្រោះ ការជួសជុលសំភារៈ និង បរិក្ខាផ្សេងៗ (ឧ. ស្ថាន មធ្យោបាយនៅក្នុងការទំនាក់ទំនង)។

### ➢ ការព្យាករណ៍ និងការផ្តល់ពត៏មានជាមុន

ភាគច្រើននៃប្រភេទគ្រោះមហន្តរាយដែលកើតឡើងបន្ទាន់ភ្លាមៗការផ្តល់ពិតមានជាមុនអាចជួយសង្គ្រោះអាយុជីវិតបានយ៉ាងច្រើន ដោយការផ្តល់ឱ្យក្រុមអ្នកងាយរងគ្រោះ នូវការកត់សំគាល់មួយអំពីស្ថានភាពជិតមក ដល់នៃមុខសញ្ញាគ្រោះថ្នាក់ ហេតុនេះគេអាចគេចចេញពីព្រឹត្តិការណ៍ នោះ រឺ មួយគេអាចធ្វើការប្រុងប្រយត្ន័ជាមុន ដើម្បីអាច កាត់បន្ថយនូវគ្រោះថ្នាក់ចំពោះគេបាន។ គេត្រូវកំនត់ និង ដាក់បញ្ចូលទៅក្នុងផែនការត្រៀមបង្ការគ្រោះមហន្តរាយនូវមធ្យោបាយនិងវិធីសាស្រ្តដ៏ត្រឹមត្រូវក្នុងការផ្សព្វផ្សាយពតិមានដល់ក្រុមងាយរងគ្រោះ ដើម្បីធ្វើ ឱ្យការផ្តល់ពិតមានជាមុនបានត្រឹមត្រូវនិងមានប្រសិទ្ធិភាពបំផុតនោះ ។ វាមានសារៈសំខាន់ណាស់ដែលយើងចាំបាច់ត្រូវធានាថាពតិមានពីមុខសញ្ញាគ្រោះថ្នាក់ដែលយើងបានផ្សព្វផ្សាយ គឺបាន ទៅដល់អ្នកដែលប្រឈមមុខនឹងគ្រោះថ្នាក់ហើយពួកគាត់អាចយល់បានច្បាស់

លាស់ពីពត៌មានទាំងនោះ ។ ការធ្វើផែនការសំរាប់ការផ្តល់ពត៌មានជាមុនពីមុខសញ្ញាគ្រោះថ្នាក់នេះ គេគួរកំនត់ឱ្យបានច្បាស់ថា តើគេត្រូវផ្តល់ ពត៌មានទៅដល់អ្នកទាំងនោះ តាមមធ្យោបាយណា និង អ្នកណាទទួលខុសត្រូវនៅគ្រប់លំដាប់ថ្នាក់ សំរាប់ ឆ្លើយតបទៅនឹងពត៌មាន ។




➢ **ការស្រាវជ្រាវ និង រុករកសង្គ្រោះ :**

សកម្មភាពផ្សេងៗនៃការងារត្រៀមបង្ការគ្រោះមហន្តរាយគឺគួតែមានរៀបចំក្រុមការងារឆ្លើយតប។ ក្រុមនេះគួរទទួលការបណ្តុះបណ្តាល និង ត្រូវរៀបចំនៅថ្នាក់ខេត្ត ស្រុក ឃុំ ថ្នាក់ភូមិ ដើម្បីអនុវត្តការស្រាវជ្រាវ រុករកសង្គ្រោះទាំងនៅក្នុងទឹក និងលើគោក។ សមាជិកក្រុមនេះគួរ ដឹងនូវគោលការណ៍នៃការរុករកនិង សង្គ្រោះ និង បច្ចេកទេសជាមូលដ្ឋានសំរាប់ធ្វើការសង្គ្រោះជីវិត រួមទាំងបច្ចេកទេសការសង្គ្រោះបឋមផងដែរ។



## ➢ វិធានការកាត់បន្ថយ

ដោយផ្អែកលើពត៌មានស្តីពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាពដែលគេប្រមូលបាន ពីសហគមន៏ ដូច្នេះគេអាចកំនត់បាននូវវិធានការនិងសកម្មភាពផ្សេងៗ សំរាប់ កាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់ ទាំង តាមបែបហេដ្ឋារចនាសម្ព័ន្ធ និង មិនមែនហេដ្ឋា រចនាសម្ព័ន្ធដែលគេអាចអនុវត្តសំដៅកាត់បន្ថយ ឥទ្ធិពលមុខសញ្ញា គ្រោះថ្នាក់ទៅលើសហគមន៏ ។ តាមរយៈវិធានការផ្សេងៗទាំងនេះ សហគមន៏នឹងអាច ធ្វើការវិភាគនិងសំរេចចិត្ត ថាតើវិធានការណាខ្លះដែលចាំបាច់ត្រូវអនុវត្តភ្លាមៗ ដោយហេតុថាវាមិនត្រូវការប្រើប្រាស់ធនធានពីខាងក្រៅ សហគមន៏(ដូចជា វិធានការដែលមិនចាំបាច់ចំណាយប្រាក់ រឺ ចំណាយតិចតួច) និង វិធានការផ្សេងទៀត ដែលចាំបាច់ត្រូវប្រើប្រាស់ធនធានពីខាងក្រៅ ។



## គ. ដំណាក់កាលក្រោយពេលគ្រោះមហន្តរាយ

- **ការស្តារឡើងវិញ និង សាងសង់ឡើងវិញ**

ការសាងសង់ឡើងវិញ គឺជាពាក្យដែលគេប្រើដើម្បីបញ្ជាក់ពីវិធានការជាអចិន្ត្រៃយផ្សេងៗ ដែលគេធ្វើ ឡើង ដើម្បីជួសជុល រឺ ជំនួសឡើងវិញនូវ លំនៅដ្ឋាន ហេដ្ឋារចនាសម្ព័ន្ធដែលខូចខាត និង ដើម្បីធ្វើឱ្យសេដ្ឋកិច្ច ដំណើរការឡើងវិញ ។ សកម្មភាពនៃការសាងសង់លំនៅដ្ឋានអចិន្ត្រៃយ៏ និងស្តារទាំងស្រុងឡើងវិញនូវរាល់សេវាកម្មទាំងអស់ ។

ការស្តារឡើងវិញ និងរៀបចំឡើងវិញគឺសំដៅទៅលើដំណើរនៃការអនុវត្តដោយសហគមន៏ដែលទទួលផលប៉ះពាល់ដោយគ្រោះមហន្តរាយ ដើម្បីជំនួសឡើងវិញទាំងស្រុងឱ្យដូចស្ថានភាពដើមមុនពេលមានគ្រោះមហន្តរាយការស្តារឡើងវិញពាក់ពន្ធ័ទៅនឹងអន្តរាគមន៏ផ្សេងៗដើម្បីជំនួសឡើងវិញនូវសេវាកម្មជាមូលដ្ឋាន ដើម្បីសំរួលដល់ដំណើរការរៀបចំឡើងវិញរបស់អ្នកដែលទទួលរងគ្រោះ ។ ***ឧទាហរណ៏ :*** គាំទ្រដល់ប្រជាពលរដ្ឋដើម្បីជួសជុលផ្ទះ របស់គេឡើងវិញ ការបង្កើតជាថ្មីឡើងវិញនូវសេវាកម្មសំខាន់ៗដូចជា បរិក្ខាផ្សេងៗក្នុងសហគមន៏ និង ការធ្វើឱ្យដំណើរការឡើងវិញ នូវសកម្មភាពសង្គម និង សកម្មភាព សេដ្ឋកិច្ចនានា ។

**ពង្រាងទី ១**



# ផ្នែកទី ៤

# ការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាពរបស់សហគមន៍

ឧបសម្ព័ន្ធទី ១

# ការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះថ្នាក់
# ភាពងាយរងគ្រោះ និង សមត្ថភាពរបស់សហគមន៍

## ១. តើអ្វីទៅជាការប៉ាន់ប្រមាណលើ មុខសញ្ញាគ្រោះថ្នាក់ ភាពងាយរងគ្រោះ និង សមត្ថភាព?

សំដៅទៅលើដំណើរការនៅក្នុងការប្រមូលពិតមានអំពីរូបភាពជាក់ស្តែងនៃមុខសញ្ញាគ្រោះថ្នាក់ដែលធ្លាប់កើតមានកន្លងមក និង ផលប៉ះពាល់នាពេលបច្ចុប្បន្ន ព្រមទាំងភាពងាយរងគ្រោះក្នុងសហគមន៍ ហើយនិងធនធានដែលមានស្រាប់នៅសហគមន៍ដែលគេអាចយកមកប្រើប្រាស់ដើម្បីទប់ទល់រឺកាត់បន្ថយផលប៉ះពាល់ដោយសារមុខសញ្ញាគ្រោះថ្នាក់។

វាមានសារសំខាន់ណាស់ដែលត្រូវចងចាំថាការធ្វើHVCA វាមិនមែនជាដំណាក់កាលចុងក្រោយនោះទេ។

ផ្ទុយទៅវិញ ការធ្វើ HVCA គឺដើម្បីស្វែងរកពតិមានអំពីប្រវត្តិនៃស្ថានភាព គ្រោះថ្នាក់ដោយគ្រោះមហន្តរាយដែលធ្លាប់កើតមាននៅសហគមន៍ ហើយផ្អែកលើពតិមាននេះ គឺយើងអាចឈានទៅបង្កើត និងអនុវត្តផែនការសកម្មភាពសំរាប់ត្រៀមបង្ការនិងកាត់បន្ថយគ្រោះមហន្តរាយ សំរាប់សហគមន៍។

## ២. តើធាតុសំខាន់ៗរបស់ HVCA មានអ្វីខ្លះ?

ដំណើរការធ្វើ HVCA គឺវាពាក់ពន្ធ័ទៅនឹង :

### ក. ការប៉ាន់ប្រមាណលើមុខសញ្ញាគ្រោះមហន្តរាយ

អ្នកពាក់ពន្ធ័ទាំងអស់របស់សហគមន៍ធ្វើការកំនត់និងវិភាគលើលក្ខណៈធម្មជាតិរបស់មុខសញ្ញា គ្រោះថ្នាក់ រឺ ការគំរាមកំហែងដែលអាចកើតមានចំពោះសហគមន៍។ តាមរយៈដំណើរការប៉ាន់ប្រមាណនេះ យើងអាចកំនត់បានពីប្រូបាបប៊ីលីតេ( ភាពអាចកើតមាន) នៃការកើតឡើងរបស់មុខសញ្ញាគ្រោះថ្នាក់ភាពញឹកញាប់នៃការកើតឡើងរបស់វា ដូចជា: ទំហំ និង រយៈពេលដែលវាកើតឡើង ព្រមទាំងប្រភេទមុខសញ្ញា គ្រោះថ្នាក់ផងដែរ។

### ខ. ការប៉ាន់ប្រមាណភាពងាយរងគ្រោះ

**ពន្លាទី ១**

អ្នកពាក់ពន្ធ័ទាំងអស់របស់សហគមន៍ធ្វើការកំនត់នូវធាតុដែលប្រឈមមុខទៅនឹងគ្រោះថ្នាក់ (មនុស្ស រចនាសម្ព័ន្ធផ្សេងៗ ជីវភាពរស់នៅ .. ។ល។) ដោយសារប្រភេទនៃមុខសញ្ញាគ្រោះថ្នាក់ និមួយៗ ហើយធ្វើការ វិភាគថា តើហេតុអ្វីបានជាធាតុទាំងនេះប្រឈមមុខទៅនឹងគ្រោះថ្នាក់ ។

## គ. ការប៉ាន់ប្រមាណលើសមត្ថភាព

អ្នកពាក់ពន្ធ័ទាំងអស់របស់សហគមន៍ធ្វើការកំនត់ពីសមត្ថភាពរឺធនធានដែលគេអាចប្រើប្រាស់បាននៅពេល មានស្ថានភាពបន្ទាន់ រឺ នៅពេលមានវិបត្តិ សំដៅកាត់បន្ថយការបំផ្លាញដោយសារ គ្រោះមហន្តរាយ ហើយនិង ដើម្បីធ្វើឱ្យជីវភាពរស់នៅរបស់គេ មានសុវត្ថិភាព ។

## ឃ. ដំហាននៃការអនុវត្ត HVCA

១. បង្ហាញពីគោលបំណងនៃការធ្វើ HVCA និង ជំហានរបស់វា ដល់អ្នកដែលពាក់ពន្ធ័ទាំងអស់

២. ពន្យល់ពីផ្នែកនិមួយៗនៃការប៉ាន់ប្រមាណមុខសញ្ញាគ្រោះមហន្តរាយ

៣. ពន្យល់ពីផ្នែកនិមួយៗនៃការប៉ាន់ប្រមាណភាពងាយរងគ្រោះ

៤. ពន្យល់ពីផ្នែកនិមួយៗនៃការប៉ាន់ប្រមាណសមត្ថភាព

៥. វិភាគលើពត៌មានដែលបានប្រមូលដោយស្រង់យកពត៌មានទាំងអស់ដែលប្រមូលបានបញ្ចូលក្នុង តារាងប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះមហន្តរាយ ភាពងាយរងគ្រោះ និង សមត្ថភាព ។

ជាទូទៅ ឧបករណ៍មួយចំនួនខាងក្រោមនេះ គឺ អាចប្រើប្រាស់បានសំរាប់ធ្វើ HVCA:

| **ប្រភេទពត៌មាន** | **មធ្យោបាយរឺ ឧបករណ៍ដែលអាចប្រើបាន** |
|---|---|
| មុខសញ្ញាគ្រោះមហន្តរាយ | ការគូផែនទី ប្រវត្តិសហគមន៍ ការសំភាសន៍លើក្រុមចំណាប់អារម្មណ៍ ការដើរកាត់ ទទឹងភូមិ និង ប្រតិទិនរដូវកាល |
| ភាពងាយរងគ្រោះ | ផែនទីមុខសញ្ញាគ្រោះមហន្តរាយ (អំពីធាតុដែលប្រឈមមុខនឹងគ្រោះថ្នាក់) ការដើរ កាត់ទទឹងភូមិ ចាត់អាទិភាពទ្រព្យធន ការវិភាគជីវភាពរស់នៅ ការវិភាគបញ្ហាតាម ដើមឈើ ការសំភាសន៍ពាក់កណ្តាលផ្លូវការ |
| សមត្ថភាព | ប្រើប្រាស់មធ្យោបាយទាំងអស់ដែលមានខាងលើ និង បន្ថែម ផែនទី វេនឌ៊ីរ |

| | |
|---|---|
| | ការសំភាសន៍បែបយែនឌ័រ |
| គ្រោះថ្នាក់ដោយគ្រោះមហន្តរាយ | ចាត់អាទិភាពបញ្ហា |

## ខ. តើយើងត្រូវធ្វើការប៉ាន់ប្រមាណពីមុខសញ្ញាគ្រោះមហន្តរាយតាមរបៀបណា?

- ប្រើមធ្យោបាយ រឺ ឧបករណ៍ទាំងឡាយដែលបានរៀបរាប់ក្នុងតារាងខាងលើ ដើម្បីប្រមូល ពត៌មាន
- សរុប និងចងក្រងពត៌មានទាំងអស់ដែលទទួលបាន បញ្ចូលក្នុងតារាងប៉ាន់ប្រមាណមុខសញ្ញាគ្រោះថ្នាក់ ដូចមានឧទាហរណ៍ខាងក្រោមៈ

| **ប្រភេទមុខសញ្ញាគ្រោះមហន្តរាយ** | **ទឹកជំនន់** |
|---|---|
| កំលាំង រឺ ឥទ្ធិពលវា | ទឹកលិច ខ្យល់ព្យុះ ភ្លៀងធ្លាក់ខ្លាំង ទឹករលកធំៗ |
| សញ្ញាអាសន្នដែលអាចឱ្យដឹងបានជាមុន | ដំណឹងតាមទូរទស្សន៍ វិទ្យុ ឬ កាសែតនៅពេលដែលមានភ្លៀងធ្លាក់លើសពី ២ ថ្ងៃ |
| រយៈពេលនៃការមកដល់ | ចន្លោះ ពី ២ ម៉ោង ទៅ ២ ថ្ងៃ |
| ល្បឿននៃការកើតឡើង | លឿន |
| ភាពញឹកញាប់របស់វា | រាល់ពេលដែលមានរលកធំៗ នៅពេលដែលមានខ្យល់ព្យុះឆ្លងកាត់ (ប្រមាណជា ៦ លើក ក្នុងមួយឆ្នាំ) នៅរដូវភ្លៀងធ្លាក់ នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំង |
| នៅពេលណា | ពី ខែ ៦ ដល់ ខែ ១០ |
| រយៈពេលដែលវាកើតមាន | ២ ថ្ងៃ ដល់ ៣ ខែ |

## ច. តើយើងត្រូវធ្វើការវាយតម្លៃប្រមាណភាពងាយរងគ្រោះតាមរបៀបណា?

ប្រើមធ្យោបាយនិងឧបករណ៍ដែលមានរៀបរាប់នៅក្នុងតារាងខាងលើដើម្បីប្រមូលពត៌មានដែល ពាក់ពន្ធ័ទៅនឹងភាពងាយរងគ្រោះបន្ទាប់មកសរុបពត៌មានទាំងនោះចូលក្នុងតារាងប៉ាន់ប្រមាណភាពងាយរងគ្រោះខាងក្រោម :

ដើម្បីឱ្យការវិភាគពីភាពងាយរងគ្រោះកាន់តែច្បាស់លាស់លើមុខសញ្ញាគ្រោះមហន្តរាយនិមួយៗនោះ គេត្រូវប្រើតារាងខាងក្រោមនេះ :

**ប្រភេទមុខសញ្ញាគ្រោះមហន្តរាយ: ទឹកជំនន់**

| តំបន់ដែលប្រឈមមុខ | ប្រជាពលរដ្ឋដែលប្រឈមមុខ | សេវាកម្មផ្សេងៗដែលប្រឈមមុខ | ប្រភពនៃធនធាជីវភាពរស់នៅដែលប្រហែលនឹងរងផលប៉ះពាល់ | ហេដ្ឋារចនាសម្ព័ន្ធដែលប្រហែលជារងផលប៉ះពាល់ | រចនាសម្ព័ន្ធផ្សេងៗទៀតដែលប្រហែលជារងផលប៉ះពាល់ |
|---|---|---|---|---|---|
| តំបន់ឆ្នេរ | | | | | |
| តំបន់កសិកម្ម | | | | | |
| តំបន់ក្នុងភូមិ | | | | | |

នៅក្នុងតារាងខាងលើនេះ គេអាចបន្ថែមកូឡោនបានដោយអាស្រ័យទៅលើប្រភេទនៃភាពងាយរងគ្រោះដែលគេបានកំនត់។

| **ប្រភេទមុខសញ្ញាគ្រោះមហន្តរាយ** | **ធាតុដែលប្រឈមមុខនឹងគ្រោះថ្នាក់** | **ហេតុអ្វីបានជាវាប្រឈមមុខ** |
|---|---|---|
| ទឹកជំនន់ | | |
| រាំងស្ងួត | | |
| ខ្យល់ព្យុះទីហ្វុង | | |
| ផ្សេងៗទៀត | | |

## ឆ. តើយើងត្រូវធ្វើការប៉ាន់ប្រមាណសមត្ថភាពធនធានតាមរបៀបណា?

ចំពោះកម្មវិធី រឺ ការងារត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍ ពាក្យថា សមត្ថភាព គឺសំដៅទៅលើ ធនធាន និង កំរិតនៃភាពខ្លាំងដែលមានចំពោះបុគ្គល រឺ សហគមន៍ រឺ គ្រួសារ ដែលអាចឱ្យគេប្រើប្រាស់សំរាប់ទប់ទល់ រឺ ត្រៀមបង្ការ រឺ ការពារ រឺ កាត់បន្ថយ រឺ ឆ្លើយតបចំពោះគ្រោះមហន្តរាយបាន។ ការប៉ាន់ប្រមាណសមត្ថភាព គឺ សំដៅការស្វែងយល់ថា តើសហគមន៍ដោះស្រាយបញ្ហាបែបណានៅពេលមានវិបត្តិកើតឡើង។ ជាទូទៅការធ្វើប៉ាន់ប្រមាណនេះ គឺ ការស្វែងរកពត៌មានមូលដ្ឋានពីរ ប្រភេទ:

- ស្វែងយល់ថាតើប្រជាពលរដ្ឋធ្លាប់មានបទពិសោធន៍ដោះស្រាយដូចម្តេចចំពោះព្រឹត្តិការណ៏គ្រោះមហន្តរាយ និង យុទ្ធសាស្ត្រក្នុងការទប់ទល់។
- វិភាគថាតើធនធានអ្វីខ្លះដែលមានស្រាប់ហើយដែលគេធ្លាប់ប្រើប្រាស់ដើម្បីកាត់បន្ថយគ្រោះថ្នាក់ដោយគ្រោះមហន្តរាយ។ ទន្ទឹមនេះ គេក៏ចង់ដឹងផងដែរថា តើនរណាដែលអាចទទួលផលពីធនធានទាំង នេះ ហើយនរណាជាអ្នកត្រួតត្រា រឺ គ្រប់គ្រងលើវា។

ដូចគ្នាទៅនឹងការប៉ាន់ប្រមាណមុខសញ្ញាគ្រោះមហន្តរាយ និង ភាពងាយរងគ្រោះដែរ គឺគេអាចយកពត៌មានពីការប្រើប្រាស់ឧបករណ៏ផ្សេងៗ ហើយបញ្ចូលពត៌មានទាំងនេះ ចូលក្នុងតារាងសំរាប់ប៉ាន់ប្រមាណសមត្ថ-ភាព ដូចខាងក្រោម:

| មុខសញ្ញាគ្រោះមហន្តរាយ | យុទ្ធសាស្ត្រក្នុងការទប់ទល់ | ធនធានដែលមាន និង ធ្លាប់ប្រើ |
|---|---|---|
| | | |
| | | |
| | | |
| | | |

តារាងខាងលើនេះគឺជួយឱ្យយើងងាយស្រួលស្វែងយល់ពីសមត្ថភាពទូទៅរបស់សហគមន៍ តែដើម្បីងាយស្រួលនៅពេលធ្វើផែនការកាត់បន្ថយនិងត្រៀមបង្ការគ្រោះមហន្តរាយ គេត្រូវប្រើតារាង ខាងក្រោមនេះវិញ:

**ឧបសម្ព័ន្ធទី ១**

| **វិស័យ** | **ធនធានមនុស្ស** | **ធនធានសំភារៈ** |
| --- | --- | --- |
| បរិស្ថាន | | |
| សេដ្ឋកិច្ច | | |
| ហេដ្ឋារចនាសម្ព័ន្ធ | | |
| សុខភាព | | |

# ផ្នែកទី ៥

# កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍

# កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍

## ១. តើអ្វីគឺជាការត្រៀមបង្ការគ្រោះមហន្តរាយ?

ទោះបីជាយើងខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីដោះស្រាយបញ្ហាផ្សេងៗដែលកើតមានឡើងក្នុង ពេល និង ក្រោយពេលមានគ្រោះមហន្តរាយ តែស្ថានភាពជាក់ស្តែងនៅពេលនោះ គឺ វាធ្ងន់ធ្ងររួចជា ស្រេចទៅហើយ។ ការណ៍នេះ គឺដោយសារតែការប្រឹងប្រែង និង សកម្មភាពរបស់យើង គឺ ផ្តោតការ យកចិត្តទុកដាក់តែទៅលើ **ការងារឆ្លើយតប** នឹងព្រឹត្តិការណ៍គ្រោះមហន្តរាយ ច្រើនជាងយកចិត្តទុក ដាក់ទៅលើ **ការការពារ** និង **កាត់បន្ថយ** ឥទ្ធិពលរបស់មុខសញ្ញាគ្រោះថ្នាក់។ ***ស្ថានភាពនេះ វាមានន័យ មិនខុសគ្នាពីការព្យាយាមដើររកថ្នាំ ដើម្បីព្យាបាលជំងឺនៅ ពេលដែលយើងធ្លាក់ខ្លួនឈឺរួចជាស្រេច ហើយនោះទេ*** (ការពារប្រសើរជាងព្យាបាល)។

ការការពារជាមុនកុំឱ្យកើតមានជំងឺ វាមិនមែនត្រឹមតែជាមធ្យោបាយដ៏មានប្រសិទ្ធិភាពប៉ុណ្ណោះ ទេ លើសពីនេះទៅទៀត គឺវាអាចចំណាយធនធានអស់តិចតួចទៀតផង ។ ស្ថានភាពនេះ គឺ ស្រដៀងគ្នាទៅនឹង ព្រឹត្តិការណ៍គ្រោះមហន្តរាយដែលបានកើតឡើងដែរ។ កន្លងមកយើងតែងតែខំប្រឹង ប្រែងធ្វើការឆ្លើយតបទៅនឹង គ្រោះមហន្តរាយជាបន្ទាន់ភ្លាមៗ នៅពេលវាកើតឡើង ។ ផ្ទុយទៅវិញ យើងមិនបានប្រឹងប្រែងស្វែងយល់ថា តើហេតុអ្វីបានជាពេលនេះមានគ្រោះកើតឡើងនៅសហគមន៍យើង នោះទេ បើពេលមុនៗមិនធ្លាប់មានផងនោះ។

ដូចបានបញ្ជាក់រួចមកហើយនៅមេរៀនមុនថា "*ការត្រៀមបង្ការគ្រោះមហន្តរាយគឺជាវិធានការ និង សកម្មភាពផ្សេងៗដែលគេត្រូវអនុវត្តសំដៅត្រៀមរៀបចំជាមុនដើម្បីធានាថារាល់សកម្មភាព រឺ វិធានការដ៏មាន ប្រសិទ្ធិភាពទាំងឡាយត្រូវបានអនុវត្តនៅពេលមានមុខសញ្ញាគ្រោះថ្នាក់កើតឡើង។ ការត្រៀមបង្ការគ្រោះមហន្ត រាយ គឺដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ ដោយការរៀបចំ ការឆ្លើយតបនិងធ្វើសកម្មភាពផ្សេងៗ ទៀតតាមលំដាប់លំដោយ ដើម្បីអន្តរាគមន៍បន្ទាន់ភ្លាមៗឱ្យទាន់ ពេលវេលានៅពេលគ្រោះមហន្តរាយកើតឡើង*"។

យើងត្រូវទទួលស្គាល់ថាការត្រៀមបង្ការគ្រោះមហន្តរាយជាគោលបំណងរយៈពេលវែងមិនមែនត្រឹមតែជ ាការអនុវត្តន៍កម្មវិធីតូចណាមួយក្នុងរយៈពេលខ្លីនោះទេ។ មានន័យថា វាគឺជាលទ្ធផលដែលបានពីសកម្មភាព ការងារជាច្រើនរួមបញ្ចូលគ្នាជាបន្តបន្ទាប់ហើយនិងមិនផ្លាស់ប្តូរដែលត្រូវអនុវត្តម្តងហើយ ទៀតក្នុងរយៈពេល ដ៏វែងមួយ ផ្ទុយទៅវិញ គឺវាមិនជាការអនុវត្តន៍ត្រឹមតែសកម្មភាពមួយចំនួនហើយ ចប់តែម្តងនោះទេ ។

២. ហេតុអ្វីបានជាចាំបាច់ត្រូវយកចិត្តទុកដាក់លើការងារត្រៀមបង្ការគ្រោះមហន្តរាយ?

- តាមពិតទៅប្រសិនបើគ្មានការត្រៀមលក្ខណៈជាមុនចំពោះព្រឹត្តិការណ៍គ្រោះមហន្តរាយទេនោះ ការខូចខាត និងផលប៉ះពាល់ផ្សេងៗ នឹងមានទំហំធំក្រៃលែង។ ការរៀបចំនិងអនុវត្តផែនការត្រៀមបង្ការ ដែលមានប្រសិទ្ធិភាពនឹងអាចកាត់បន្ថយនូវផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយ គ្រោះមហន្តរាយទៅលើមនុស្ស ផលិតផលផ្សេងៗ និងទ្រព្យសម្បត្តិ ផងដែរ។

- បទពិសោធន៍នៅក្នុងប្រទេសជាច្រើនបានបង្ហាញថាផលប្រយោជន៍នៃសកម្មភាពដែលបានធ្វើនៅមុនពេលមានមុខសញ្ញាគ្រោះថ្នាក់ ដូចជាការពារ ការកាត់បន្ថយការត្រៀមបង្ការនិងការអនុវត្តន៍ គំរោង គឺមានការចំណាយតិចតួចបំផុតបើប្រៀបធៀបជាមួយនិងការធ្វើការងារជួសជុល និងស្តារឡើងវិញនូវការខូចខាតជាក់ស្តែង ដែលបណ្តាលមកពីគ្រោះមហន្តរាយ។

- ថវិកា និងធនធានដែលចំណាយដោយរាជរដ្ឋាភិបាល រួមបញ្ចូលទាំងអង្គការអន្តរជាតិ និងអង្គការក្នុងស្រុក បានប្រើប្រាស់ទៅលើការជួសជុល និង ស្តារសាងសង់ឡើងវិញ ក្រោយការខូចខាត ដោយសារគ្រោះមហន្តរាយ គឺជាធនធានដែលគួរអាចប្រើប្រាស់សំរាប់ការអភិវឌ្ឍន៍ ដូចជា គំរោងការងារវិស័យកសិកម្ម ប្រព័ន្ធធារាសាស្ត្រ កសាងសាលារៀន សេវាកម្មសង្គម ហើយនិង តំរូវការចាំបាច់សំរាប់គំរោងអភិវឌ្ឍន៍ផ្សេងៗទៀត ។

- ការកើតមានឡើងនៃគ្រោះមហន្តរាយតែមួយគត់ក៏នឹងអាចធ្វើអោយមានការខូចខាតដល់ លទ្ធផល និងសកម្មភាពការងារជាច្រើនដែលបានអនុវត្តនិងកំពុងអនុវត្តក៏ដូចជាគំរោងផ្សេងៗ ទៀត ។ គំរោង ឬការងារដែលពាក់ពន្ធ័នឹងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ វិស័យកសិកម្ម និងគំរោងអភិវឌ្ឍន៍សង្គម ដែលត្រូវបានធ្វើរួចមកហើយ និង កំពុងបន្តរធ្វើនឹងត្រូវបញ្ចប់ទាំងស្រុង ប្រសិនបើមិន អនុវត្តវិធានការផ្សេងៗជាមុនដើម្បីត្រៀមខ្លួនឆ្លើយតបទៅ នឹងគ្រោះថ្នាក់ ដែលអាចឡើងដោយគ្រោះមហន្តរាយ។

- ដោយសារតែព្រឹត្តិការណ៍គ្រោះមហន្តរាយដ៏អាក្រក់បំផុតតែងប៉ះពាល់លើមនុស្ស ដែលភាគ ច្រើនគឺជាអ្នកក្រីក្រនោះ ស្ទើរតែគ្រប់វិធានការនិងសកម្មភាពផ្សេងៗនៃការងារត្រៀមបង្ការ គ្រោះមហន្តរាយ គឺ

ធ្វើឡើងដោយព្យាយាមបំពេញតំរូវការឱ្យក្រុមជនក្រីក្រទាំងអស់នៅ ក្នុងសហគមន៍ ។ ក្រុមអ្នកក្រីក្រទាំងនេះ គឺដូចគ្នាទៅនឹងក្រុមងាយរងគ្រោះដែលស្ថាប័នទទួល ខុសត្រូវបានសន្យាថានឹងជួយ ។



*តើគ្រោះមហន្តរាយធ្លាប់មានផលប៉ះពាល់លើសហគមន៍យើងយ៉ាងដូចម្ដេចខ្លះ?*
*តើអ្នកណាខ្លះដែលធ្លាប់រងគ្រោះ?តើយើងធ្លាប់បានដោះស្រាយដូចម្ដេច?*
*តើត្រូវធ្វើអ្វីទៀតដើម្បីត្រៀមបង្ការគ្រោះមហន្តរាយ?*

## ៣. អ្វីជាផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ?

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ជាវិធានការ ឬ សកម្មភាព សំរាប់អនុវត្តជាមុន ដើម្បីធ្វើអោយការឆ្លើយតបទៅនឹងគ្រោះទឹកជំនន់អនុវត្តបានទាន់ពេលវេលា និង មានប្រសិទ្ធិភាព។ ផែនការត្រៀមបង្ការគ្រោះទឹកជំនន់មានទិសដៅ និង តួនាទីដូចខាងក្រោម :

ក. ការប៉ាន់ប្រមាណធនធាន និង សមត្ថភាពនៅគ្រប់ថ្នាក់

ខ. រៀបចំនិតិវិធីប្រតិបត្តិ ដើម្បីដឹកនាំប្រតិបត្តិការជំនួយសង្គ្រោះ នៅពេលនិងក្រោយពេលមានគ្រោះមហន្តរាយ ។ **ឧទាហរណ៍** ដូចជាការផ្ដល់ពត៌មានជាមុនអោយទាន់ពេលវេលា ការជំលៀសប្រជាជន និង ទ្រព្យសម្បត្តិ ពីកន្លែងគ្រោះថ្នាក់ រៀបចំជំរកបណ្ដោះអាសន្ន ការស្តុកទុកជំនួយសង្គ្រោះ និង ការរៀបចំប្រព័ន្ធទំនាក់ទំនង នៅពេលមានគ្រោះមហន្តរាយ ។

## ៤. តើផែនការត្រៀមបង្ការគ្រោះទឹកជំនន់មានផលប្រយោជន៍អ្វីខ្លះ ?

**ឧបសម្ព័ន្ធទី ១**

ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ អាចជួយអោយមានការរៀបចំ និង កំនត់ធនធានសំរាប់ប្រើប្រាស់ក្នុងការកាត់បន្ថយផលប៉ះពាល់គ្រោះមហន្តរាយ។ ការរៀបចំផែនការបានល្អ អាចជួយយើងនៅក្នុងការងារមួយចំនួនដូចខាងក្រោម :

១. សហគមន៍ងាយរងគ្រោះអាចទទួលបានពតិមានបានទាន់ពេលវេលា ដូចជា ពតិមានព្យាករណ៍ និង ពតិមានប្រកាសភាពអាសន្នជាដើម ។

២. អាចផ្តល់អោយនូវសេចក្តីត្រូវការចាំបាច់ ដូចជា ជំរក ការថែទាំសុខភាព ទឹកស្អាត និង ម្ហូបអាហារនៅរដូវទឹកជំនន់ ។

៣. អាចកាត់បន្ថយផលប៉ះពាល់លើជីវភាពរស់នៅ។

៤. អាចស្តារឡើងវិញបានទាន់ពេលវេលា នូវផលប៉ះពាល់លើហេដ្ឋារចនាសម្ព័ន្ធ

៥. សហការបានល្អ និង មានប្រសិទ្ធិភាពក្នុងចំណោមអង្គការ និង ស្ថាប័ន្ធពាក់ព័ន្ធ ក្នុងការឆ្លើយតបនៅពេលមានគ្រោះមហន្តរាយ។

៦. អាចធ្វើអោយសហគមន៍វិលប្រឡប់ទៅរកស្ថានភាពដើមវិញបានយ៉ាងឆាប់រហ័ស ។

## ៥. ប្រសិទ្ធិភាពនៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់

ដើម្បីអនុវត្តផែនការត្រៀមបង្ការគ្រោះទឹកជំនន់អោយមានប្រសិទ្ធិភាព ត្រូវកំនត់បញ្ហាសំខាន់ ៗ និង ដំណោះស្រាយ របស់សហគមន៍ ដូចមានជាឧទាហរណ៍ខាងក្រោម :

| បញ្ហាសំខាន់ៗ | វិធានការត្រៀមបង្ការ | ធនធានត្រូវការ | ស្ថាប័នពាក់ព័ន្ធ |
|---|---|---|---|
| ទទួលពតិមានពីទឹកជំនន់ | រៀបចំការផ្សព្វផ្សាយអោយយល់ដឹងពីគ្រោះថ្នាក់នៃទឹកជំនន់ | ផ្ទាំងរូបភាពផ្សព្វផ្សាយ និង ពតិមាន ធ្វើយុទ្ធនាការផ្សព្វផ្សាយអោយបានញឹកញាប់ | ស្ថាប័នរដ្ឋាភិបាល អង្គការនានា |
| | ធ្វើការព្យាករណ៍ និង ផ្សព្វផ្សាយពតិមានអោយដល់ អាជ្ញាធរ និង អង្គការមនុស្សធម៌នានា។ | ប្រព័ន្ធព្យាករណ៍នៅឯមន្ទីរធនធានទឹក ពតិមានព្យាករណ៍ តំឡើងឧបករណ៍វាស់ស្ទង់ទឹក និង ក្តារខៀនផ្សព្វផ្សាយ ពតិមាន បែបធម្មតា | ស្ថាប័នរដ្ឋាភិបាល (មន្ទីរធនធានទឹក នៅថ្នាក់ជាតិ និង ខេត្ត អង្គការនានា |
| ការពារអាយុជីវិត និង ទ្រព្យសម្បត្តិ | ទំនាក់ទំនងជាមួយប្រភពនានា ដែលអាចផ្តល់ពតិមានពី ការព្យាករណ៍ពីទឹកជំនន់ ។ | | ស្ថាប័នរដ្ឋាភិបាល សហគមន៍ |
| | រៀបចំប្រព័ន្ធផ្សព្វផ្សាយនិង ផ្តល់ពតិមានជាមុន អោយបាន | វិទ្យុ ទូរទស្សន៍ ទូរស័ព្ទ និងឧបករណ៍ផ្សេងៗទៀត | គណៈកម្មាធិការគ្រប់គ្រងគ្រោះ មហន្តរាយ |

| | | | |
|---|---|---|---|
| | ទាន់ពេលវេលា ផ្អែកតាមការព្យាករណ៍។ | បណ្តាញអ្នកស្ម័គ្រចិត | អ្នកស្ម័គ្រចិត្ត |
| | អនុវត្តនូវវិធានការការពារគ្រោះទឹកជំនន់ (លើកធារផ្ទះ លើកទីកន្លែងដាក់សត្វ ទប់ទំនប់ និង ទុលផ្ទះ ដោយប្រើប្រាស់សំភារៈ ដែលអាចធន់នឹងទឹក។ | ការកំនត់តំបន់ងាយរងគ្រោះ<br>ឯកសារទាក់ទងនឹងវិធានការការពារគ្រោះទឹកជំនន់<br>បាវខ្សាច់ ......................... | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា<br>វិទ្យាស្ថានហិរញ្ញវត្ថុ |
| | ប្រើប្រាស់នូវវិធានការការពារទឹកជំនន់ផ្សេងទៀត........... | សំភារៈផ្សព្វផ្សាយ | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា |
| | ថែរក្សា និង ការពារហេដ្ឋារចនាសម្ព័ន្ធកាត់បន្ថយគ្រោះទឹកជំនន់ដែលមានស្រាប់ | ត្រួតពិនិត្យទំនប់ជាប្រចាំ............. | ស្ថាប័នរដ្ឋាភិបាល<br>សហគមន៍ |
| | កំណត់ក្រុមងាយរងគ្រោះ ដូចជា ក្រុមស្ត្រី និង កុមារ | ផែនទី | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា |
| | ធ្វើអោយប្រាកដថា សហគមន៍អាចយល់បានពីពត៌មាន ប្រកាសភាពអាសន្ន ហើយគេអាចឆ្លើយតបបានទាន់ពេល | មានប្រព័ន្ធរួចជាស្រេចដើម្បីផ្តល់ពត៌មានដល់សហគមន៍<br>ផ្សព្វផ្សាយជាប្រចាំដើម្បីធ្វើអោយ ប្រជាជនយល់ដឹងពីពត៌មានជាមុន | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា<br>សហគមន៍ |
| | រៀបចំប្រតិបត្តិការស្រាវជ្រាវ និង សង្គ្រោះ | ទូក ឧបករណ៍ទំនាក់ទំនង<br>រៀបចំក្រុមសង្គ្រោះជាមុន នៅតាមសហគមន៍ | ស្ថាប័នរដ្ឋាភិបាល<br>សហគមន៍ - អ្នកស្ម័គ្រចិត្ត និង សហគមន៍ |
| | ប្រតិបត្តិការជំលៀស និង ចល័តការស្រាវជ្រាវ និង សង្គ្រោះ | ស្រង់ពត៌មានជាបន្ទាន់ពីតំបន់ និង ប្រជាជនដែលទទួលការប៉ះពាល់ | ការវាយតំលៃរបស់ WFP |
| | សន្តិសុខគ្រួសារ និង ទ្រព្យសម្បត្តិ (ការពារចោរ........) | រៀបចំក្រុមទទួលខុសត្រូវការពារសន្តិសុខគ្រួសារ និង ទ្រព្យសម្បត្តិជាប្រចាំ ។ | សហគមន៍ |
| | កំនត់ទីកន្លែងដែលមានសុវត្ថិភាព | | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា |
| សេចក្តីត្រូវការសំរាប់ផ្គត់ផ្គង់ជាមូលដ្ឋាន នៅពេលទឹកជំនន់ | សំភារៈនិង ការដឹកជញ្ជូនទៅកាន់កន្លែងមាន សុវត្ថិភាព | ទូក ធនធានសារពើភណ្ឌ ផែនទី | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា<br>សហគមន៍ |
| | ផ្តល់អោយនូវអ្វីជាសេចក្តីត្រូវការជាមូលដ្ឋាន ដូចជា ទឹកស្អាត និង ម្ហូបអាហារ | រៀបចំអណ្តូងស្នប់ ប្រភពទឹកស្អាតនៅលើទួលសុវត្ថិភាព សំភារៈចំរោះទឹក និង ធ្វើការផ្សព្វផ្សាយ និង អប់រំពីការប្រើប្រាស់ទឹកស្អាត | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា<br>សហគមន៍ |
| | រៀបចំ និងគ្រប់គ្រងសំភារៈស្តុក និងម្ហូបអាហារ - ចំណីសត្វ និងជំនួយសង្គ្រោះ និងធានាថាអ្វីទាំងអស់អាចមាននៅរដូវទឹកជំនន់ | ឃ្លាំងនៅលើទីទួលសុវត្ថិភាព<br>ធនធានផ្សេង ៗ<br>ផែនទី | ស្ថាប័នរដ្ឋាភិបាល<br>សហគមន៍ |
| | ប៉ាន់ប្រមាណ និង វាយតំលៃជាបន្ទាន់តំបន់ និង ប្រជាជនដែលទទួលរងគ្រោះ | រៀបចំទុកជាមុននូវឯកសារសំរាប់ស្រង់ និង វាយតំលៃ សេចក្តីត្រូវការឯកសារវាយតំលៃ | ស្ថាប័នរដ្ឋាភិបាល<br>សហគមន៍ |

| | | | |
|---|---|---|---|
| | | សេចក្តីត្រូវការរបស់ WFP | |
| | កំនត់ប្រភពនានាដែលអាចប្រមូលបាននូវធនធានមនុស្ស សំភារៈ និង ថវិកាសំរាប់ជំនួយសង្គ្រោះ | ឈ្មោះរបស់អង្គការមនុស្សធម៌ និង ស្ថាប័នរដ្ឋាភិបាល<br>ប្រព័ន្ធទំនាក់ទំនង | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា<br>សហគមន៍ |
| | ធ្វើផែនការសំរាប់ស្វែងរកថវិកា | ផ្អែកតាមការប៉ាន់ប្រមាណសេចក្តីត្រូវការ | ស្ថាប័នរដ្ឋាភិបាល-<br>អង្គការនានា - សហគមន៍ |
| ផ្តល់អោយនូវជំរកបណ្តោះអាសន្ន | រៀបចំ និង ថែរក្សាទីទួលសុវត្ថិភាពមុនពេលគ្រោះទឹកជំនន់ | ផ្អែកតាមការប៉ាន់ប្រមាណសេចក្តីត្រូវការ | ស្ថាប័នរដ្ឋាភិបាល<br>សហគមន៍ |
| | ទៅមើលជំរកបណ្តោះអាសន្ន<br>យ៉ាងហោចណាស់ ៣ដង | ទូក ពតិមានអំពីផ្លូវទៅកាន់ជំរកបណ្តោះអាសន្ន<br>ក្តារពតិមានបង្ហាញពីទីតាំងថែរក្សាផ្លូវ | ស្ថាប័នរដ្ឋាភិបាល<br>សហគមន៍ |
| | រៀបចំ និង បែងចែកជំរកបណ្តោះអាសន្ន | ក្រណាតកៅស៊ូតង់<br>ជំនួយម្ហូបអាហារសំរាប់មនុស្ស និង សត្វ | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា |
| ផ្តល់នូវសេចក្តីត្រូវការថ្នាំពេទ្យ | ប្រើប្រាស់បរិក្ខាពេទ្យ | អាគារបណ្តោះអាសន្នសំរាប់គ្លីនិចនៅលើទីទួល<br>ក្រុមពេទ្យចល័តនៅពេលទឹកជំនន់ (ទូក និង ជំនួយថ្នាំពេទ្យ) | ស្ថាប័នរដ្ឋាភិបាល<br>ទទួលបន្ទុកផ្នែកសុខភាព<br>អង្គការនានា និង សហគមន៍ |
| | ចាត់វិធានការសមស្របដើម្បីការពារជំងឺផ្សេង ៗ | ធ្វើការផ្សព្វផ្សាយដើម្បីការពារជំងឺផ្សេង ៗ | ស្ថាប័នរដ្ឋាភិបាល<br>អង្គការផ្នែកសុខភាព<br>អង្គការនានា |
| ធ្វើអោយមានជីវភាពរស់នៅដូច ធម្មតា ដើម្បីកាត់បន្ថយ ផល ប៉ះពាល់ | ធ្វើការងារ រួមមានវិធានការការពារ និង កាត់បន្ថយ | លើកផ្លូវ<br>ធ្វើអោយមានទូក និង ................. | ស្ថាប័នរដ្ឋាភិបាល |
| | ធ្វើអោយមានឱកាសក្នុងការប្រកបរបរចិញ្ចឹមជីវិតដូចជាការដាំដំណាំលើទីទួលសុវត្ថិភាព | ការដាំដំណាំ និង ឧបករណ៍ផ្សេងទៀតសំរាប់ធ្វើដំណើរ | ស្ថាប័នរដ្ឋាភិបាល |
| កែសំរួលផែនការកម្មវិធីត្រៀមបង្ការ | ផ្អែកតាមបទពិសោធន៍កន្លងមក | | ស្ថាប័នរដ្ឋាភិបាល |
| ប្រើប្រាស់ពតិមាន | បង្កើនការយល់ដឹង | | ស្ថាប័នរដ្ឋាភិបាល |
| ស្តារ និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធខូចខាត | ប៉ាន់ប្រមាណ និង វាយតំលៃការប៉ះពាល់<br>ប្រមូលធនធានចាំបាច់ និង អនុវត្តសកម្មភាព ជួលជុល និង ស្តារឡើង វិញ | | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា<br>សហគមន៍ |
| ប៉ាន់ប្រមាណ និង វាយតំលៃ ពីការខូចខាត និង បាត់បង់ | វិធីសាស្រ្តវាយតំលៃ ECLAC | | ស្ថាប័នរដ្ឋាភិបាល<br>អង្គការនានា និង<br>សហគមន៍- អ្នកស្ម័គ្រចិត្ត |

## ៦. តើអ្នកណាជាអ្នកពាក់ព័ន្ធនៅក្នុងការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ?




តើសហគមន៍យើងត្រូវធ្វើអ្វីខ្លះនៅពេលខាងមុខ ដើម្បីត្រៀមបង្ការ ចំពោះគ្រោះមហន្តរាយ?

ការទទួលខុសត្រូវសំខាន់នៅក្នុងការរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់គឺក្រុមសហគមន៍អាជ្ញាធររដ្ឋាភិបាល ត្រូវបានគេគិតថា ជាអ្នកឆ្លើយតបទៅនឹងគ្រោះទឹកជំនន់។ ដូច្នេះ អាជ្ញាធរមូលដ្ឋានត្រូវទទួលខុសត្រូវលើការងារសំរបសំរួលទូទៅទាក់ទងនឹងការងារត្រៀមបង្ការគ្រោះទឹកជំនន់ដូចជាការសំរបសំរួលការពិភាក្សារវាងអង្គការ ឬ ស្ថាប័នដៃគូ ដើម្បីកំនត់តួនាទី និង ការទទួលខុសត្រូវ។ នៅពេលដែល មានការកំនត់តួនាទី និង ការទទួលខុសត្រូវច្បាស់លាស់ហើយ មានន័យថា នៅពេលអនុវត្តការងារ អង្គការនិមួយៗដែលមានភារកិច្ចអាចអនុវត្តការងារបានពិតប្រាកដ ។

រដ្ឋាភិបាលជាតិ និង ស្ថាប័ននានា ដោយមានការជួយជ្រោមជ្រែងពីអង្គការក្រៅរដ្ឋាភិបាល ជាអ្នកជួយសំរបសំរួល ការងាររៀបចំផែនការ ។ តួនាទី និង ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ ទាំងអស់ត្រូវចងក្រងជាឯកសារអោយបានច្បាស់លាស់នៅក្នុងផែនការ។ ដូច្នេះគេអាចត្រួតពិនិត្យ តួនាទីរបស់គេ ដើម្បីធានាអោយការអនុវត្តការងារបានទាន់ពេលវេលា ។ តារាងខាងក្រោមផ្តល់អោយ នូវសកម្មភាពនានា និង តួនាទីរបស់ស្ថាប័នពាក់ព័ន្ធនិមួយ ៗ :

| ឈ្មោះស្ថាប័នពាក់ព័ន្ធ | សកម្មភាពសំខាន់ ៗ |
|---|---|
| រដ្ឋាភិបាល និង ស្ថាប័ននានា | ■ រៀបចំគោលការណ៍នានា និង ចេញដីកា អនុក្រិត<br>■ ធ្វើការព្យាករណ៍ និង ផ្សព្វផ្សាយដល់អាជ្ញាធរ និង អង្គការមនុស្សធម៌នានា។ |
| គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ ខេត្ត និង ស្រុក | ■ ផ្សព្វផ្សាយពត៌មានប្រកាសភាពអាសន្ន ផ្អែកតាមការព្យាករណ៍<br>■ ត្រៀមស្រាវជ្រាវ និង សង្គ្រោះ<br>■ រៀបចំសំភារៈ និង មធ្យោបាយផ្សេងៗ ទៅកាន់ទីទួលសុវត្ថិភាព<br>■ កំនត់ រៀបចំ និង ថែរក្សាទីទួលសុវត្ថិភាព |

| | |
|---|---|
| | ■ ផ្តល់អោយនូវទឹកស្អាតនៅលើទីទួល<br>■ ត្រៀមដើម្បីផ្តល់អោយនូវជំរកបណ្តោះអាសន្ន ជំនួយសង្គ្រោះ និង សេវាកម្មសុខភាព<br>■ ប្រើប្រាស់ទំរង់សំរាប់ធ្វើការវាយតំលៃផលប៉ះពាល់ និង សេចក្តីត្រូវការ និង រាយការណ៍ជូនរដ្ឋាភិបាលដើម្បីសុំជំនួយ បន្ថែមនៅពេលត្រូវការ<br>■ កំនត់ប្រភព និង អង្គការមនុស្សធម៌ដែលគេអាចជួយជំនួយសង្គ្រោះ និង សហការជាមួយគេជាប្រចាំនៅមុនគ្រោះ ទឹកជំនន់<br>■ ចែង និង កំនត់អោយច្បាស់ពីតួនាទី និង ការទទួលខុសត្រូវរវាងស្ថាប័នរដ្ឋាភិបាល និង អង្គការមនុស្សធម៌នានា<br>■ ផ្អែកតាមតួនាទី ត្រូវរៀបចំផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ដោយសហការជាមួយអង្គការមនុស្សធម៌ ដូចជា កាកបាទក្រហម និង អង្គការនានាដើម្បីអនុវត្ត<br>■ កែសំរួលផែនការត្រៀមបង្ការក្រោយពេលទឹកជំនន់ និង មុនពេលទឹកជំនន់ ជាប្រចាំ |
| សហគមន៍ (រៀបចំជាក្រុម) | ■ ជំលៀសទៅកាន់ទីទួលសុវត្ថិភាព ផ្អែកតាមពត៌មានព្យាករណ៍<br>■ ការពារទ្រព្យសម្បត្តិគ្រួសារដោយទុកដាក់អោយខ្ពស់<br>■ ប្រើប្រាស់ទូកផ្ទាល់ខ្លួនដើម្បីសង្គ្រោះអ្នកដទៃ នៅពេលត្រូវការ<br>■ ចែករំលែកដល់សំភារៈស្តុកសំរាប់អាហារមនុស្ស និង សត្វ |
| អង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ និង អង្គការមនុស្សធម៌ | ■ ផ្តល់ជំនួយបច្ចេកទេសនៅក្នុងការព្យាករណ៍<br>■ ផ្តល់ជំនួយសំរាប់ដឹកជញ្ជូនទៅកាន់ទីទួលសុវត្ថិភាព<br>■ សំរបសំរួលនៅលើទីទួល ដូចជា ផ្គត់ផ្គង់ទឹកស្អាត ជំរកបណ្តោះអាសន្ន ថ្នាំពេទ្យ ម្ហូបអាហារ តាមការស្នើពីអាជ្ញាធររដ្ឋាភិបាល<br>■ ផ្តល់ជំនួយសង្គ្រោះតាមការស្នើសុំរបស់អាជ្ញាធរ<br>■ សំរបសំរួលការធ្វើផែនការ ។ |

## ចំណុចសំខាន់ ៗ ត្រូវពិចារណា

- ការបែងចែកតួនាទី និង ភារកិច្ចច្បាស់លាស់ វាធ្វើមិនអោយមានការអនុវត្តការងារជាន់គ្នា និង វាអាចធ្វើអោយមានយន្តការ និង មានសហប្រតិបត្តិការល្អរវាង :
    - o អង្គការដែលធ្វើការនៅតាមមូលដ្ឋាន
    - o ផែនការជាតិ និង ផែនការមូលដ្ឋាន
    - o ធ្វើអោយប្រព័ន្ធនៅមូលដ្ឋានមានជិតស្និទ្ធគ្នា

- រចនាសម្ព័ន្ធស្ថាប័ន នៅថ្នាក់ខេត្ត និង ស្រុកក្នុងការគ្រប់គ្រងគ្រោះមហន្តរាយនៅក្នុងប្រទេស កម្ពុជា និង វៀតណាម សមាជិកគណៈកម្មាធិការទាំងអស់ គួរអនុវត្តតួនាទីបន្ថែមទៀត ដោយ ចាត់តាំងបុគ្គលិក ឬ តំណាងរបស់ខ្លួនអោយជួយគណៈកម្មាធិការក្នុងការធ្វើការងារគ្រប់គ្រង គ្រោះមហន្តរាយ ។

- កែសំរួលជាបន្ទាន់ និង ម្តងទៀតក្រោយពីធ្វើការងារ ព្រោះក្រោយពីការធ្វើការងារសង្គ្រោះបន្ទាន់ វានឹងបានបង្ហាញពីអ្វីដែលត្រូវកែលំអ ។ ដូច្នេះផែនការក៏ត្រូវធ្វើការកែលំអប្រចាំឆ្នាំ ។

## ៧. ហេតុអ្វីយើងចាំបាច់ត្រូវអនុវត្តកម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍ ?

- អ្នកនៅក្នុងសហគមន៍ផ្ទាល់ជាអ្នករងគ្រោះខ្លាំងបំផុតហើយមានតែអ្នកនៅក្នុងសហគមន៍ទេដែលអាចស្គាល់បានយ៉ាងច្បាស់ពីគ្រោះថ្នាក់ដែលអាចកើតមានឡើងចំពោះគេ (គ្រោះថ្នាក់ទៅលើ ផ្នែករូបវន្ត សេដ្ឋកិច្ច និងសង្គម) និង អាចគ្រប់គ្រងវាបានប្រកបដោយប្រសិទ្ធិភាព។
- គ្មានអ្នកណា គេចាប់អារម្មណ៍ និង ទទួលខុសត្រូវលើការស្វែងយល់ពីសហគមន៍ និង អភិវឌ្ឍន៍ កិច្ចការ និង ស្ថានភាពសហគមន៍ ជាជាងសហគមន៍ខ្លួនឯងផ្ទាល់នោះទេ។
- អ្នកដែលអាចធ្វើការឆ្លើយតបនឹងគ្រោះមហន្តរាយបានមុនគេបង្អស់ និង លឿនជាងគេបំផុត នោះគឺជាមនុស្សដែលចេញពីសហគមន៍ ខ្លួនឯងគេផ្ទាល់ដើម្បីជួយដល់សហគមន៍គេផ្ទាល់។
- ដើម្បីសំរេចបាននូវការផ្តួចផ្តើមគំនិតចំពោះវិធានការផ្សេងៗ សំដៅកាត់បន្ថយគ្រោះថ្នាក់ដោយគ្រោះមហន្តរាយ ឱ្យមានប្រសិទ្ធិភាពនោះការប្រមូលនិងវិភាគពតិមានដែលពាក់ពន្ធ័នឹងមុខសញ្ញាគ្រោះថ្នាក់ និង ស្ថានភាពគ្រោះមហន្តរាយ គួរធ្វើឡើងតាមបែបផែនមួយ និងប្រើប្រាស់ភាសាមួយ ដែលសហគមន៍ខ្លួនឯងងាយយល់បាន ។
- ត្រូវតែគិតគូរដល់ធនធានដែលមានស្រាប់ និងតំរូវការចាំបាច់របស់សហគមន៍ ព្រោះថាគេត្រូវ តែចូលរួមនៅគ្រប់ជំហ៊ានទាំងអស់ក្នុងសកម្មភាពត្រៀមបង្ការគ្រោះមហន្តរាយ។ ធ្វើបែបនេះគេប្រហែលជានឹងកំនត់បាននូវវិធានការដែលសមស្របដើម្បីឆ្លើយតបទៅនឹងបញ្ហា និងតំរូវការ របស់សហគមន៍ផ្ទាល់។
- មនុស្សគឺជាធនធានដ៏សំបូរ និងមានតំលៃសំរាប់ការងារអភិវឌ្ឍ ដែលយើងគួរតែប្រើប្រាស់ និងពង្រឹង។

## ៨. ដំណើរការអនុវត្តន៍កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍

### ក. តើត្រូវធ្វើយ៉ាងណាដើម្បីអោយសហគមន៍មួយអាចក្លាយទៅជាសហគមន៍ ដែលអាចត្រៀមខ្លួនរួចជាស្រេច ចំពោះព្រឹត្តិការណ៍គ្រោះមហន្តរាយដែលកើតឡើង?

ពីរ-បីឆ្នាំកន្លងមកនេះ ប្រទេសកម្ពុជាយើងទទួលរងគ្រោះដោយគ្រោះមហន្តរាយជាបន្តបន្ទាប់។ រាជរដ្ឋាភិបាល ចំណាយថវិកាអស់ជាច្រើនលានទៅលើការជួសជុលឡើងវិញ និង ជំនួសនូវហេដ្ឋារចនា សម្ព័ន្ធដែលទទួល

រងការខូចខាត និងផ្តល់នូវជំនួយសង្គ្រោះ ។ គ្រួសារជាច្រើនត្រូវបានចាកចេញជាបន្ទាន់ រឺត្រូវជំលៀសចេញពីផ្ទះ រយៈពេលយូរ ឬ ទៅសាងសង់ទីលំនៅថ្មី ក្រោយពីទឹកជំនន់នៅឆ្នាំ២០០០ ដែលជាហេតុនាំ ឱ្យមានការរំខាន ដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគេ ។ បញ្ហានេះបានបង្កើននូវការស្មុគស្មាញដល់ពួកគេ ។ ពុំមានខេត្ត-ក្រុង ស្រុក-ឃុំ និង ភូមិណាមួយ ដែលមិនទទួលរងគ្រោះនោះទេ ។

ទោះបីនេះហាក់ដូចជាទិដ្ឋភាពមិនល្អយ៉ាងណាក៏ដោយ តែមានដំណោះស្រាយជាច្រើនដែលអាច ធ្វើបាន ដោយមន្ត្រីមូលដ្ឋាន និងអ្នកដែលមានទីលំនៅអចិន្ត្រៃយ៍នៅសហគមន៍ក្នុងការរៀបចំធ្វើផែនការ ទប់ទល់ នឹងគ្រោះមហន្តរាយសំដៅកាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់ដោយគ្រោះមហន្តរាយ ការពារនូវ សុវត្ថិភាពរបស់សហគមន៍ ហើយនិងអ្នកដែលរស់នៅទីនោះ។ ចំនុចគន្លឹះដើម្បីធ្វើការងារនេះគឺវាទាក់ ទងនឹងបញ្ហា ***<u>ត្រូវធ្វើនៅពេលណា?</u>*** ។ វាជាការប្រសើរបំផុតដែលស្ថាប័ន និង អង្គការទទួល ខុសត្រូវត្រូវចំណាយកំលាំង និង ប្រើប្រាស់ធនធាន ដើម្បីធ្វើការងារត្រៀមបង្ការគ្រោះមហន្តរាយ ***<u>នៅមុនពេល</u>*** មានមុខសញ្ញសគ្រោះថ្នាក់កើត ឡើងប្រសើជាជាង ប្រមូលធនធាន និង កំលាំង ដើម្បីជួយដល់សហគមន៍ដោះស្រាយ និង រៀបចំឡើងវិញនូវរាល់ការខូចខាត ក្រោយព្រឹត្តិការណ៍គ្រោះមហន្តរាយ កើតឡើង ។

ក្នុងការអនុវត្តកម្មវិធី ត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍ យើងត្រូវអនុវត្តនូវ សកម្មភាព រឺ វិធានការ មួយចំនួនខាងក្រោម ដែលជាគន្លឹះឆ្ពោះទៅរកការរៀបចំសហគមន៍របស់យើងឱ្យ មានសមត្ថភាពត្រៀមខ្លួនរួចជាស្រេចចំពោះរាល់ព្រឹត្តិការណ៍គ្រោះមហន្តរាយដែលអាចកើតមាន ។

១. រៀបចំអណត្តិច្បាស់លាស់សំរាប់កម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយនៅតាមសហគមន៍ ដោយសំរបសំរួលឱ្យមានកិច្ចព្រមព្រៀង ជាមួយថ្នាក់ខេត្ត ដល់ថ្នាក់ភូមិ និង បណ្តាភ្នាក់ងារ រឺក្រុម ផ្សេងៗទៀតដែលពាក់ពន្ធ័។

២. ត្រូវផ្តល់ការបណ្តុះបណ្តាលបង្កើនចំណេះដឹងជាមូលដ្ឋានដល់មន្ត្រីអាជ្ញាធរមូលដ្ឋាន និង ក្រុម ផ្សេងៗទៀត ក្នុងសហគមន៍ និង បុគ្គលផងដែរ។

៣. បង្កើតប្រពន្ធ័នៃការយល់ដឹងជាសាធារណៈដល់ក្រុមពាក់ពន្ធ័ទាំងអស់នៅក្នុងសហគមន៍ ដើម្បី ឱ្យបានដឹងពីការត្រៀមបង្ការគ្រោះមហន្តរាយ និងមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាន ដោយខ្លួនគេ។

៤. សហគមន៍ត្រូវប្រមូលរាល់ប្រមូលពិតមានទាំងអស់ដែលទាក់ទងនឹងបញ្ហាគ្រោះមហន្តរាយ ក្នុងសហគមន៍ ដោយប្រើប្រាស់មធ្យោយ វាយតំលៃនៅជនបទតាមបែបចូលរួម **(PRA)**។

៥. កំនត់ ប្រភេទមុខសញ្ញាគ្រោះថ្នាក់ដែលវាអាចនឹងកើតមាននៅក្នុងសហគមន៍។

៦. ប្រមូលពត៌មានដែលពាក់ពន្ធ័នឹងភាពងាយរងគ្រោះ និង សមត្ថភាពដែលមាននៅសហគមន៍ ។

៧. តាមរយៈការវិភាគ ទិន្នន័យ និង ពត៌មានដែលប្រមូលបាន ត្រូវដាក់ចេញនូវវិធានការ រឺ សកម្មភាពទាំងឡាយដែលសមស្របដើម្បីត្រៀមបង្ការ និង កាត់បន្ថយមុខសញ្ញាគ្រោះថ្នាក់ ធ្វើយ៉ាងណាបង្កើតនូវសហគមន៍មួយ ដែលបានត្រៀមបង្ការរួចជាស្រេចចំពោះមុខសញ្ញា គ្រោះថ្នាក់ដែលអាចកើតឡើងនៅពេលណាមួយ ។

៨. រៀបចំផែនការសហគមន៍ដើម្បីត្រៀមបង្ការគ្រោះមហន្តរាយ ដោយដាក់បញ្ចូលនូវរាល់បណ្តាវិធានការសមស្របទាំងឡាយដែលបានកំនត់ខាងលើនេះ ។

៩. ស្វែងរកការគាំទ្រដល់ដំណើរការធ្វើសមាហរណកម្មផែនការសកម្មភាពរបស់សហគមន៍ទៅនឹង ផែនការអភិវឌ្ឍន៍រយៈពេលវែងនៅថ្នាក់ឃុំ ។

១០. កំនត់នូវអាទិភាពចំពោះវិធានការ រឺ គំរោងដំណោះស្រាយទាំងឡាយ ថាតើត្រូវអនុវត្ត គំរោងណាខ្លះមុនគេ និង បន្តបន្ទាប់ ។

១១. រៀបចំក្រុមការងារក្នុងសហគមន៍ដើម្បីទទួលខុសត្រូវលើការអនុវត្តវិធានការនិមួយៗ ក្នុងផែនការ

១២. សំរបសំរួលជាមួយនឹងក្រុមពាក់ពន្ធ័ទាំងក្នុងនិងក្រៅសហគមន៍ទាំងអស់ដើម្បីស្វែងរកធនធានមកប្រើប្រាស់សំរាប់អនុវត្តផែនការសកម្មភាពសហគមន៍ដើម្បីត្រៀមបង្ការគ្រោះមហន្តរាយ ។

១៣. ត្រួតពិនិត្យការអនុវត្តន៏ នៃសកម្មភាពទាំងអស់ និងគំរោងនានា ។

១៤. ធ្វើការវាយតំលៃប្រចាំឆ្នាំ និង រំលឹកឡើងវិញពីសកម្មភាព និង គំរោងដែលបានធ្វើរួច និង កែសំរួលផែនការសកម្មភាពធ្វើយ៉ាងណាអោយវាអាចសមស្របនឹងស្ថានការណ៏គ្រោះមហន្តរាយ

# ផ្នែកទី ៦
# វិធានការគន្លឹះ សំរាប់ការទារត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យទឹកជំនន់តាមសហគមន៍

# មេរៀនទី ៦.១: ប្រព័ន្ធផ្តល់ព័ត៌មានជាមុនពីគ្រោះទឹកជំនន់នៅតាមសហគមន៍

## ១. និយមន័យ

ប្រព័ន្ធផ្តល់ពត៌មាន ជាការប្រាប់អោយដឹងមុនទៅដល់ប្រជាពលរដ្ឋដែលស្ថិតនៅ ក្រោមការគំរាម កំហែងដោយគ្រោះមហន្តរាយ ដែលអាចកើតឡើង (ក្នុងករណីនេះគឺសំដៅទៅលើការបំផ្លិចបំផ្លាញ និង ការខូចខាតដោយទឹកជំនន់) ដែលអាចកើតមាននៅក្នុងពេលខាងមុខហើយប្រព័ន្ធនេះក៏អាចផ្តល់ជាចំណុច ចាប់ផ្តើមសំរាប់បុគ្គល និង ក្រុមមនុស្សក្នុងការធ្វើសេចក្តីសំរេចចិត្តសំរាប់អនុវត្តវិធានការការពារ និង កាត់បន្ថយគ្រោះថ្នាក់ និង ផលប៉ះពាល់បានទាន់ពេលវេលា និង មានប្រសិទ្ធិភាពបាន។

វាជាសារ សំរាប់ផ្តល់ពត៌មានអំពីគ្រោះថ្នាក់នៃគ្រោះទឹកជំនន់ដែលអាចកើតឡើង ឧទាហរណ៍ នៅពេលដែលកំរិតទឹកជំនន់ឡើងដល់ ឬ ខ្ពស់ជាងកំរិតដែលគេបានកំនត់សំរាប់ធ្វើការផ្តល់ពត៌មានជាមុន ឬ ប្រកាសភាពអាសន្ន។

ផលប្រយោជន៍សំខាន់នៅក្នុងការរៀបចំប្រព័ន្ធផ្តល់ពត៌មានដល់ថ្នាក់មូលដ្ឋាន គឺដើម្បីប្រាប់អោយ ដឹងជាមុនដល់សហគមន៍ដែលរស់នៅក្នុងតំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់ និង ដើម្បីអនុវត្តនូវ វិធានការណ៍ ឬ សកម្មភាពសមស្របដើម្បីកាត់បន្ថយផលប៉ះពាល់ និង ការខាតបង់អោយ មានកំរិតអប្បរមា។

នៅក្នុងអាងទន្លេមេគង្គប៉ែកខាងក្រោម, ពត៌មានការព្យាករណ៍កំពស់ទឹកជំនន់តែងតែចេញផ្សាយ ដោយមជ្ឈមណ្ឌលឧតុនិយមជាតិ ។ នៅក្នុងប្រទេសកម្ពុជា, នាយកដ្ឋានជលសាស្ត្រ និង ការងារទន្លេ របស់ក្រសួងធនធានទឹក និង ឧតុនិយម ជាអ្នកផលិត និង ចេញផ្សាយពតិមានព្យាករណ៍ និង ពតិមាន ប្រកាសភាពអាសន្នតាមរយៈព្រឹត្តិប័ត្រទឹកជំនន់ប្រចាំថ្ងៃ ដល់ស្ថាបប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ច និង អង្គការពាក់ព័ន្ធនានា ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយបន្តដល់សហគមន៍ដែលប្រឈមមុខ ។ លើសពីនេះ នៅរដូវទឹកជំនន់ ពតិមានព្យាករណ៍ពីកំពស់ទឹកជំនន់ត្រូវបានផ្សព្វផ្សាយតាមបណ្តាញផ្សព្វ ផ្សាយពតិមានដូចជា ផ្សាយតាមទូរទស្សន៍ជាតិ និង បណ្តាញទូរទស្សន៍ឯកជនប្រចាំថ្ងៃ ចុះផ្សាយ តាមសារពតិមានជាតិប្រចាំថ្ងៃ និង ផ្សាយតាមវិទ្យុផ្សាយសំលេងជាតិ និង ឯកជននៅថ្នាក់ជាតិ និងថ្នាក់ខេត្តក្រុង។

ដូច្នេះការព្យាករណ៍នេះ មានសារះសំខាន់ណាស់រាប់សហគមន៍ដែលរស់នៅតាមតំបន់ទឹកជំនន់នៃ ដងទន្លេ ដើម្បីអាចអោយពួកគេត្រួតពិនិត្យពតិមានព្យាករណ៍អំពីទឹកជំនន់បានទៀងទាត់នៅរដូវ ទឹកជំនន់។

## ២. បណ្តាញជាតិសំរាប់ព្យាករណ៍ និង ផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់

នៅក្នុងប្រទេសកម្ពុជា ការបញ្ជូន និង ការផ្តល់ពត៌មានព្យាករណ៍ពីកំពស់ទឹកឆ្លងកាត់ក៏រិតដូចខាងក្រោម:



## ៣. ដំណាក់កាលនៃការព្យាករណ៍ និង ការផ្តល់ពត៌មានជាមុន









## ➢ សញ្ញាសំគាល់សំរាប់ផ្តល់ពត៌មានជាមុន

| | សញ្ញាសំគាល់កំរិតទឹកជំនន់បង្កើតឡើងដោយ<br>**Action Against Hunger, Cambodia** |
|---|---|
| **ស្ថានភាពធម្មតា ( All Clear )**<br>ជាដំណាក់កាលឃ្លាំមើលស្ថានភាពធម្មតា |  |
| **ការផ្តល់ពត៌មានជាមុន ឬ ប្រកាសភាពអាសន្ន**<br>ជាដំណាក់កាលដែលទឹកជំនន់អាចនឹងបង្កការប៉ះពាល់ដល់ គេហដ្ឋាន សត្វពាហនៈ និង ផ្លូវ......និង ដំណាក់កាលចាត់វិធានការណ៍ឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែង ។ |  |
| **ការផ្តល់ពត៌មានពីភាពធ្ងន់ធ្ងរពីទឹកជំនន់**<br>ជាដំណាក់កាលដែលទឹកជំនន់អាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ អាយុជីវិតមនុស្ស សត្វ និង ទ្រព្យសម្បត្តិ ។ |  |

## ៣. កម្មវិធីផ្តល់ពត៌មានជាមុនពីទឹកជំនន់តាមសហគមន៍

### ក. គំរោងផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់អនុវត្តដោយគណៈកម្មការទន្លេមេគង្គ

ចាប់តាំងពីឆ្នាំ ២០០៣ មក គណៈកម្មការទន្លេមេគង្គ (MRC) បានសហការជាមួយកាកបាទក្រហមកម្ពុជា (CRC) និង កាកបាទក្រហមអាមេរិចកាំង (ARC) ។ អង្គភាពដៃគូទាំង ៣ នេះ បានចាប់ផ្តើមអនុវត្តគំរោងប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់ជាលើកតំបូងនៅក្នុងប្រទេសកម្ពុជា ដោយមានជំនួយឧបត្ថម្ភថវិកាពីការិយាល័យជំនួយសង្គ្រោះរបស់បរទេសសហរដ្ឋអាមេរិក (OFDA) ។ ដោយសារគំរោងនេះ ជាគំរោងដ៏ធំមួយនៅកម្ពុជា ដែលបានគ្របដណ្តប់បានសហគមន៏គោលដៅងាយរងគ្រោះបានចំនួយដល់ទៅ ៤០ ភូមិ នៅក្នុងខេត្តគោលដៅចំនួន ៥ តាមបណ្តោយដងទន្លេមេគង្គ និង ដៃរបស់វា ក្នុងនោះរួមមាន ខេត្តស្ទឹងត្រែង កំពង់ចាម ក្រចេះ កណ្តាល និង ព្រៃវែង ។

ប្រព័ន្ធផ្តល់ពតិមានបែបនេះ បានរៀបចំប្រព័ន្ធផ្សព្វផ្សាយពតិមានព្យាករណ៏ពីកំពស់ទឹកស្តង់ដាមួយ ដែលមានសារៈសំខាន់ និង ងាយយល់បាន ដែលទទួលពតិមាននេះពីតាមភូមិក្នុងតំបន់លិចទឹកជំនន់ ។ សហគមន៏

នៅតាមតំបន់ប្រឈមមុខនឹងគ្រោះទឹកជំនន់អាចឆ្លើយតបបានយ៉ាងល្អទៅនឹងពត៌មានព្យាករណ៍ ដែលផលិតដោយដោយនាយកដ្ឋានជលសាស្ត្រ និង ការងារទន្លេ (DHRW) ដោយបានការគាំទ្រពីគណៈកម្មការទន្លេមេគង្គ (MRC) ។

ប្រព័ន្ធទំនាក់ទំនងមានដូចជា បង្គោលម៉ែត្រស្ទង់ទឹកដែលបានតំលើងនៅតាមភូមិគោលដៅ និង ក្តារខៀនពត៌មានកំពស់ទឹក ។ វិទ្យុទាក់ទងឬអាយកូម ត្រូវបានផ្តល់អោយដល់មូលដ្ឋានស្រុក និង បានផ្តល់ម៉ាស៊ីនហ្វាក់ទូរស័ព្ទ និង ប្រព័ន្ធអ៊ីនធឺណែតដល់ស្ថាប័នអ្នកអនុវត្តនៅថ្នាក់ខេត្ត និង ថ្នាក់ជាតិ ។

បានរៀបចំអោយមានផែនទីភូមិ ដែលគូរដោយដៃ ដែលមានលក្ខណៈងាយយល់របស់អ្នកភូមិ ដោយមានបង្ហាញពី ផ្លូវគមនាគមន៍ និង ទីតាំងទីទួលសុវត្ថិភាពជាដើម ។

លើក្តារខៀនពត៌មានកំពស់ទឹក មានបង្ហាញពី សញ្ញាក៏រិតប្រកាសអោយដឹងជាមុន ដោយមានប្រើប្រាស់ពណ៌ផ្សេងៗគ្នា ដូចជា ពណ៌ក្រហម "*ប្រាប់ស្ថានភាពទឹកជំនន់ក្នុងដំណាក់កាលធ្ងន់ធ្ងរ* ", ពណ៌លឿង "*ប្រាប់ពីស្ថានភាពទឹកជំនន់ក្នុងដំណាក់កាលប្រកាសអាសន្ន* " និង ពណ៌ខៀវ បង្ហាញពី "*ទឹកជំនន់មានស្ថានភាពធម្មតា* " និងមានក៏រិតទឹកជំនន់ប្រចាំ ថ្ងៃពីស្ថានីយ៍ និង ពីបង្គោលម៉ែត្រតាមភូមិផងដែរ ។

អ្នកស្ម័គ្រចិត្តកាកបាទក្រហម (RCVs) មានភារកិច្ចថែទាំក្តារពត៌មាន ហើយធ្វើការជាមួយសហគមន៍មូលដ្ឋាន ក្នុងកាផ្សព្វផ្សាយពត៌មានទឹកជំនន់ដ៏សំខាន់នេះដល់សហគមន៍រៀងរាល់ថ្ងៃ ។

- **មេរៀនបទពិសោធន៍ ដែលទទួលបានពីការអនុវត្តន៍**

មានមេរៀនបទពិសោធន៍ជាច្រើនដែលទទួលបានពីគំរោងតំបូងនេះ ។ អ្នកភូមិមានក៏រិតចំនេះដឹងទាបដែលធ្វើអោយមានឧបសគ្គទៅដល់ដំណើរការផ្សព្វផ្សាយពត៌មានកំពស់ទឹកជំនន់នៅក្នុងសហគមន៍ ។ ដូច្នេះ ត្រូវគិតគូរពីវិធីសាស្ត្រក្នុងការទំនាក់ទំនងជាមួយអ្នកភូមិដែលមានចំនេះដឹងទាប ។

ការផ្សាយពត៌មាន ក៏ជាឧបសគ្គមួយទៀត ដោយការខ្វះហេដ្ឋារចនាសម្ព័ន្ធនៅតាមសហគមន៍ជនបទ ។ចំពោះអ្នកដែលរស់នៅក្បែរក្តារខៀនពត៌មាន អាចទទួលបានពត៌មានការព្យាករណ៍ទឹកជំនន់ ។ ទោះជាយ៉ាងណាក៏ដោយការផ្សព្វផ្សាយពត៌មាននេះ ទៅដល់សហគមន៍ដាច់ស្រយាល មានការរអាក់រអួល ដោយសារខ្វះផ្លូវធ្វើដំណើរ និងមធ្យោបាយធ្វើដំណើរ ឧ. ទូក ជាដើម ។ អ្នកស្ម័គ្រចិត្តកាកបាទក្រហម (RCVs) តែងចុះទៅពិនិត្យមើលតាមផ្ទះដែលនៅក្នុងភូមិដាច់ស្រយាល ដោយសារគេមិនអាចមកមើលពត៌មានលើក្តារពត៌មានដែលបានតំលើងនោះបាន ។ មេក្រូ បានប្រើដើម្បីផ្សព្វផ្សាយពត៌មានកំពស់ទឹក ។ លើសពីនេះ វិទ្យុទាក់ទង ឬអាយកូមតែងតែដាច់ប៉ុស្តិ៍ ឬគ្មានសេវាពេលមានខ្យល់ និង ភ្លៀងខ្លាំង ។

ខណៈដែល គំរោងផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ (EWS) បានធ្វើការ ដើម្បីពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្នុងការរៀបចំប្រព័ន្ធទំនាក់ទំនង និង ប្រព័ន្ធផ្សព្វផ្សាយពត៌មានព្យាករណ៍ទឹកជំនន់ដែលមានប្រសិទ្ធភាព ដូច្នេះក្នុងជំហានបន្តបន្ទាប់នៃគំរោងនេះ មានបំណងធ្វើការយ៉ាងជិតស្និទ្ធិជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ ដើម្បីបន្តពង្រឹងសមត្ថភាពដល់ថ្នាក់ឃុំទៀត ។ ការប្រើប្រាស់អ្នកស្ម័គ្រចិត្តកាកបាទក្រហម ដើម្បីអនុវត្តគំរោងនេះ មិនសូវមាននិរន្តរភាពរឹងមាំទេ ដោយសារគេអាចធ្វើការបានយ៉ាងល្អនៅពេលដែលមានគំរោងពីបណ្តាអង្គភាពដៃគូនានា តែនៅពេលគំរោងនេះ ដកចេញបណ្តាញនេះមិនសូវមានភាពសកម្មក្នុងការអនុវត្តការងារនេះ ។

## ខ. គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់របស់អង្គការប្រឆាំងគ្រោះអត់ឃ្លាន (ACF)

ដោយបានការឧបត្ថម្ភថវិកាពី ការិយាល័យត្រៀមបង្ការគ្រោះមហន្តរាយរបស់ជំនួយមនុស្សធម៌សហគមន៍អឺរ៉ុប (DIPECHO) គណៈកម្មការទន្លេមេគង្គ (MRC) បានសហការជាមួយនឹងអង្គការប្រឆាំងគ្រោះអត់ឃ្លាន ក្នុងសកម្មភាពដូចគ្នានឹងគំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់របស់កាកបាទក្រហមកម្ពុជា និង កាកបាទក្រហមអាមេរិកាំងខាងលើ ។ គំរោងនេះ បានអនុវត្តនៅក្នុងភូមិគោលដៅចំនួន ៩ ក្នុងខេត្តកំពង់ចាម ។ គំរោងនេះ មិនផ្តោតសំខាន់តែទៅលើប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ប៉ុណ្ណោះទេ តែគំរោងនេះ បានអនុវត្តដោយផ្ទាល់ជាមួយក្រុមគ្រប់គ្រងគ្រោះមហន្តរាយឃុំ លើការងារត្រៀមបង្ការគ្រោះទឹកជំនន់ផងដែរ ។ គំរោងរបស់អង្គការ ACF ទាក់ទងនឹងប្រព័ន្ធផ្តល់ពត៌មានជាមុន មានលក្ខណៈខុសគ្នាពីគំរោងរបស់កាកបាទក្រហមកម្ពុជា និង កាកបាទក្រហមអាមេរិកាំងត្រង់ថា គំរោងនេះ ធ្វើការយ៉ាងជិតស្និទ្ធិជាមួយនឹងអាជ្ញាធរខេត្ត ស្រុក ព្រមទាំងជាមួយ RCV និង អ្នកដឹកនាំសហគមន៍ ក្នុងការរៀបចំកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ ។ ការចូលរួមរបស់មូលដ្ឋាននៅក្នុងគំរោងនេះ បានជួយបង្កើតនូវមូលដ្ឋានគ្រឹះ នៅក្នុងភាពជាម្ចាស់ការ និង និរន្តរភាពរបស់សហគមន៍យូរអង្វែង ។

ដោយការប្រើប្រាស់ប្រព័ន្ធដូចគ្នានឹង ប្រព័ន្ធក្រោមគំរោងរបស់ ARC និង CRC, គំរោងរបស់អង្គការ ACF នេះ មានការផ្តល់ពត៌មានជាមុនដល់អ្នកភូមិតាមរយៈការប្រើប្រាស់ក្តារពត៌មាន បង្គោលម៉ែត្រស្ទង់ទឹក និង មេក្រូសំរាប់ការផ្សាយពត៌មានពីភាពអាសន្ន និង មានការកិច្ចសហការដោយផ្ទាល់ជាមួយនឹងមន្ទីរពត៌មានខេត្តកំពង់ចាម ដើម្បីជួយផ្សព្វផ្សាយពត៌មានតាមប្រព័ន្ធផ្សព្វផ្សាយវិទ្យុFM នេះជាវិធីសាស្ត្រប្រសិទ្ធភាពមួយ សំរាប់ការផ្សាយពត៌មាន ដល់ប្រជាជន ។

អ្នកភូមិមួយចំនួន បានបង្កើតបង្គោលម៉ែត្រស្ទង់ទឹកដោយខ្លួនដោយគេ នៅតាមផ្ទះ ។ គេធ្វើដូចនេះ មានភាពងាយស្រួល ដោយមិនចាំបាច់ធ្វើដំណើរទៅមើលកំរិតកំពស់ទឹកនៅកន្លែងណាដែលមានបង្គោល ។ ទាំងនេះជាផលប្រយោជន៍ ដែលបង្គោលម៉ែត្រស្ទង់ទឹកនេះបានត្រូវធ្វើបន្តគ្នានៅតំបន់ដាច់ស្រយាលជាច្រើន ។

- **មេរៀនបទពិសោធន ដែលទទួលបានពីការអនុវត្តន៍**

គំរោង **ACF** នេះក៏បានជួបប្រទះនូវផលលំបាកជាច្រើនដែរ ដូចជាកំរិតនៃការយល់ដឹងរបស់សហគមន៍មូលដ្ឋានមានកំរិតទាប ឧទាហរណ៍ មានការកត់ត្រាកំពស់ទឹកមិនបានត្រឹមត្រូវពីបង្គោលម៉ែត្រស្ទង់ទឹក ដែលជាហេតុធ្វើអោយការរៀបចំពត៌មានសំរាប់ព្យាករណ៍មិនត្រឹមត្រូវ និង ធ្វើអោយមានបាត់ទំនុកចិត្តរបស់អ្នកភូមិលើគំរោងប្រព័ន្ធផ្តល់ពត៌មានទឹកជំនន់នេះ ។

### គ. គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់ របស់អង្គការអុកស្វាមអង់គ្លេស (OGB)

ប្រព័ន្ធផ្តល់ពត៌មានទឹកជំនន់ជាមុននេះ ឧបត្ថម្ភដោយអង្គការអុកស្វាមអង់គ្លេស **(Oxfam-GB)** ចាប់ពីឆ្នាំ ២០០៣ ដល់ ២០០៥ ។ គំរោងនេះ បានអនុវត្តនៅក្នុង ១៣ ភូមិនៅក្នុងស្រុកចំនួន ៣ របស់ខេត្តតាកែវ ។ គំរោងនេះផងដែរ បានយកតាមរបៀងនៃគំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនរបស់គណៈកម្មការទន្លេមេគង្គ**MRC** ដូចជា មានដាក់បង្គោលម៉ែត្រស្ទង់ទឹក និង ក្តារខៀនពត៌មានជាដើម ។ ក្នុងគោលបំណងដើម្បីផ្សព្វផ្សាយពត៌មានព្យាករណ៍ ដល់សហគមន៍ពីការត្រៀមបង្ការនឹងទឹកជំនន់ ។

- **មេរៀនបទពិសោធន៍ ដែលទទួលបានពីការអនុវត្តន៍**

ការផ្សព្វផ្សាយពត៌មានដល់ភូមិដែលនៅឆ្ងាយពីកន្លែងដាក់បង្គោលម៉ែត្រស្ទង់ទឹកជាបញ្ហាលំបាក និង ត្រូវយកចិត្តទុកដាក់ ។

### ឃ. ការធ្វើអោយប្រសើរឡើងនូវប្រព័ន្ធផ្តល់ពត៌មានជាមុនពីទឹកជំនន់នៅថ្នាក់សហគមន៍

***(នៅក្រោមគំរោងពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់)***

គំរោងប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ មានសារៈសំខាន់នៅក្នុងការកាត់បន្ថយគ្រោះមហន្តរាយទឹកជំនន់ នៅក្នុងប្រទេសកម្ពុជា ។ ដូច្នេះហើយ បានជាមានការបន្តរបៀបត្រៀមបង្ការគ្រោះទឹកជំនន់ ដោយប្រើប្រាស់ប្រព័ន្ធប្រភេទនេះនៅថ្នាក់ឃុំ។ ការកសាងសមត្ថភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់មូលដ្ឋាន ជាវិធីសាស្ត្រសមស្របដែលអាចជួយបង្កើននូវភាពម្ចាស់ការ និង ជំនឿទុកចិត្ត ដូច្នេះវាឈានទៅរក

និរន្តរភាពនៃការត្រៀមបង្ការគ្រោះមហន្តរាយយូរអង្វែង ។ ជាមួយគ្នានេះដែរ វាអាចជួយធ្វើអោយមានទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពនៃការផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់។

គំរោង ពង្រឹងការគ្រប់គ្រងគ្រោះអាសន្នទឹកជំនន់ ឧបត្ថម្ភថវិកាពីភ្នាក់ងារសហប្រតិបត្តិការផ្តល់ជំនួយបច្ចេកទេសអន្តរជាតិ ប្រទេសអាឡឺម៉ង់ (GTZ), ដើម្បីពង្រឹងការយល់ដឹងពីប្រព័ន្ធផ្តល់ពតិមានជាមុនពីទឹកជំនន់នៅថ្នាក់មូលដ្ឋាន ដោយផ្អែកលើបទពិសោធន៏ និង មេរៀនទទួលបានពីគំរោងប្រព័ន្ធផ្តល់ពតិមានជាមុនពីគ្រោះទឹកជំនន់មុនៗ ។ ដូច្នេះហើយ បានជាចាប់តាំងពីឆ្នាំ ២០០៤ មក គំរោងពង្រឹងការគ្រប់គ្រងភាពអាសន្នគ្រោះទឹកជំនន់ ផ្នែកទី ៤ នៃកម្មវិធីគ្រប់គ្រង និង កាត់បន្ថយគ្រោះទឹកជំនន់ បានកំនត់យកប្រព័ន្ធផ្តល់ពត៍មានជាមុនពីទឹកជំនន់នៅមូលដ្ឋាន សហគមន៏ (CBEWS) ជាសកម្មភាពអាទិភាពមួយដែលត្រូវអនុវត្ត ដូចដែលបានកំនត់នៅក្នុងកម្មវិធីត្រៀមបង្ការ គ្រោះទឹកជំនន់(FPP)។ ប្រព័ន្ធនេះ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ជាអ្នកគ្រប់គ្រងនិងដឹកនាំអនុវត្ត ។

វចនាសម្ព័ន្ធ និង តួនាទីសំខាន់ របស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ដើម្បីអនុវត្តនយោបាយថ្នាក់ជាតិស្តីពីការគ្រប់គ្រងគ្រោះមហន្តរាយ ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត មានភារកិច្ចរៀបចំសេចក្តីណែនាំ និង គាំទ្រសកម្មភាពរបស់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយស្រុក។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ជាអ្នករាយការណ៍ជូនគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) នូវរាល់សកម្មភាព ដែលអនុវត្តដោយអាជ្ញាធរខេត្ត និង អង្គការក្រៅរដ្ឋាភិបាលនានានៅថ្នាក់ខេត្ត ។ នៅថ្នាក់ខេត្ត និង ស្រុក អភិបាលខេត្តរង និង អភិបាលស្រុករង ជាប្រធានក្រុមប្រតិបត្តិការនៃក្រុមទាំង ៤ គឺ ក្រុមរុករកសង្គ្រោះ និង សន្តិសុខ, ក្រុមសុខភាព អនាម័យ និង ទឹកអនាម័យ, ក្រុមគ្រប់គ្រងពតិមាន និង ប៉ាន់ប្រមាណ និង ក្រុមប្រតិបត្តិការឆ្លើយតបសង្គ្រោះបន្ទាន់ និង ស្តារជួសជុលឡើងវិញ ។ លើសពីនេះទៀត គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ជាអ្នកធ្វើសេចក្តីរាយការណ៍ពីការខូចខាត និង ខូចខាតដោយគ្រោះមហន្តរាយ ហើយរៀបចំសំណើរសុំជំនួយហិរញ្ញវត្ថុ និង សំភារៈ និង ការអន្តរាគមន៏ នៅពេលមានគ្រោះមហន្តរាយកើតឡើង ។ ( *មើលប្រអប់វចនាសម្ព័ន្ធរបស់***PCDM**)

## មេរៀនទី ៦.២: ការជម្លៀស និង ការគ្រប់គ្រងទីកន្លែងជម្លៀស

### ក. និយមន័យ

ការជម្លៀសគឺជាចលនាមនុស្ស ដែលត្រូវចាកចេញពីទីកន្លែងប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ដែលបានកើតឡើង ទៅកាន់ទីកន្លែង សុវត្ថិភាព ។ មុខសញ្ញាគ្រោះថ្នាក់ទាំងអស់មិនតំរូវអោយមានការជម្លៀសគ្រប់ពេលវេលានោះទេ ។ ការជម្លៀស គឺជាការចាំបាច់ក្នុងករណីដែលមុខសញ្ញាទាំងឡាយណាដែលទំនងជាអាចបង្កការគំរាមកំហែង និង អាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់អាយុជីវិតមនុស្ស-សត្វ និងទ្រព្យសម្បត្តិ នៅកន្លែងដែលមុខសញ្ញាបានកើតឡើង ។

ការជម្លៀសមិនកើតឡើងទាំងអស់តែម្តងនោះទេ ប៉ុន្តែត្រូវបានរៀបចំជាដំណាក់ៗបន្ទាប់ពីក៏រិតនៃការប្រកាសអាសន្ននៃប្រព័ន្ធជូនដំណឹងជាមុន ។ ប្រការនេះគឺដើម្បីជៀសវាង នូវភាពស្មុគស្មាញ ។

### ខ. ចំណុចសំខាន់ៗ ដែលត្រូវយកចិត្តទុកដាក់នៅពេលការជម្លៀស :

ក. ការប្រកាសជូនដំណឹង អំពីមុខសញ្ញាគ្រោះថ្នាក់ដែលអាចកើតមាន មានន័យថា ប្រជាពលរដ្ឋត្រូវរៀបចំសំរាប់ ធ្វើការជម្លៀស ។

ខ. បញ្ជាអោយធ្វើដំណើរទៅកាន់ចំណុចប្រមូលផ្តុំ/ចំណុចដែលត្រូវដឹកជញ្ជូន ។

គ. ការជម្លៀសជាក់ស្តែងចេញពីតំបន់ប្រឈមមុខទៅនឹងគ្រោះថ្នាក់ទៅកាន់តំបន់សុវត្ថិភាព ។

ឃ. ស្នាក់នៅមណ្ឌលជម្លៀស។

ង. វិលត្រលប់មកកាន់កន្លែងចាស់ ឬ ទៅតាំងទីលំនៅកន្លែងថ្មី ។

ដើម្បីធានា និង ធ្វើអោយការជម្លៀសមានប្រសិទ្ធិភាព និង ទាន់ពេលវេលា សហគមន៍ត្រូវរៀបចំផែនការមួយសំរាប់ជម្លៀសជាក់ស្តែង ដូចតទៅ :

- កំណត់អត្តសញ្ញាណកន្លែងសុវត្ថិភាព សំរាប់ធ្វើមណ្ឌលជម្លៀស
- កំណត់អត្តសញ្ញាណផ្លូវខ្លីបំផុត និង មានសុវត្ថិភាពបំផុត
- កំណត់អត្តសញ្ញាណ និង រៀបចំផ្លូវជំទៃ
- កំណត់អត្តសញ្ញាណចំណុចត្រូវដឹកជញ្ជូន និង ចំណុចត្រូវប្រមូលផ្តុំប្រជាពលរដ្ឋ
- ដាក់ " ផ្លាកសញ្ញា " នៅតាមបណ្តោយផ្លូវជម្លៀស
- រៀបចំបញ្ជីមេរាយឈ្មោះអ្នកដែលត្រូវជម្លៀស ហើយពិនិត្យនៅត្រង់ចំណុចដឹកជញ្ជូននីមួយៗ ដើម្បីពិនិត្យ

មើលថាតើក្រុមមានសមាជិកគ្រប់ចំនួនដែរឬយ៉ាងណា

- រៀបចំកម្មវិធីដឹកជញ្ជូន និង ចាត់ជាក្រុមនៅក្នុងករណីមានការដឹកជញ្ជូន
- រៀបចំបរិក្ខាបំរុង និង ផែនការជម្លៀសសត្វ និង ទ្រព្យសម្បត្តិរបស់អ្នកដែលត្រូវធ្វើការជម្លៀស
- រៀបចំផែនការគ្រប់គ្រងការជម្លៀស និង បង្កើតជាគណៈកម្មាធិការផ្សេងៗ ក្នុងចំណោមសមាជិកសហគមន៍
- កំណត់អត្តសញ្ញាណ និង រៀបចំលក្ខខ័ណ្ឌនៅក្នុងពេលជម្លៀស ( ដឹកជញ្ជូន ប្រេងឥន្ធនៈ ស្បៀងអាហារ ទឹក ថ្នាំពេទ្យ ផ្លាកសញ្ញាដាក់តាមដងផ្លូវ ប្រព័ន្ធទំនាក់ទំនង ។ល។)
- នៅក្នុងខណៈនៅមណ្ឌលជម្លៀស សមាជិកសហគមន៍ចូលរួមសកម្មយ៉ាងខ្លាំងនៅរាល់ទិដ្ឋភាពទាំងអស់នៃការគ្រប់គ្រងជំរុំ

## គ. ការគ្រប់គ្រងទីកន្លែងជម្លៀស :

មុខសញ្ញាខ្លះតំរូវអោយប្រជាជនដែលរស់នៅតំបន់ប្រឈមមុខនឹងមុខសញ្ញាគ្រោះថ្នាក់ត្រូវផ្លាស់ទីលំនៅរយៈពេលវែង។ អ្នកដែលត្រូវបានជម្លៀសប្រមូលផ្តុំមកពីទីកន្លែងខុសៗគ្នា ហើយជាញឹកញយចាំបាច់ត្រូវ រស់នៅក្នុងទីកន្លែងដែលមានសុវត្ថិភាពរួមគ្នា ។ ប្រការនេះ អាចនាំអោយមានស្ថានភាពច្របូកប្រល់ និង ខ្វះលក្ខណៈអនាម័យប្រសិនបើគ្មានប្រព័ន្ធនៃការគ្រប់គ្រងដាក់អោយដំណើរការទេនោះ ។ ប្រជាពលរដ្ឋអាច ក្លាយ ទៅជាពឹងផ្អែក និង ៗមានអារម្មណ៍តានតឹង ជួនកាលក្លាយទៅជាការបង្កអំពើហឹង្សា ប្រសិនបើពួកគេ គ្មានអ្វីធ្វើ ហើយគ្រាន់តែអង្គុយ និងរង់ចាំជំនួយនោះ ។ ការចូលរួមរបស់ ស្ថាប័ន ឬ ក្រុមដែលមានតួនាទី និង ការទទួលខុស ត្រូវក្នុងការជម្លៀសមានសារៈសំខាន់ណាស់ ព្រោះថាសិទ្ធិក្នុងការសំរេចចិត្តដើម្បីចាត់ចែងចាត់វិធានការក្នុង សង្គ្រោះ និង ជួយកាត់បន្ថយផលប៉ះពាល់ដល់ជីវិត និង ស្ថានភាពនៃបរិស្ថាន ។ ការចូលរួមរបស់ប្រជាពលរដ្ឋនៅ ក្នុងការ គ្រប់គ្រងទីកន្លែងជម្លៀស គឺជាមធ្យោបាយមួយសំរាប់កសាងឡើងវិញនូវជំនឿ ទុកចិត្ត និង សមត្ថភាព របស់ប្រជាពលរដ្ឋព្រោះគេមានបទពិសោធន៍នៅក្នុងអំឡុងពេលគ្រោះមហន្តរាយ ។ ជីវិតរស់នៅក្នុងមណ្ឌល ជម្លៀសមានលក្ខណៈខុសប្លែកគ្នាយ៉ាងខ្លាំងពីជីវិតរស់នៅសាមញ្ញរបស់ប្រជាពលរដ្ឋមុនពេល ដែលពួកគេចូលទៅ កាន់ជុំរុំនោះ ។ នៅក្នុងខណៈដែល ចូលរួមពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងប្រចាំថ្ងៃ ចំពោះទីកន្លែងជម្លៀស ។ ប្រជាពលរដ្ឋអាចកសាងសហគមន៍សារជាថ្មី ហើយពួកគេមានបទពិសោធន៍ នៅក្នុង ការរិះគិតទៅកាន់អនាគតសា ជាថ្មីម្តងទៀត ។ ការបង្កើតឡើងប្រព័ន្ធគ្រប់គ្រងទីកន្លែងជម្លៀស អនុវត្តទៅតាមដំណើរប្រហាក់ប្រហែលគ្នា ដូចគ្នានឹងការបង្កើតឡើងនូវអង្គការឆ្លើយតបនឹងគ្រោះមហន្តរាយនៅមូលដ្ឋានដូច្នោះដែរ ដែលត្រូវបានជម្លៀស អាចត្រូវបាន ទទួលការរៀបចំចាត់តាំងរួចនៅក្នុងគណៈកម្មាធិការនានាឆ្លើយតបនឹងគ្រោះមហន្តរាយ ប្រសិនបើមិនទាន់ត្រូវបានពួកគេមានមេដឹកនាំរបស់ខ្លួន ។ គណៈកម្មការសមស្រប ត្រូវបានបង្កើតឡើងអ្នកស្ម័គ្រ ចិត្តក្នុងចំណោម

អ្នកត្រូវបានជម្លៀសត្រូវបានរស់នៅប្រមូលផ្តុំគ្នា ។ រចនាសម្ព័ន្ធគ្រប់គ្រងពឹងផ្អែកយ៉ាងច្រើន ទៅលើទំរង់ជារូបវន្ត នៃទីកន្លែងជម្លៀស ពោលគឺអាស្រ័យលើទីកន្លែងជម្លៀស ជាកន្លែងដែលមានទីធ្លាធំទូលាយ ដូចជា សាលារៀន វត្តអារាម ទីកន្លែងសាធារណៈដែលមានសុវត្ថិភាព ។

## ឃ. មុខងារ និងការទទួលខុសត្រូវរបស់គណៈកម្មការនានា

គណៈកម្មការនានា សំរាប់ទទួលខុសត្រូវលើវិស័យផ្សេងៗ ត្រូវបានរៀបចំ និង បង្កើតដូចជា គណៈកម្មការសុខភាព គណៈកម្មការស្បៀងអាហារ គណៈកម្មការសន្តិសុខ គណៈកម្មការពត៌មាន ទំនាក់ទំនង/សារធារណៈ ។ល។ គណៈកម្មការទាំងនេះ ជ្រើសរើសមេដឹកនាំរបស់ខ្លួន ដើម្បីអោយតំណាងនៅ ក្នុងគណៈកម្មការនៃទំនាក់ទំនងគ្រប់គ្រងរួមមួយ ។ ភារកិច្ចរបស់គណៈកម្មការទាំងនេះអាចប្រែប្រួលទៅ តាមសាសនាខុសៗគ្នា ដោយសារយោងទៅតាមបរិបទគ្រោះមហន្តរាយជាក់លាក់ និងភាពងាយរងគ្រោះ ។ ជាទូទៅ យើងអាចពណ៌នា អំពីភារកិច្ចរបស់យើង ដូចខាងក្រោម :

### ☞ គណៈកម្មការសុខភាព :

ស្ថានភាពអនាម័យផ្អែកបរិស្ថាន ( ចោលសំរាម ទីកន្លែងសំរាប់សត្វធាតុ បង្គន់អនាម័យ កន្លែងងូតទឹកនៅ ទីកន្លែងជម្លៀស) ។ ប្រការនេះក៏រួមមានផងដែរអំពីការកប់សាកសព នៅក្បែរៗទីនោះ ។ ការផ្តល់នូវជំនួយសង្គ្រោះបន្ទាន់ និង ជំនួយថ្នាំពេទ្យ ការដឹកជញ្ជូនទៅកាន់គ្លីនិក ប្រសិនបើអាចធ្វើបាន ការរៀបចំឱសថបុរាណ និង បង្កើនសន្និធិថ្នាំពេទ្យជាមូលដ្ឋានផ្អែកទៅលើបទពិសោធន៍នេះគណៈកម្មការជាទូទៅរួមមានស្ត្រី ។ អាស្រ័យហេតុនេះគណៈកម្មការនិង អភិវឌ្ឍន៍ខ្លួនឯងទៅក្នុងក្រុមរបស់ស្ត្រី ចំពោះបញ្ហាដទៃទៀត ( ការថែទាំកុមារប្រចាំថ្ងៃ ការយកចិត្តទុក ដាក់ចំពោះអំពើហឹង្សាក្នុងគ្រួសារ ការពិគ្រោះ ឬជីវភាពរស់នៅដទៃទៀត )

### ☞ គណៈកម្មការស្បៀងអាហារ

ការចែកចាយដោយយុត្តិធម៌ នូវជំនួយស្បៀងអាហារដោយចិត្តទុកដាក់ជាពិសេសចំពោះកុមារ មនុស្សចាស់ ស្ត្រីមានផ្ទៃពោះ និង ស្ត្រីបំបៅកូន ។ ការគ្រប់គ្រងលើការធ្វើម្ហូបអាហារ : ការកំណត់ទីតាំងចំអិនអាហារ ប្រព័ន្ធចំអិនអាហារ ( ឧ. ការចំអិន អាហារ ជាសមូហភាពដើម្បីសន្សំអុសកាត់បន្ថយផ្សែង ឬចំអិនម្ហូបទៅតាមគ្រួសារនីមួយៗ ) ។ រៀបចំស្តុកម្ហូបអាហារសំខាន់ ។

## ☞ គណៈកម្មការសន្តិសុខៈ

ធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋម្នាក់ៗមានសុវត្ថិភាព ពុំមានបាត់បង់ជីវិត និងបានមកដល់ទីកន្លែងជម្លៀស ។ ធ្វើយ៉ាងណាឱ្យសុវត្ថិភាពនៅមណ្ឌលជម្លៀសទាំងថ្ងៃ និងទាំងយប់ (មនុស្សម្នា ទ្រព្យសម្បត្តិ និង សត្វ)។ តាមដានទីស្នាក់នៅរបស់ប្រជាពលរដ្ឋការចរចាជាមួយនឹងក្រុមប្រដាប់អាវុធ ចរចាជាមួយប៉ូលីស សមត្ថកិច្ចនៅក្នុងការធ្វើអន្តរាគមន៍ ក្នុងពេលមានទំនាស់រវាងអ្នកដែលត្រូវបានជម្លៀសតាមដានស្ថានភាពជាក់ស្តែង ពីប្រភពដើមមុនពេលត្រឡប់មកកាន់ទីនោះ ។

## ☞ គណៈកម្មការទំនាក់ទំនង/ពត៌មានសាធារណៈ

ធ្វើទំនាក់ទំនងជាមួយនឹងអ្នកនៅខាងក្រៅ (រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ប្រព័ន្ធផ្សព្វផ្សាយ) ដើម្បីផ្តល់ពតិមានចាំបាច់ ស្តីពីប្រវត្តិនៃហេតុការផ្សេងៗ លក្ខខ័ណ្ឌនៅក្នុងទីកន្លែងជម្លៀស តំរូវការ ។ល។ ការកត់ឈ្មោះ និងការតាមដានសមាជិកគ្រួសារ បង្កើតធនធានគាំទ្រ និងការបញ្ចុះបញ្ចូលបញ្ហានានារបស់អ្នកត្រូវបានជម្លៀស ជូនដំណឹងនិងផ្តល់ដំណឹងថ្មីៗទៅអោយអ្នកត្រូវបានជម្លៀសអំពីការវិវត្តន៍ទាក់ទងទៅនឹងស្ថានភាព របស់ខ្លួនទាក់ទងនឹងការមកដល់ នៃអ្នកត្រូវបានជម្លៀសនៅមណ្ឌលជម្លៀស មានប្រការសំខាន់ណាស់ដែល ប្រជាពលរដ្ឋត្រូវចុះឈ្មោះ និងការធ្វើបញ្ជីរាយមុខជំនាញរបស់ពួកគេទាំងនោះ ។ តាមដែលអាចធ្វើទៅបាន យើងគប្បីប្រើប្រាស់ សមត្ថភាពដែលមានស្រាប់នៅក្នុងចំណោមអ្នកដែលត្រូវបានជម្លៀស។ អ្នកដែលមាន បទពិសោធន៍ខាងផ្នែកសុខភាព អាចចូលរួមនៅក្នុងគណៈកម្មការសុខភាព គ្រូបង្រៀន និង សិស្សបញ្ចប់ សាលាមធ្យមសិក្សា អាចនឹងបង្រៀនកុមារ និងដឹកនាំមណ្ឌលថែទាំប្រចាំថ្ងៃ។ ប្រជាពលរដ្ឋដែលមាន ជំនាញទំនាក់ទំនងល្អ និងមានជំនាញ នៅក្នុងការចរចា អាចនឹងមានប្រសិទ្ធភាពនៅក្នុង គណៈកម្មាធិការ ទំនាក់ទំនង និង ពតិមានសាធារណៈ ។ ពួកគេមានមុខងារសំខាន់នៅក្នុងការ ដោះស្រាយជាមួយ នឹងភ្នាក់ងារជំនួយ ភ្នាក់ងារត្រូវ បានជម្លៀសច្រើនតែតវ៉ាអំពីអ្នកធ្វើទស្សនៈកិច្ចជាច្រើន ដែលមកសាកសួរ សំនួរគ្រប់បែបយ៉ាង នៅក្នុងការ វាយតំលៃអំពីតំរូវការ ប៉ុន្តែពួកគេមិនបានផ្តល់ជំនួយទាល់តែសោះ ។ ប្រជាពលរដ្ឋចាត់ទុកថា នេះជាកាយវិការមួយដែលបង្កការរំខាន ហើយនៅចុងបញ្ចប់ដែល ធ្វើអោយមាន ការមួរម៉ៅក្តៅក្រហាយ ។ ប្រការល្អ គេគួរចាត់តាំងមនុស្សមួយចំនួន ដើម្បីធ្វើទំនាក់ទំនងជាមួយនឹងអ្នកមកពីខាងក្រៅ ។

## មេរៀនទី ៦.៣៖ តួនាទីរបស់ស្ត្រី លើសកម្មភាពចូលរួមត្រៀមបង្ការគ្រោះទឹកជំនន់

............................

............................

................................

# មេរៀនទី ៦.៤: ការគ្រប់គ្រងបញ្ជីធនធាន សំរាប់ត្រៀមបង្ការនិងកាត់បន្ថយគ្រោះទឹកជំនន់

## ១. សារៈសំខាន់នៃការគ្រប់គ្រងធនធាន

ផលប្រយោជន៍សំខាន់មួយនៃការរៀបចំធ្វើបញ្ជីរសារពើភ័ណ្ឌធនធាន គឺអាចឱ្យអ្នកធ្វើផែនការពិនិត្យបាន យ៉ាងច្បាស់លាស់ ថាតើធនធានដែលមានស្រាប់ ពោលគឺសំភារៈ ធនធានមនុស្ស និងហិរញ្ញវត្ថុមានគ្រាប់គ្រាន់ ដើម្បីដោះស្រាយជាមួយគ្រោះមហន្តរាយជាសក្តានុភាពបណ្តាលមកពីទឹកជំនន់។ ប្រសិនបើធនធានមិនគ្រប់គ្រាន់ ការរៀបចំយថាភាព ក៏អាចត្រូវកំណត់ផងដែរ។ ការវិភាគ និងការវាយតំលៃធនធានទាំងអស់នេះ ត្រូវចងក្រង ទុកជាឯកសារ តាមទម្រង់បញ្ជីរធនធាន ជាផ្នែកមួយនៃផែនការត្រៀមបង្ការទឹកជំនន់។

### គោលបំណង

កំណត់ប្រភេទ ភាពដែលមាន និងទីតាំងរបស់ធនធានដែលមាននៅតាមមូលដ្ឋានសំរាប់ការឆ្លើយតប ទឹកជំនន់ មានប្រសិទ្ធិភាព។កំណត់ធនធានដែលត្រូវការពីខាងក្រៅ បន្ថែមលើធនធានដែលមាននៅក្នុងមូលដ្ឋាន។ បង្កើតបញ្ជីរសារពើភ័ណ្ឌធនធាន។

### គោលគំនិតសំខាន់ៗ

បញ្ជីរសារពើភ័ណ្ឌធនធានកំណត់និងផ្តល់អាទិភាពធនធាន ការកំណត់ការប្រើប្រាស់ធនធានដែលមានឱ្យ មានប្រសិទ្ធិភាពនៅក្នុងតំបន់ ព្រមទាំងប្រមើលពីតម្រូវការសំរាប់ជំនួយពីខាងក្រៅ ក្នុងពេលមានគ្រោះអាសន្ន។ បញ្ជីរសារពើភ័ណ្ឌធនធានត្រូវផ្តល់អាទិភាពក្នុងការកំណត់ធនធានដែលមានក្នុងមូលដ្ឋានដែលអាចប្រើប្រាស់បានឬ កៀងគរបាន និងនៅ លើកឡើងធនធានទាំងនោះដែលអាចមាន ប៉ុន្តែត្រូវខូចខាត ឬមិនដំណើរការ។ ការធ្វើ បច្ចុប្បន្នភាពនៃបញ្ជីរសារពើភ័ណ្ឌធនធាន ត្រូវធ្វើជាទៀងទាត់ មុនទឹកជំនន់កើតឡើង ដើម្បីពិនិត្យស្ថានភាព ធនធានឡើងវិញ។ នេះមានសារៈសំខាន់ក្នុងការបង្កើតបញ្ជីរសារពើភ័ណ្ឌលំអិតនៃប្រព័ន្ធបែបនេះជា បរិក្ខារ ទំនាក់ទំនង ស្តុបទុក ដឹកជញ្ជូន សុខាភិបាល ទីជំរកសុវត្ថិភាព និងបរិក្ខារដែលពាក់ព័ន្ធ។ល។ ដើម្បីធានា ការឆ្លើយ តបទឹកជំនន់មានប្រសិទ្ធិភាព។

ភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយដែលមាន (ទាំងរដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល) និងវត្ថុមាន របស់ក្រុមអ្នកស្ម័គ្រចិត្ត ក៏ត្រូវពិចារណាថាជាធនធានមានតំលៃផងដែរ។

### បញ្ជីធនធានសំរាប់ការត្រៀមបង្ការទឹកជំនន់

**ឧបសម្ព័ន្ធទី ១**

បញ្ជីរសារពើភ័ណ្ឌធនធានមួយដែលបានបង្កើតឡើងសំរាប់ការធ្វើផែនការត្រៀមបង្ការទឹកជំនន់កំនត់ភាព ដែលមាននៃធនធានដូចតទៅ :

ធនធានមនុស្ស - ឧ. អ្នកស័គ្រចិត្ត ក្រុមពន្លត់អគ្គីភ័យ អ្នកមានវិជ្ជាជីវៈខាងវេជ្ជសាស្ត្រ អ្នក ជំនាញខាងស្រាវ ជ្រាវ និងបុគ្គលិកសង្គ្រោះ ។

ធនធានសំភារ: - ឧ. ធនធានផ្នែកដឹកជញ្ជូន ការទំនាក់ទំណង ទីជំរក និងធនធានផ្សេងៗ ប្រព័ន្ធស្តុបទុក ប្រព័ន្ធសុខាភិបាល និងផ្សេងៗ ។

ធនធានហិរញ្ញវត្ថុ - ឧ. ថវិកាឆ្លើយតបគ្រោះអាសន្នគ្រប់គ្រងដោយអាជ្ញាធរមូលដ្ឋានសំរាប់ការប៉ាន់ប្រមាណ រហ័សនៅពេលទឹកជំនន់ ដែលបរិច្ចាកពីប្រភពធនធានឯកជន ។

បញ្ជីរសារពើភ័ណ្ឌធនធានបំរើជាឯកសារមូលដ្ឋានមួយក្នុងការកំនត់ថាតើធនធានដែលមានគ្រប់គ្រាន់ដោះស្រាយជាមួយនឹងគ្រោះមហន្តរាយជាសក្តានុភាពបណ្តាលដោយទឹកជំនន់ និងកំណត់អ្វីដែលជាធនធានខាងក្រៅអាចត្រូវការ ។ វាត្រូវតែថែរក្សានិងធ្វើបច្ចុប្បន្នភាពជាទៀងទាត់ ឆ្លុះបញ្ចាំងពីកន្លែងនិងទីតាំងពិតរបស់ធនធាន ។ បញ្ជីរសារពើភ័ណ្ឌធនធានរបស់តំបន់ពិសេស ឆ្លុះបញ្ចាំងពីធនធានដែលមាននៅក្នុងអនុតំបន់របស់វា ។ ឧទាហរណ៏ បញ្ជីរសារពើភ័ណ្ឌធនធានខេត្ត គឺជាការចងក្រងបញ្ជីរសារពើភ័ណ្ឌធនធានទាំងឡាយមកពីបញ្ជីរសារពើភ័ណ្ឌធនធានតាមស្រុក ហើយបញ្ជីរសារពើភ័ណ្ឌធនធានស្រុក គឺជាការប្រមូលផ្តុំបញ្ជីរសារពើភ័ណ្ឌធនធានទាំងឡាយមកពីឃុំដែលមាននៅក្នុងស្រុក ។ល ។

ក្នុងការរៀបចំបញ្ជីរសារពើភ័ណ្ឌធនធាន តួនាទីរបស់អាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយខេត្តនិងស្រុក គឺជាស្នូលក្នុងការសំរបសំរួលការសហការក្នុងចំណោមអ្នកពាក់ព័ន្ធ( ភ្នាក់ងារពាក់ព័ន្ធនិងអង្គការផ្សេងៗ) ដើម្បីថែរក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីរសារពើភ័ណ្ឌ ។

## ២. ប្រភពធនធាន

ឧទាហរណ៏នៃធនធានខុសៗគ្នាដែលមាននៅក៏រិតខុសៗគ្នា : តាមផ្ទះសម្បែង ថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ មានក្នុងបញ្ជីរដូចខាងក្រោម ។

### *ក. ធនធានតាមផ្ទះសម្បែង ថ្នាក់ភូមិ និងថ្នាក់ឃុំ :*

*ធនធានមនុស្ស* - អ្នកស្ម័គ្រចិត្តកាកបាទក្រហម ក្រុមឆ្លើយតបគ្រោះមហន្តរាយនៅក្នុងភូមិ សមាជិក សហជីពស្ត្រី គណ:កម្មាធិការឃុំ អាជ្ញាធរ-ភ្នាក់ងារគ្រប់គ្រងគ្រោះមហន្តរាយមូលដ្ឋាន ក្រុមសុខាភិបាល ថ្នាក់ភូមិ ឬក្រុម សង្គ្រោះបឋម ។

*ធនធានសំភារៈ*

**ការដឹកជញ្ជូន** — នៅជិតផ្លូវថ្នាល់ ចំនួនផ្លូវថ្នល់ខាងលើប៉ាន់ប្រមាណកំរិតទឹក ម៉ូតូ ទូក ឡាន រទេះ ផ្លូវទៅតំបន់សុវត្ថិភាព។

**ការទំនាក់ទំនង** - ឧបករណ៍វិទ្យុ ទូរទស្សន៍ ទូរស័ព្ទ ហ្វាក់ ប្រដាប់បំពងសំលេង។

ទីជំរកនិងធនធានដែលពាក់ព័ន្ធ - ចំនួន ទីតាំង និងសមត្ថភាពរបស់តំបន់សុវត្ថិភាព-ទាំងអ្វីដែលមានស្រាប់និងអ្វីដែលជាសក្តានុភាព ដូចជា ដីទួលសាលារៀន វត្តអារាម ឬប្រាសាទ តង់ បរិក្ខាជាមូលដ្ឋាននៅតំបន់សុវត្ថិភាព។

**ប្រព័ន្ធស្តុបទុក**- ចំនួនឃ្លាំង ឬតំបន់ស្តុបទុកដែលអាចជំនួស និងចំណុះរបស់វា។

**ប្រព័ន្ធសុខាភិបាល**- ចំនួននិងទីតាំងគ្លីនិកឬកន្លែងថែទាំសុខភាពផ្សេងទៀតនៅក្នុងតំបន់ជុំវិញ។

ផ្សេងៗ-ចំនួនឧបករណ៍ដែកប្រហោងមានរុន្ធ បង្គន់ ចំនួនស្នាមទឹកឡើង មណ្ឌលប្រកាសអាសន្ននៅ ក្នុងភូមិ ចំនួននិងទីតាំងប៉ុស្តិ៍ស្វែងរកនិងសង្គ្រោះ។

***ធនធានហិរញ្ញវត្ថុ***—ចំនួនស្ថាប័នហិរញ្ញវត្ថុនៅក្នុងតំបន់ ការមានថវិកាមូលដ្ឋានសំរាប់គ្រោះអាសន្ន ម្ចាស់ ជំនួយ-អ្នកបរិច្ចាកជាសក្តានុភាពដែលមាន ក្នុងករណីគ្រោះអាសន្ន។

## ខ. ធនធាននៅថ្នាក់ស្រុក :

***ធនធានមនុស្ស***—គណៈកម្មាធិកា-ភ្នាក់ងារទទួលខុសត្រូវការគ្រប់គ្រងគ្រោះមហន្តរាយនៅថ្នាក់ស្រុក (ឧ.គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ស្រុក DCDM គណៈកម្មាធិការកាកបាទក្រហមស្រុក ភ្នាក់ងារគ្រប់គ្រងធនធានទឹកនិងឧត្តុនិយម) អង្គការធំៗ(ឧ.សហជីពស្ត្រី ក្រុមអ្នកស្ម័គ្រចិត្ត ក្រុមយុវជន ក្រុមកសិករ) បុគ្គលិកសុខាភិបាល បណ្តាញការងារអ្នកស្ម័គ្រចិត្តទទួលខុសត្រូវការផ្សព្វផ្សាយគ្រោះអាសន្ន អង្គការក្រៅរដ្ឋាភិបាល។

***ធនធានសំភារៈ***

**ការដឹកជញ្ជូន**-លើកផ្លូវ សេវាកម្មរថយន្ត-រទេះភ្លើងសាធារណៈ បណ្តាញផ្លូវល្អ ការទៅដល់តំបន់ សុវត្ថិភាព ទូកនិងបណ្តាញទឹក ឡាន ម៉ូតូ រទេះ។

**ការទំនាក់ទំនង**-បណ្តាញព័ត៌មានសាធារណៈ (ឧ.បណ្តាញអ្នកស្ម័គ្រចិត្តកាកបាទក្រហម បណ្តាញសហជីពស្ត្រី) ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ម៉ាស៊ីនហ្វាក់ ក្តាររូបភាព និងឧបករណ៍ក្រិតទឹកជំនន់។

ទីជំរកនិងធនធានដែលទាក់ទង- ចំនួននិងទីតាំងជំរកសុវត្ថិភាព( មានស្រាប់និងជាសក្តានុភាព) និង ចំណុះរបស់វា បរិក្ខាជាមូលដ្ឋាននៅតំបន់សុវត្ថិភាព ។

ប្រព័ន្ធស្តុបទុក ។

**ប្រព័ន្ធសុខាភិបាល**-ចំនួននិងទីតាំងមន្ទីរពេទ្យនិងសេវាសុខាភិបាល ។

ផ្សេង១-ការប្រើប្រាស់សេវា ដូចជា( ប្រព័ន្ធអាងស្តុកទឹក ប្រព័ន្ធចែកចាយទឹក) និងរោងចក្រផលិត អគ្គិសនី ប្រព័ន្ធលូរបង្ហូរទឹកសំអុយ ទំនប់ទឹកនិង dykes ។

***ធនធានហិរញ្ញវត្ថុ***— ចំនួនស្ថាប័នហិរញ្ញវត្ថុ ដូចជាធនាគារនៅក្នុងតំបន់ ការមានថវិកាគ្រោះអាសន្នមូលដ្ឋាន ម្ចាស់ ជំនួយ-អ្នកបរិច្ចាកជាសក្តានុភាពដែលមាន ក្នុងករណីគ្រោះអាសន្ន ។

### ***គ. ធនធាននៅថ្នាក់ខេត្ត :***

***ធនធានមនុស្ស:*** គណៈកម្មាធិការទទួលខុសត្រូវការគ្រប់គ្រងគ្រោះមហន្តរាយ ( ឧ. គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត PCDM) អង្គការជាតិនិងអន្តរជាតិដែលធ្វើការនៅក្នុងតំបន់ សាខាកាកបាទក្រហម ខេត្ត និងអ្នកស្ម័គ្រចិត្ត អង្គការធំ១ ( ឧ. សហជីពស្ត្រីខេត្ត សហជីពកសិករនិងយុវជន ក្រុមអ្នកស្ម័គ្រចិត្ត) អង្គការគ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ខេត្ត បណ្តាញអ្នកស្ម័គ្រចិត្តក្នុងមូលដ្ឋានទទួលខុស ត្រូវការប្រកាសអាសន្ន ។

***ធនធានសំភារៈ***

**ការដឹកជញ្ជូន**-លើកផ្លូវ សេវាកម្មរថយន្ត-រទេះភ្លើងសាធារណៈ បណ្តាញផ្លូវល្អ ការទៅដល់តំបន់ សុវត្ថិភាព ទូកនិងបណ្តាញទឹក ឡាន ម៉ូតូ រទេះ ។

**ការទំនាក់ទំនង**-បណ្តាញព័ត៌មានសាធារណៈ ( ឧ.បណ្តាញអ្នកស្ម័គ្រចិត្តកាកបាទក្រហម បណ្តាញ សហជីពស្ត្រី) ស្ថានីយ៍វិទ្យុ ទូរទស្សន៍ ម៉ាស៊ីនហ្វាក់ ក្តាររូបភាព និងឧបករណ៍វាស់ទឹកជំនន់ ។

ទីជំរកនិងធនធានដែលទាក់ទង- ចំនួននិងទីតាំងជំរកសុវត្ថិភាព( មានស្រាប់និងជាសក្តានុភាព) និង ចំណុះរបស់វា បរិក្ខាជាមូលដ្ឋាននៅតំបន់សុវត្ថិភាព ។

ប្រព័ន្ធស្តុបទុក ។

**ប្រព័ន្ធសុខាភិបាល**-ចំនួននិងទីតាំងមន្ទីរពេទ្យនិងសេវាសុខាភិបាល ។

ផ្សេង១-ការប្រើប្រាស់សេវា ដូចជា( ប្រព័ន្ធអាងស្តុកទឹក ប្រព័ន្ធចែកចាយទឹក) និងរោងចក្រផលិត អគ្គិសនី ប្រព័ន្ធលូរបង្ហូរទឹកសំអុយ ទំនប់ទឹកនិង dykes ។

**ធនធានហិរញ្ញវត្ថុ** - ចំនួនស្ថាប័នហិរញ្ញវត្ថុ ដូចជាធនាគារនៅក្នុងតំបន់ ការមានថវិកាគ្រោះអាសន្នមូលដ្ឋាន ម្ចាស់ជំនួយ-អ្នកបរិច្ចាកជាសក្តានុភាពដែលមាន ក្នុងករណីគ្រោះអាសន្ន។

## ***ឃ. ធនធាននៅថ្នាក់ជាតិ :***

ធនធានជាតិគួរតែទទួលបានយ៉ាងងាយស្រួលដោយសហគមន៍គោលដៅនៅពេលមានគ្រោះមហន្តរាយកើតឡើង និងឥទ្ធិពលលើសពីសមត្ថភាពដោះស្រាយរបស់សហគមន៍។ ធនធានជាតិអាចបែងចែកបន្តទៀតទៅក្នុង ធនធានរដ្ឋាភិបាល និងអង្គការ។

***ធនធានរដ្ឋាភិបាល :***

***ធនធានមនុស្ស***- ក្រុមប្រឹក្សា-គណៈកម្មាធិការ- ក្រសួងគ្រប់គ្រងគ្រោះមហន្តរាយជាតិ ឬថ្នាក់កណ្តាលទទួលខុសត្រូវលើសេវាកម្មការពារជាតិ ឧត្តុនិយមជលសាស្ត្រ សេវាកម្មផ្លូវច្បាប់ ភ្នាក់ងារគ្រប់គ្រងកសិកម្មនិងធនធានទឹក ស្ថាប័នអប់រំ ការដឹកជញ្ជូន ប្រៃសនីយ៍និងទូរគមនាគមន៍ ការិយាល័យឬមជ្ឈមណ្ឌលព័ត៌មាន អង្គការសង្គមកិច្ច និងអាជ្ញាធរអាកាសចរណ៍ស៊ីវិល និងការហោះហើរ។

***ធនធានសំភារៈ*** គ្របដណ្តប់លើធនធានដឹកជញ្ជូន ការទំនាក់ទំនង ទីជំរក និងធនធានទាក់ទង ប្រព័ន្ធស្តុកទុក ប្រព័ន្ធសុខាភិបាលនិងផ្សេងៗ។

***ធនធានហិរញ្ញវត្ថុ***- ស្ថាប័នហិរញ្ញវត្ថុថ្នាក់ជាតិ ថវិកាគ្រោះអាសន្នជាតិ។

ធនធានក្រៅរដ្ឋាភិបាល គឺជាទ្រព្យសម្បត្តិគ្រប់គ្រងជាម្ចាស់និងប្រតិបត្តិដោយដោយសង្គមស៊ីវិល ដូចជា :

***ធនធានមនុស្ស***—អ្នកមើលការខុសត្រូវវិទ្យុ អង្គការឯកជន-អង្គការពាណិជ្ជកម្ម ក្រុមសាសនា អ្នកលក់ដុំ និងអ្នកផ្គត់ផ្គង់ស្បៀងសង្គ្រោះបន្ទាន់ បុគ្គលិកពេទ្យឯកជន ក្រុមសាធារណៈ ដូចជាកាកបាទក្រហម អង្គការអឌ្ឍចន្ទក្រហមនៅថ្នាក់ជាតិ អង្គការសង្គមកិច្ច អ្នកស្ម័គ្រចិត្ត ជាពិសេសសកម្មជនយុវវ័យ។

*ធនធានសំភារៈ* គ្រប់ដណ្តប់លើធនធានដឹកជញ្ជូន ការទំនាក់ទំនង ទីជំរកនិងធនធានទាក់ទង ប្រព័ន្ធស្តុកទុក និងប្រព័ន្ធសុខាភិបាលនិងផ្សេងៗ។

***ធនធានហិរញ្ញវត្ថុ***— ស្ថាប័នហិរញ្ញវត្ថុឯកជន ថវិកាដែលមានតាមរយៈកម្មវិធីអនុវត្តដោយភ្នាក់ងារកាត់បន្ថយគ្រោះមហន្តរាយនិងការអភិវឌ្ឍន៍ចំណុច។

ក្រៅពីធនធានទាំងឡាយខាងលើ ក៏នៅមាន **ធនធានអន្តរជាតិ** ជាមធ្យោបាយខាងក្រៅ ដែលប្រទេសមួយអាចទទួលបានដើម្បីជាបំណងកាត់បន្ថយគ្រោះមហន្តរាយ ។ ការប្រើប្រាស់ធនធានអន្តរជាតិ ដោយប្រទេសអាចពឹងផ្អែកលើកត្តាដូចតទៅ ៖

- កិច្ចព្រមព្រៀងជំនួយទ្វេភាគីដែលមានស្រាប់ ជាមួយអង្គការ ភ្នាក់ងារ ប្រទេសផ្តល់ជំនួយ ។
- ភាពទាក់ទងខាងផ្នែកនយោបាយ ពីទស្សនៈរបស់ប្រទេសជាអ្នកទទួល ក្នុងការទទួលជំនួយពីខាងក្រៅ ។
- ស្ថេរភាពនៃធនធានអន្តរជាតិ ជាពិសេស ស្ថានភាពគ្រោះមហន្តរាយ(ពីទស្សនៈរបស់ម្ចាស់ជំនួយ) ។

## សំណួរសំរាប់ពិចារណា

តើធនធានសំខាន់អ្វីខ្លះដែលមាននៅថ្នាក់ជាតិ ថ្នាក់ខេត្ត និងថ្នាក់ស្រុក ដែលអាចប្រើប្រាស់ដើម្បីត្រៀមចំឆ្លើយតបទៅនឹងទឹកជំនន់ ។

ហេតុអ្វីបានជាត្រូវយកចិត្តទុកដាក់ពិសេសចំពោះធនធានដែលមាននៅតាមផ្ទះ និងថ្នាក់ឃុំ?

តើចំណាត់ថ្នាក់សំខាន់ៗអ្វីខ្លះដែលធនធាននៅគ្រប់កំរិតអាចត្រូវវាយតំលៃ?

# មេរៀនទី ៦.៥: ការគ្រប់គ្រងសុខភាពសាធារណៈ ក្នុងរដូវទឹកជំនន់

## ១ និយមន័យ

ជាការថែរក្សាសុខភាពប្រជាពលរដ្ឋទូទៅ

ជាការសិក្សាវាយតំលៃជាបន្តបន្ទាប់នូវធនធាន និង អេកូឡូស៊ីសហគមន៍

ជាការសិក្សាស្រាវជ្រាវស្វែងរកមូលដ្ឋានច្បាស់លាស់ដែលពាក់ពន្ធ័ដល់បញ្ហាសុខភាព

ជាការកាត់បន្ថយនូវភាពអន្តរាយ ឬគ្រោះថ្នាក់ដែលប៉ះពាល់ដល់សុខភាព និងជួយដោះស្រាយអំពីបញ្ហាសុខភាព ដែលកើតមាននៅក្នុងសហគមន៍

ការធ្វើផែនការសុខាភិបាល និង ការកំណត់គោលនយោបាយផ្នែកសុខាភិបាល

**សុខភាពសាធារណៈចែកចេញជា ០៣ផ្នែក:**

ក. ភាពសុខស្រួលខាងផ្លូវកាយ

ខ. ភាពសុខស្រួលខាងផ្លូវចិត្ត

គ. ភាពសុខស្រួលខាងផ្លូវសង្គម

**សុខភាពសាធារណៈជាកិច្ចការងាររបស់អ្នកណាខ្លះ?**

គ្រប់ផ្នែក គ្រប់ថ្នាក់ គ្រប់ជំនាញពិតជាពាក់ពន្ធ័ក្នុងការទទួលខុសត្រូវ:

អ្នកជំនាញខាងផ្នែកសុខភាពសាធារណៈ( ប្រមូល-វិភាគពត៌មាន-សិក្សាស្រាវជ្រាវពីផល ប៉ះពាល់-ការបញ្ចៀសភាពអន្តរាយ...)

ក្រុមគ្រូពេទ្យ-គិលានុប្បដ្ឋាកធ្វើការថែ និង ព្យាបាល ។

គណកម្មការគ្រប់គ្រងគ្រោះមហន្តរាយគ្រប់ថ្នាក់ទទួលខុសត្រូវចាត់ចែងដឹកនាំ ផ្តល់របាយការណ៏ សហការ និង ជាពិសេស គឺការអប់រំសុខភាពតាមបែបសុខភាពសាធារណៈ ។ល។.

**ហេតុអ្វីបានជាចាំបាច់ត្រូវអប់រំសុខភាពសំរាប់គ្រោះទឹកជំនន់?**

- គ្រោះទឹកជំនន់ជាមហន្តរាយដែលបណ្តាលឱ្យខូចខាត បាត់បង់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ទ្រព្យសម្បត្តិសាធារណៈ ពិសេសសុខភាពប្រជាពលរដ្ឋទូទៅ ។
- ការយល់ដឹងជាមុនអំពីគ្រោះទឹកជំនន់ និង វិធានការការពារជាមធ្យោបាយដ៏មានប្រសិទ្ធិភាពបំផុត សំរាប់កាត់បន្ថយគ្រោះភ័យក្នុងពេលមានទឹកជំនន់ ។

**តើនរណាខ្លះដែលអាចធ្វើការងារអប់រំសុខភាពបាន?**

- អ្នកណាក៏អាចធ្វើការងារអប់រំសុខភាពបានដែរឱ្យតែពួកគាត់អាចយល់ពីប្រធាន បទដែលត្រូវធ្វើការអប់រំមានបទពិសោធន៍ខ្លះទៅនឹងប្រធានបទនោះ រួមជាមួយសមត្ថភាពដែលអាចធ្វើឱ្យអ្នកទទួលការអប់រំយល់ និង អាចធ្វើតាមការអប់រំបាន ។
- ប៉ុន្តែបច្ចុប្បន្ននេះតាមការសិក្សាបែបសុខភាពសាធារណៈបង្ហាញឱ្យឃើញថាការ អប់រំសុខភាពដែលមានប្រសិទ្ធិភាព និង សុពលភាពបំផុតនោះគឺការធ្វើឡើង តាមរយៈគ្រឹះស្ថានសិក្សា ។

ខាងក្រោមនេះ គឺជាវិធានការសាមញ្ញៗដែលជួយឱ្យសហគមន៍ដែលស្ថិតនៅតំបន់ងាយទទួលរងការគំរាមកំហែងដោយសារគ្រោះទឹកជំនន់ទាំងឡាយ អាចចៀសផុតពីគ្រោះថ្នាក់បាន:

## ២. វិធានការណ៍នានាសំរាប់ត្រៀមបង្ការ និង កាត់បន្ថយគ្រោះថ្នាក់

### ក. វិធីបង្ការកុំអោយលង់ទឹក:

- ធ្វើរបងព័ទ្ធជុំវិញស្រះ-បឹង-ត្រពាំង- ឬ កន្លែងមានរណ្តៅជ្រៅ
- ធ្វើរនាំងការពារតាមមាត់ទ្វារផ្ទះ ឬតាមទូក ឬ តាមកន្លែងមាត់ច្រកក្បែរទាំងដែលអាចក្មេងតូចវា ឬ ដើរធ្លាក់ចូលទឹកបាន ។
- ការធ្វើដំណើរដោយទូក កាណូត មិនត្រូវដាក់មនុស្សលើសចំណុះឡើយ ( ពិសេសកុមារ ស្ត្រីផ្ទៃពោះ និង ចាស់ជរា ) ហើយក៏ត្រូវមានពោងគ្រប់គ្រាន់ផងដែរ ។
- កុំឱ្យក្មេងលេងទឹក ឬ បង្ហាត់ក្មេងហែលទឹក ឬងូតទឹកឱ្យក្មេងនៅកន្លែងដែលមានទឹកហូរ ។
- មិនត្រូវបណ្តោយក្មេងលេងទឹក ឬ បង្ហាត់ហែលទឹក។
- មិនត្រូវយកក្មេង ទៅងូតទឹកកន្លែងមានទឹកជ្រៅ ឬ ទឹកហូរខ្លាំងឡើយ ។

### ខ. វិធីបង្ការសត្វពស់ចឹក:

- ដាក់ផ្លែក្រូចសើចនៅជុំវិញកន្លែងយើងរស់នៅ ឬ នៅតាមកន្លែងដែលសង្ស័យថាអាចមានពស់មករស់នៅ (ជាវិធីបូរាណតែមានប្រសិទ្ធិភាព)
- មុនពេលលូកយករបស់របរពីកន្លែងដែលមានរំពុករំពុយ រមូរបាវ គំនរអុស ស្នឹម ចំបើង.. ត្រូវយកឈើវែងគោះជាមុន និង បើពេលយប់ត្រូវប្រើពិលបំភ្លឺផងដែរ។
- ពាក់ស្បែកជើងកវែង និងស្លៀកខោក្រាស់ជើងវែង ក្នុងពេលធ្វើដំណើរ ពិសេសនៅពេលយប់។
- ពេលសំរាន្តត្រូវដាក់មុងដោយមានសង្កត់ជើងមុងឱ្យបានមុតមាំជុំវិញ ។

- ឧស្សាហ៍ឆែកឆេរមើលក្នុងកន្លែងស្នាក់នៅ និង សំអាតឱ្យមានរបៀបរៀបរយល្អ ។
    - កំចាត់សត្វល្អិតនានា រក្សាសត្វស្លាបចិញ្ចឹមឱ្យនៅឆ្ងាយពីយើង( ទាក់ទាញពស់)

☞ ***ករណីមានពស់ចឹក ត្រូវ:***

- រក្សាអ្នករងគ្រោះកុំឱ្យមានចលនាខ្លាំង ។ ក្នុងករណីអ្នករងគ្រោះមានតែម្នាក់ឯង សូមធ្វើដំណើរយឺតៗ ដើម្បីស្វែងរកជំនួយឯអ្នកជួយសង្គ្រោះ
- ត្រូវលើកទឹកចិត្តកុំឱ្យអ្នករងគ្រោះស្លុតខ្លាំង និងជួយចងការ៉ូរួចចងអបហើយបញ្ជូនទៅកាន់សេវាសុខាភិបាល ជាបន្ទាន់ ។
- ហាមផ្តល់គ្រឿងស្រវឹងដល់អ្នករងគ្រោះ ។
- ហាមធ្វើអន្តរាគមន៍ផ្សេងៗលើមុខរបួសដែលគ្មានប្រយោជន៍ ។
- ករណីពស់ព្រួសពិសដាក់ភ្នែកសូមលាងភ្នែកជាបន្ទាន់ជាមួយនឹងទឹកស្អាត ឬ ទឹកលាយអំបិលបន្តិច ឬ បើគ្មានសូមលាងជាមួយនឹងទឹកនោម ។

***<u>ចំណាំ:</u>*** *- ក្នុងករណីពស់ពិសចឹកហើយមានស្នាមមុតជាចង្កូម និងពុំមានចេញឈាម ( វាជាពស់មានពិស) ។*
*- ក្នុងករណីពស់ពិសចឹកមានស្នាមមុតជាចង្កូម និងមានចេញឈាម ( វាជាពស់គ្មានពិស) ។*

## គ. វិធីបង្ការជំងឺឆ្លងផ្សេងៗ និង ជំងឺកង្វះអាហាររូបត្ថម្ភ:

- ការបង្ការជំងឺឆ្លង : ដោយការអនុវត្តន៏វិធានការស្អាត ០៣ប្រការ គឺ:
  ១-ផឹកស្អាត ២- ហូបស្អាត និងមានជីវជាតិ ៣- រស់នៅស្អាត ។
- បង្ការកង្វះអាហាររូបត្ថម្ភ : ដោយការអប់រំឱ្យប្រជាជនស្គាល់អាហារសំខាន់ៗទាំង ០៣ក្រុម គឺ :
  - អាហារសាងសង់ឬស្ថាបនា
  - អាហារថាមពល
  - អាហារការពារ

## ឃ. វិធីបង្ការជំងឺលើទារក(ក្រោមអាយុ ៥ឆ្នាំ)នៅពេលទឹកជំនន់:

- ត្រូវបន្តបំបៅកូនដោយទឹកដោះម្តាយ ។
- ត្រូវផ្តល់អាហារបានត្រឹមត្រូវ និង ទៀងទាត់ ។
- ត្រូវផ្តល់ថ្នាំបង្ការបានត្រឹមត្រូវ និង តាមដានសុខភាពជាប្រចាំ ។

## ខ- ការត្រៀមសំភារៈប្រើប្រាស់ និងស្បៀងអាហារផ្សេងៗ

ត្រូវតែមានត្រៀមនូវ សំភារៈទាំងឡាយណាដែលធានាបំរើបានទៅលើជីវភាព និង គាំពារ ដល់សុខមាលភាព ចាំបាច់ប្រចាំថ្ងៃ។



ត្រូវតែមានលក្ខណៈសម្បត្តិ ដែលរក្សាទុកបានយូរ ពិសេសត្រូវតែស្ថិតក្នុងក្រុមអាហារទាំង ០៣យ៉ាង គឺៈ

*១-អាហារសាងសង់*

*២-អាហារថាមពល*

*៣-អាហារការពារ*



## ច- របៀបថែរក្សាទឹកស្អាតសំរាប់បរិភោគៈ

- ទឹកដាំពុះដែលធានាថាអាចផឹកបានលុះត្រារក្សាក្នុងស្ថានភាពពុះរយៈពេល១៥នាទី និង ពុំមានលាយទឹកផ្សេងទៀតក្រោយដាំពុះឡើយ។
- ទឹកភ្លៀងត្រូវត្រងពីដំបូលស្អាត និងទុកដាក់បានល្អ រួមទាំងការប្រើប្រាស់ឱ្យបានត្រឹមត្រូវផង។

- ឧបករណ៍ទុកដាក់និងសំរាប់ដងប្រើត្រូវស្អាត។
- ទុកដាក់ឆ្ងាយពីទឹកផ្សេងៗទៀត។
- ត្រូវកូរសាច់ជូរ-ទុករងថ្លា-ផ្ទេរយកទឹកថ្លាដាក់ក្នុងឧបករណ៍រក្សាទុកប្រើសំរាប់ដាំស្ល ។
- ទឹកដែលបង់ថ្នាំក្លរ៉ាមីន គឺទុកសំរាប់ផឹក ( ថ្នាំ ០១គ្រាប់(៥០០ម.ក្រ) បង់ចូលក្នុងទឹក២៥លីត្រ ដោយរក្សាទុករយៈពេល ៣០នាទីសិន ទើបអាចប្រើប្រាស់បាន) ។




## ៣. បទដ្ឋានសំខាន់ៗដែលត្រូវយកមកគិតគូរសំរាប់បំរើឱ្យស្ថានភាពសុខភាព និងជីវភាពរបស់សហគមន៍ក្នុងពេលមានគ្រោះទឹកជំនន់

| | **បរិមាណ និង គំរូវការ** |
|---|---|
| **១-បរិមាណទឹក :** | ប្រជាជនម្នាក់ត្រូវការទឹកប្រើប្រាស់ប្រចាំថ្ងៃចំនួន ១៥ លីត្រក្នុងនោះ ក្នុង ១ ថ្ងៃ |
| **២-អណ្តូងទឹក :** | ០១គ្រឿងសំរាប់ប្រជាជន ២៥០ នាក់ និង ចំងាយពីបង្គន់អនាម័យ យ៉ាងតិច ៣០ម៉ែត្រហើយគឺជាអណ្តូងទឹកដែលទទួលបានការវិភាគត្រឹមត្រូវដោយផ្នែកជំនាញបាល់ដល់ សុខភាព ។ |
| **៣-បន្ទប់ទឹក :** | ត្រូវមាន ១ បន្ទប់សំរាប់ប្រជាជន ២០ នាក់ ។ ការសាងសងមិនត្រូវមានចំងាយលើសពី ៥០ម៉ែត្រ ពីជំរកស្នាក់នៅឡើយ ។ |
| **៤-បង្គន់អនាម័យ:** | បង្គន់ ១ សំរាប់មនុស្សប្រើប្រាស់យ៉ាងច្រើនបំផុត ២០នាក់ និង មានចំងាយពី ៦-៥០ ម៉ែត្រពីជំរកស្នាក់នៅ ឬ មិនឱ្យដើរលើសពី ១ នាទីហើយក៏ត្រូវមានចំងាយពីប្រភព ទឹកប្រើប្រាស់ចំនួនយ៉ាងតិច ៣០ម៉ែត្រ ពិសេសត្រូវមានបង្គន់ស្ត្រី និង បុរស នៅដាច់ ពីគ្នា។ |

| | |
|---|---|
| **៥-ការទុកដាក់កាកសំណល់រឹង** | ត្រូវមានសំភារៈដាក់កាកសំណល់ ១ ដែលមានចំណុះ ១០០លីត្រ សំរាប់ ១០ គ្រួសារឬរណ្តៅ២ម៉ែត្រគុណ៩ម៉ែត្រគុណ២ម៉ែត្រសំរាប់មនុស្ស៥០០នាក់ ហើយកាកសំណល់ត្រូវបានដុត ឬ រកកន្លែងជីកកប់បានត្រឹមត្រូវ និង ឱ្យឆ្ងាយពីប្រភពទឹកប្រើប្រាស់ ។ |
| **៦-ការផ្គត់ផ្គង់ជំរក :** | គ្រួសារដែលមានសមាជិក ៥នាក់យ៉ាងហោចត្រូវមានកំរាលផ្លាស្ទិក ៤ម៉ែត្រ x៦ម៉ែត្រ ហើយក៏ត្រូវគិតគូរពីគុណភាពរបស់កំរាលផងដែរ។ |
| **៧-តំរូវការសាប៊ូសំអាត :** | មនុស្សម្នាក់ត្រូវការសាប៊ូសំអាតចំនួន ២៥០ ក្រាម ក្នុង១ខែ ។ |
| **៨-ឧបករណ៍រក្សាទឹកស្អាត :** | ១ គ្រួសារ ត្រូវមានធុងទឹកមានគំរបចំណុះ ២០លីត្រ ចំនួន ១ ។ |
| **៩-ជំរកស្នាក់នៅ :** | គួរមាន ៤ ម៉ែត្រក្រឡា សំរាប់មនុស្សម្នាក់ ។ |
| **១០-តំរូវការអុសដុត :** | ចង្រ្កានមួយសំរាប់គ្រួសារ ១គ្រួសារ និង ត្រូវការអុស ៥ គ.ក្រ ក្នុង ១ថ្ងៃ ។ |
| **១១-តំរូវការថ្នាំពេទ្យ :** | ១ឃីតរបស់អង្គការសុខភាពពិភពលោកគឺសំរាប់ប្រជាជន១០.០០០នាក់/៣ខែ។ |
| **១២-តំរូវការអាហាររូបត្ថម្ភជាមធ្យម** | មនុស្សម្នាក់ត្រូវការ ២១០០គីឡូកាឡូរី/១ខែ ស្មើ ១៤.៧ គ.ក្រ :<br>- ធញ្ញជាតិ :១០.៥ គ.ក្រ - គ្រាប់សណ្តែក : ១.៨ គ.ក្រ<br>- ប្រេង : ១.២ គ.ក្រ - ស្ករ : ១.២ គ.ក្រ |

## ផ្នែកទី ៧

## ការធ្វើសមាហរណកម្ម កម្មវិធីត្រៀមបង្ការ គ្រោះទឹកជំនន់ទៅក្នុងគំរោងផែនការអភិវឌ្ឍន៍ និង វិនិយោគរបស់ឃុំ-សង្កាត់

ឧបសម្ព័ន្ធទី ១

# ការធ្វើសមាហរណកម្មកម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ នៅក្នុងគំរោងផែនការអភិវឌ្ឍន៍ និង វិនិយោគរបស់ឃុំ-សង្កាត់

**១. អ្វីទៅជាផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់ និង ផែនការវិនិយោគឃុំ-សង្កាត់?**

## ក. និយមន័យ

***- ផែនការអភិវឌ្ឍន៍ឃុំ/សង្កាត់:***

គឺចង្កោមនៃបណ្តាចក្ខុវិស័យ គោលដៅ និង យុទ្ធសាស្ត្រដែលឃុំ-សង្កាត់ បានលើកឡើងសំរាប់អនុវត្តនៅក្នុងអាណត្តិ០៥ឆ្នាំរបស់ខ្លួន ។

- ***ផែនការវិនិយោគឃុំ/សង្កាត់:***

គឺជាផែនការសកម្មភាពអាទិភាពដែលឃុំ/សង្កាត់បានលើកឡើងប្រចាំឆ្នាំ (ឬ ធ្វើបច្ចុប្បន្នភាព) ដើម្បីសំរេចគោលដៅ និង យុទ្ធសាស្ត្ររបស់ខ្លួនដែលមាននៅក្នុងផែនការអភិវឌ្ឍន៍តាមបណ្តាឆ្នាំនីមួយៗរបស់ខ្លួន។

## ខ. ទិដ្ឋភាពរួម

កម្មវិធីត្រៀមបង្ការគ្រោះទឹកជំនន់ វាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការគ្រប់គ្រង និងអភិវឌ្ឍន៍តាមមធ្យោបាយនៃកិច្ចសហប្រតិបត្តិការពហុវិស័យ និងការគាំទ្រផ្នែកហិរញ្ញវត្ថុដែលខ្លួនស្វែងរកពីថវិកាអភិវឌ្ឍន៍។

នៅពេលមានទឹកជំនន់កើតឡើង វានាំមកនូវផលប៉ះពាល់លើការអភិវឌ្ឍន៍ ជាពិសេសផ្នែកកសិកម្ម ផ្ទះសម្បែង និង ហេដ្ឋារចនាសម្ព័ន្ធ សុខភាព ការអប់រំ និង ការអភិវឌ្ឍនសំរាប់ស្ត្រី។ ដូច្នេះ វាជាភាពចាំបាច់ដើម្បីអនុវត្ត និង សំរបសំរួលផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ឱ្យមានប្រសិទ្ធិភាពនៅតាំងពីថ្នាក់ជាតិ ថ្នាក់ខេត្ត-ក្រុង និងស្រុក ពិសេស គឺថ្នាក់ឃុំ ដើម្បីកាត់បន្ថយនូវផលប៉ះពាល់ដែលបណ្តាកមកពីគ្រោះមហន្តរាយទាំងឡាយ ។

## គ. គោលបំណង

- ដើម្បីលើកឡើងពីសារៈសំខាន់នៃការធ្វើសមាហរណកម្មផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ទៅក្នុងផែនការអភិវឌ្ឍន៍និងវិនិយោគរបស់ឃុំ-សង្កាត់ តាមរយៈវិស័យទាំង ០៥ *(រួមមាន: ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិនិងបរិស្ថាន សេវាកម្មរដ្ឋបាលនិងសន្តិសុខ និង យេនឌ័រ)* ។

- ដើម្បីផ្តល់ការស្វែងយល់ពីអន្តរទំនាក់ទំនង រវាងការងារគ្រប់គ្រងនិងកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ ពិសេសលើការងារត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយនឹង ការអភិវឌ្ឍន៍។
- ដើម្បីផ្តល់ការស្វែងយល់ពីការធ្វើសមាហរណកម្មផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ទៅក្នុងផែនការអភិវឌ្ឍន៍ដទៃទៀត។
- ដើម្បីផ្តល់ការស្វែងយល់វិធីសហការល្អប្រសើរ នៅក្នុងចំនោមភ្នាក់ងារខុសគ្នារបស់ខេត្ត-ស្រុក និងឃុំ ដែលនាំទៅដល់ការភ្ជាប់ទំនាក់ទំនង រវាងផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយផែនការផ្សេងៗទៀត។

## ឃ. គោលគំនិតសំខាន់ៗ

ផែនការខុសៗគ្នាមាននៅគ្រប់កំរិតទាំងអស់របស់ប្រទេស ចាប់ពីថ្នាក់ជាតិ ខេត្ត ស្រុក និង ឃុំ។ អាស្រ័យលើទំហំ វិសាលភាព និងពេលវេលានៃផែនការនីមួយៗ។ គោលបំណង និងវដ្តផែនការ គឺមានភាពខុសគ្នា។ ប្រការសំខាន់ គឺអ្នកធ្វើផែនការមូលដ្ឋាន មានការយល់ដឹងល្អពីផែនការអភិវឌ្ឍន៍ និង ការកាត់បន្ថយគ្រោះមហន្តរាយ នៅគ្រប់កំរិតដែលមានលក្ខណៈខុសៗគ្នា ទាំងគោលបំណង វដ្តរបស់ផែនការ និងកំណត់ពីការជាប់ទាក់ទង ដែលអាចបង្កើតបានរវាង ផែនការត្រៀមបង្ការគ្រោះទឹកជំនន់ និង ផែនការអភិវឌ្ឍន៍នៅថ្នាក់ខេត្ត ថ្នាក់ស្រុក និង ថ្នាក់ឃុំ។

សារៈសំខាន់នៃការធ្វើសមាហរណកម្មការកាត់បន្ថយគ្រោះមហន្តរាយ ទៅក្នុងវដ្តផែនការទ្បេងទាត់ (របស់ផ្នែកអភិវឌ្ឍន៍) មិនត្រឹមតែនៅថ្នាក់ខេត្ត និងថ្នាក់ស្រុកនោះទេ ប៉ុន្តែនៅថ្នាក់ជាតិ ក៏គួរឱ្យអ្នកពាក់ព័ន្ធ បានយល់ដឹងផងដែរ។ លទ្ធភាព នៃធនធានថវិកាបន្ថែមតាមរយៈការភ្ជាប់ទំនាក់ទំនង គួរតែបានលើកឡើង ដើម្បីធានាពីនិរន្តរភាព នៃការអនុវត្តន៍ផែនការត្រៀមបង្ការគ្រោះទឹកជំនន់។ សមាហរណកម្ម នៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយផែនការកាត់បន្ថយគ្រោះមហន្តរាយ និង ការអភិវឌ្ឍន៍ថ្នាក់មូលដ្ឋាន តំរូវឱ្យអ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ អាចចេះដឹងបាន អំពីនីតិវិធី ធ្វើផែនការអភិវឌ្ឍ កំណត់ពេលវេលា និង យន្តការថវិកានៅតាមតំបន់របស់គេ។ ទន្ទឹមនឹងនោះដែរ ការធ្វើសមាហរណកម្ម ក៏អំពាវនាវឱ្យមានប្រព័ន្ធសំរបសំរួលល្អប្រសើរជាច្រើន ដើម្បីឱ្យផែនការត្រៀមបង្ការ គ្រោះទឹកជំនន់មានការគាំទ្រពីអាជ្ញាធរគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍន៍ និង មានថវិកាគ្រប់គ្រាន់។ ដំណើរការធ្វើសមាហរណកម្ម នឹងបង្ហាញពីតំលៃមានប្រសិទ្ធិភាព ព្រោះស្ថាប័នគ្រប់គ្រងគ្រោះមហន្តរាយ និងអភិវឌ្ឍន៍ អាចអនុវត្តគំរោងរួមគ្នាបាន។ ដំណើរការនេះធ្វើឱ្យសកម្មភាពត្រួតស៊ីគ្នាមានជាអប្បរមា ជំរុញការបង្កើតកម្មវិធីបន្ថែម និង លើកកំពស់ការរួមកំលាំងគ្នារវាងវិស័យទាំងពីរ។

ផ្ទុយទៅវិញ ប្រសិនបើយើង ធ្វើមិនដឹងមិនឮចំពោះស្ថាប័នសំរាប់គ្រោះទឹកជំនន់ និង គ្រោះមហន្តរាយ នៅថ្នាក់ខេត្ត-ស្រុកនោះ ផែនការអភិវឌ្ឍន៍ នឹងនាំមកនូវភាពអសមត្ថភាព ដើម្បីព្យាករណ៍ទុកធនធានមនុស្ស និង ធនធានហិរញ្ញវត្ថុ ដែលត្រូវការក្នុងកំឡុងពេលគ្រោះអាសន្ន។ ការកង្វះភាពយល់ដឹងបែបនេះ នឹងត្រូវចំនាយច្រើន និងធ្វើឱ្យផែនការអភិវឌ្ឍន៍ និងការប៉ាន់ប្រមាណហិរញ្ញវត្ថុ នឹងទទួលបរាជ័យ។

ដូច្នេះ ការធ្វើសមាហរណកម្ម ក្លាយជាដំណើរការមួយសំរាប់អ្នកធ្វើផែនការនៅក្នុងវិស័យទាំងពីរ លុបចោលវដ្តខុសៗគ្នា នៃគ្រោះមហន្តរាយដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍ ហើយ ការអភិវឌ្ឍន៍ (ជាពិសេសការស្តារឡើងវិញក្រោយពេលគ្រោះមហន្តរាយ ការធ្វើផែនការអភិវឌ្ឍន៍ប្រថុចប្រញ៉ាចពេក) នឹងធ្វើឱ្យឥទ្ធិពលនៃគ្រោះមហន្តរាយកាន់តែធ្ងន់ធ្ងរឡើង។

| ឧទាហរណ៍ នៃផែនការខុសៗគ្នានៅថ្នាក់ខេត្ត ស្រុក និង ឃុំ | | |
|---|---|---|
| **ល.រ** | **ផែនការ** | **គោលបំណងនៃផែនការ** |
| ១ | ផែនការកាត់បន្ថយគ្រោះភ័យ នៃគ្រោះមហន្តរាយ ខេត្ត-ស្រុក និងឃុំ | ប្រមូលធនធាន និង កំណត់វិធានការជាក់លាក់ ដើម្បីត្រៀមបង្ការ ឆ្លើយតប និង ស្តារឡើងវិញពីគ្រោះមហន្តរាយ ដែលខេត្ត-ស្រុក-ឃុំ អាចនឹង ប្រឈម មុខ។ |
| ២ | ផែនការអភិវឌ្ឍខេត្ត-ស្រុក និង ឃុំ | កំណត់វិស័យអភិវឌ្ឍ និង ធនធានសក្តានុភាព ដើម្បីអនុវត្តកិច្ចការនៅថ្នាក់ខេត្ត ស្រុក និង ឃុំ។ |
| ៣ | ផែនការមន្ទីរខេត្ត-ស្រុក និង ឃុំ | ចំណាត់ធនធានសំរាប់ប្រតិបត្តិការជាប្រចាំ និង សំរាប់ការខិតខំប្រឹងប្រែងថ្មីៗ |
| ៤ | ផែនការពិសេសផ្សេងទៀតនៅថ្នាក់ ខេត្ត ស្រុក និង ឃុំ | ធានាថាសកម្មភាពថ្មី ដែលបានបង្កើតឡើង ត្រូវបានអនុវត្តដោយមានធនធានគ្រប់គ្រាន់ (មនុស្ស សំភារៈ ហិរញ្ញវត្ថុ) |

## ឃ. ការធ្វើសមាហរណកម្មលើវិស័យអាទិភាពទាំង០៥ របស់ឃុំ-សង្កាត់ នៅក្នុងការងារគ្រប់គ្រងគ្រោះមហន្តរាយ:

### ១.ផ្នែកសេដ្ឋកិច្ច:

-ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ

-ស្ថានភាពសិប្បកម្ម

-សេវាកម្មនានា

- ស្ថានភាពកសិកម្ម *(ការងារដាំដុះ, ការចិញ្ចឹមសត្វ, ការងារជលផល និង ការងាររុក្ខកម្ម ជាដើម)* ។

**២. ផ្នែកសង្គមកិច្ច:**

ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ

- ការងារអប់រំ
- ការងារសុខភាពនិងអនាម័យ
- ការងារសុខភាពស្ត្រី និងកុមារ
- ការងារទឹកស្អាត និងអនាម័យ
- ការងារជនងាយរងគ្រោះដែលត្រូវទទួលកិច្ចការពារពិសេស

**៣. ផ្នែកធនធានធម្មជាតិ និងបរិស្ថាន:**

- ការប្រែប្រួលធនធានធម្មជាតិ (ការរុករានបំពានការកាប់ឆ្ការព្រៃឈើ និង ព្រៃលិចទឹក)
- ការបំពុលបរិស្ថាន
- ការប្រើប្រាស់ជីគីមី និងថ្នាំគីមីសំលាប់សត្វល្អិតស្មៅ
- សំរាម និង ការធ្វើអាជីវកម្មរ៉ែ

**៤. សេវាកម្មរដ្ឋបាល និងសន្តិសុខ:**

- ការងារចុះអត្រានុកូលដ្ឋាន
- សណ្តាប់ធ្នាប់និងសន្តិសុខមូលដ្ឋាន

**៥. យេនឌ័រ**

- ការងារអំពើហឹង្សាក្នុងគ្រួសារ និង ការជួញដូរស្ត្រីនិងកុមារ
- ស្ថានភាពស្ត្រីនៅមូលដ្ឋាន
- ការចូលរួមរបស់ស្ត្រីក្នុងសង្គម




## ខ. ការងារគ្រប់គ្រងគ្រោះមហន្តរាយ

- **វិធានការណ៍ត្រៀមបង្ការគ្រោះមហន្តរាយ :**
  - **វិធានការណ៍ត្រៀមបង្ការបែបមិនមែនហេដ្ឋារចនាសម្ព័ន្ធ (អរូបវ័ន្ត)**
    - ការពង្រឹងសមត្ថភាព និង ការងារបណ្តុះបណ្តាល
    - ការងារផ្សព្វផ្សាយ និងបង្កើនការយល់ដឹងពីវិធានការត្រៀមបង្ការ និងកាត់បន្ថយគ្រោះភ័យ
    - ការរៀបចំផែនការ សំរាប់សង្គ្រោះ និង ជំលៀស
    - ការរៀបចំ និង ការគ្រប់គ្រងប្រព័ន្ធពតិមាន
  - **វិធានការណ៍ត្រៀមបង្ការបែប ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត**

- o រៀបចំប្រព័ន្ធផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់ ដូចជាបង្គោលម៉ែត្រ វាស់ស្ទង់ទឹក និងក្តារខៀនផ្សព្វផ្សាយពត៌មានព្យាករណ៍កំពស់ទឹក
- o ការកែលំអទីទួលសុវត្ថិភាព ( អណ្តូងទឹកស្អាត បង្គន់ ជំរកបណ្តោះ អាសន្ន..... ។ល ។
- o ការកែលំអ និង ពង្រឹងទំនប់ ប្រឡាយដោះទឹក ផ្លូវទៅកាន់ ទីទួលសុវត្ថិភាព
- o ការស្តុក និង ការគ្រប់គ្រងឃ្លាំងស្តុកសំភារៈ និងជំនួយសង្គ្រោះ

➢ **វិធានការណ៍ ជំលៀស សង្គ្រោះ និង ឆ្លើយតប**

- ត្រួតពិនិត្យមុខសញ្ញាបង្កគ្រោះថ្នាក់ដែលអាចកើតឡើង
- ការព្យាករណ៍និងការផ្តល់ពត៌មានជាមុនពីគ្រោះទឹកជំនន់
- ការសង្គ្រោះ  ជំលៀស  និង ស្រាវជ្រាវរុករកជនរងគ្រោះនៅរដូវ ទឹកជំនន់
- ការគ្រប់គ្រងប្រជាជនដែលជំលៀសមកស្នាក់នៅលើទីសុវត្ថិភាពនៅ រដូវទឹកជំនន់
- កម្មវិធីសុខភាព និង អនាម័យ ( ផ្តល់ទឹកស្អាត អប់រំពីការរស់នៅ ស្អាត ហូបស្អាត និង រស់នៅស្អាត
- ការវាយតំលៃ និងការប៉ាន់ប្រមាណផលប៉ះពាល់ និងសេចក្តីត្រូវការរបស់ជន រងគ្រោះ
- ផ្តល់ជំនួយសង្គ្រោះបន្ទាន់ ( ជំរកបណ្តោះអាសន្ន ស្បៀងអាហារ ...ជាដើម) ។

➢ **ការស្តារ និង ជួសជុលឡើងវិញ**

- ការវាយតំលៃ និង ការប៉ាន់ប្រមាណការខូចខាតនិងសេចក្តីត្រូវការ ដើម្បីស្តារនិងជួសជុលឡើងវិញ
- ការរៀបចំផែនការ និង យុទ្ធសាស្រ្តស្តារ និង ជួសជុលឡើងវិញ
- អនុវត្តផែនការ និង យុទ្ធសាស្រ្តស្តារ និង ជួសជុលឡើងវិញ ក្រោយពីគ្រោះមហន្តរាយ

# គំរោងវិនិយោគឃុំទាក់ទិននឹងការកាត់បន្ថយគ្រោះទឹកជំនន់ សំរាប់អនុវត្តក្នុងឆ្នាំ២០០៨ ស្ថិតក្នុងស្រុកគោលដៅទាំង០៤ នៃខេត្តកណ្តាល និង ព្រៃវែង របស់ADPC

## ស្រុក ល្វាឯម

| ល.រ | ឈ្មោះគំរោង | អរិ.ក្សត្រ | បារុង | បឹងគ្រំ | កោះកែវ | កោះរះ | ល្វាស | ឧញ៉ាអុង | ភូមិធំ | ព្រែកក្មេង | ព្រែករៃ | ព្រែកឫស្សី | សំបួរ | សារិ-កែវ | ថ្មគរ | ទឹកឃ្លាំង | សរុប | ថវិកាប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | ជីកស្រះ/ស្តារប្រភពទឹកស្រោចស្រព | | | | ១៥០០ម | ១៨០០ម | ១៧០០ ម | ៣៣០០ម | ២៥០ ម | | | ៧៨៥០ម | | ១៥០៥០ម | ២៥៥០ម | ៤២៥០ម | ១៦ | N/A |
| ២ | លើក/ស្តារជួសជុលទំនប់ទឹក | | | ៣៥ម | ១៧០០ម | | | | | | ១៦០០ម | ១៤០០ម | | | ២០០០ | ៣០ ម | ០៦ | N/A |
| ៣ | ស្តារបឹង/ស្ទឹង/អូរ/ត្រពាំងធម្មជាតិ | | | ១០០០ម | | | | | | | | | | | | | ០១ | N/A |
| ៤ | សាងសង់/ជួសជុលសំណង់ទ្វារស្ទាក់ទឹក | | | | | | | | ០៤ | | | | | | | | ០១ | N/A |
| ៥ | គំរោងជីក/ជួសជុលអណ្តូងស្នប់ | | ០៥ | ០១ | | | | ០៤ | | | ២៥ | | | | ៦០ | | ០៥ | ៩៥,០០០,០០០ រ |
| ៦ | សង់/ជួសជុលលូធារាសាស្ត្រមាន/ គ្មានទ្វារទឹក | | | | | ១៨ម | | | | | | | | | | | ០១ | N/A |
| ៧ | វគ្គបំប៉នពីជំនាញសង្គ្រោះបន្ទាន់ | | ០២វគ្គ | | ០១វគ្គ | | | | | ០២វគ្គ | ០១វគ្គ | ០១វគ្គ | | | ០១វគ្គ | | ០៦ | ៥,៥០០,០០០ រ |
| ៨ | គំរោងសាងសង់អាងស្តុកទឹកស្អាត | | | | | | | | | ០១ | | | | | | | ០១ | ៨,០០០,០០០ រ |
| ៩ | គំរោងលើកទីទួលសុវត្ថិភាព និង ជំរក | | | | | | | ០២ | | ០១ | | | | | | ០១ | ០៤ | ៨០,០០០,០០០ រ |
| ១០ | ការពង្រឹងសមត្ថភាពលើគ្រោះទឹកជំនន់ | ១ វគ្គ | ១ វគ្គ | ១ វគ្គ | ១ វគ្គ | | ១ វគ្គ | ១វគ្គ | ១វគ្គ | ១ វគ្គ | ១ វគ្គ | ១ វគ្គ | ១ វគ្គ | ១ វគ្គ | ១ វគ្គ | ១ វគ្គ | ១៤ | ១៣,០០០,០០០ រ |
| ១១ | បង្កើតក្តារផ្សព្វផ្សាយពិតមានមូលដ្ឋាន | ០៤ផ្ទាំង | ០៣ | | | | | ០៥ | | | | | | ០៤ | | | ០៤ | ១៥,៦០០,០០០ រ |
| ១២ | ពង្រឹងសមត្ថភាពជនបង្គោលស្ត្រី- កុមារ | | ១ វគ្គ | | ១ វគ្គ | | | | | | | ១ វគ្គ | ១ វគ្គ | | | | ០៤ | ៤,០០០,០០០ រ |

## ស្រុក លើកដែក

| ល.រ | ឈ្មោះគំរោង | កំពង់ភ្នំ | ក្អមសំណរ | ខ្ពបអាទាវ | ពាមរាំង | ព្រែកដាច់ | ព្រែកទន្លាប់ | សណ្តារ | សរុប គំរោង | ថវិកាប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ជីក/ស្តារប្រឡាយស្រោចស្រព | ៦០០ម | ២០០០ម | | ៥០០០ម | ២៤០០ម | ៨១០០ម | ១៦៥០ម | ០៦ | N/A |
| ២ | ស្តារបឹង/ស្ទឹង/អូរ/ព្រែក/ត្រពាំងទឹកធម្មជាតិ | | ២១០០ម | ៦០០០ម | ៥០០០ម | ៣២០០ម | ១២៥០០ម | ៣០០០ម | ០៦ | N/A |
| ៣ | ទិញ/ជួសជុល/អន្តរាគមន៍លើម៉ាស៊ីនបូមទឹក | | | ០២គ្រឿង | | ០៤គ្រឿង | ០១គ្រឿង | | ០២ | N/A |
| ៤ | គំរោងសាងសង់/ជួសជុលលូកាត់ផ្លូវ | | | | ០៣កន្លែង | ១៨លូកង់ | ១៥កន្លែង | | ០៣ | N/A |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៥ | សាងសង់/ជួសជុលទ្វារទឹក/សំណង់ស្ទាក់ទឹក | | | | | | ០២កន្លែង | | ០២ | N/A |
| ៦ | ជួសជុល/អាងស្តុកទឹក | | | | ០១កន្លែង | | | | ០១ | N/A |
| ៧ | គំរោងលើកទីទួលសុវត្ថិភាព និង ជំរកបណ្តោះអាសន្ន | ៣000ម2 | ៥៥២៨អា | | ២២៥0ម3 | ៣១00ម3 | | ០២ កន្លែង | ០៥ | N/A |
| ៨ | គំរោងសាងសង់បង្គន់អនាម័យ ( បង្គន់តាមលក្ខណ:គ្រួសារ) | ០២ | | | ២00 | ៦៥0 | | ៣0 | ០៤ | ៤៤១,000,000 រ |
| ៩ | គំរោងផ្តល់មធ្យោបាយចំរោះទឹកស្អាត | | | | ១៥0ធុង | ៦៧0ធុង | | | ០២ | ៤៩,២00,000 រ |
| ១០ | គំរោងពាង/អាងទឹកស្អាតតាមគ្រួសារ | | | | | ២0ម3 | | | ០១ | ៨២,000,000 រ |
| ១១ | បង្កើតក្តារផ្សព្វផ្សាយពិតមានមូលដ្ឋាន | | ០១ផ្ទាំង | | | ០២ផ្ទាំង | | ០១ផ្ទាំង | ០៤ | ៤,000,000 រ |
| ១២ | ចាក់ដីទីធ្លាសាលា សំរាប់ប្រើប្រាស់ជាទីទួលសុវត្ថិភាព | | | | | ៥000ម3 | | | ០១ | ៥,000,000 រ |
| ១៣ | ការពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំលើការងារគ្រោះមហន្តរាយ | ០១វគ្គ | ០១វគ្គ | ០១ វគ្គ | | ០១វគ្គ | ០១វគ្គ | ០១ វគ្គ | ០៦ | ៦,000,000 រ |
| ១៣ | ពង្រឹងសមត្ថភាពជនបង្គោលទទួលបន្ទុកស្ត្រី និង កុមារ | | | | | ០២ វគ្គ | | | ០១ | ១,២00,000 រ |

## ស្រុក ពាមជរ

| ល.រ | ឈ្មោះគំរោង | អង្គរអង្គ | កំពង់ប្រាសាទ | កោះចេក | កោះរកា | កោះសំពៅ | ក្រាំងតាយ៉ង | ព្រែកក្របៅ | ព្រែកសំបួរ | ឫស្សីស្រុក | ស្វាយភ្លោះ | សរុប គំរោង | ថវិកាប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | គំរោងសាងសង់/ជួសជុលទ្វារទឹក/សំណង់ស្ទាក់ទឹក | | | | | ០២ | | | | | | ០១ | ៣៦,១៨0,000 រ |
| ២ | គំរោងសាងសង់លូកាត់ផ្លូវ | ៤៥កន្លែង | ៦ កន្លែង | | | ៧កន្លែង | ៦ កន្លែង | ៥ កន្លែង | | ១០ កន្លែង | | ០៦ | ១៣២,៤៥២,000 រ |
| ៣ | ជីក/ស្តារប្រឡាយស្រោចស្រព | | ១១៩0ម | ២៥00ម | ១0000ម | ២១0៦ម | ១២៩២ម | ២៨00ម | | ១២៩៣ម | | ០៧ | ៤២២,៦៩១,000 រ |
| ៤ | ស្តារបឹង/ស្ទឹង/អូរ/ព្រែក/ត្រពាំងទឹកធម្មជាតិ | | ១៧៩0ម | ២៥00ម | | ៣៩៧៣ម | | | | ១៣00ម | ០២កន្លែង | ០៥ | ៧១៤៦៦៣,២00 រ |
| ៥ | សាងសង់អណ្តូងទឹកស្អាត | | | | | | | | | ៣៣ អណ្តូង | | ០១ | ៥២,៩៦៥,000 រ |
| ៦ | គំរោងសាងសង់បង្គន់អនាម័យ | ១0 | | | | | ២៤ | ១0 | ៥0 | ១១ | | ០៥ | ២៤៨,៣៣0,000 រ |
| ៧ | ផ្តល់ទូកជាមធ្យោបាយសង្គ្រោះដល់គ្រួសារក្រីក្រ | ០៤គ្រឿង | ០៥ | ០៤ | ០៥ | ០២ | ០១ | ០៣ | ០៣ | ១១ | ៣ | ១0 | ១៤១,៤00,000 រ |
| ៨ | គំរោងផ្តល់មធ្យោបាយចំរោះទឹកស្អាត | ៧៥0ធុង | ៤៧៥ | ៧៥0 | ១000 | | ៨0 | | ៤៥0 | ១៨៩៥ | ៩00 | ០៨ | ២១៨,០៥0,000 រ |
| ៩ | តម្រូវការ:សង្គ្រោះបន្ទាន់ ( អាវភ្លៀង/អាវពោង) | ៦0 អាវ | | | | | | | | | | ០១ | ១,៨00,000 រ |
| ១០ | គំរោងលើក និងកែលំអទីទួលសុវត្ថិភាព | កែលំអ ០២ | ០២ | ០៤ | ០៤ | ០៨ | ០១ | ០៣ | ០៣ | ០៨ | ០៣ | ១0 | ៦៦១,១៨៤,000 រ |
| ១១ | តម្រូវការជំរកស្នាក់នៅបណ្តោះអាសន្នលើទីទួល | ០២ ជំរក | ២១0 ជំរក | ០៤ ជំរក | ០៤ ជំរក | ៤៨ ជំរក | | ១៥0 ជំរក | ១៦ ជំរក | ១៦៥ ជំរក | | ០៨ | ១៨0,៤៣0,២00 |
| ១២ | ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំពីគ្រោះទឹកជំនន់ | | ០១ វគ្គ | ០១ វគ្គ | ០១ វគ្គ | ០១ វគ្គ | ០១ វគ្គ | ០១ វគ្គ | ០១ វគ្គ | ០១ វគ្គ | ០១ វគ្គ | ០៩ | ៩0,000,000 រ |
| ១៣ | តម្រូវការក្តារពិតមាន និងបង្គោលស្ទង់កំពស់ទឹក | ០៥ កន្លែង | | | | | | | | | | ០១ | ១0,000,000 រ |

## ស្រុក ស៊ីធរកណ្តាល

| ល.រ | ឈ្មោះគំរោង | អំពិលក្រៅ | ជ្រៃឃ្មុំ | ល្វេ | ព្រៅទី១ | ព្រៅទី២ | ពោធិ៍ទិ | ព្រែកចង្ក្រាន | ព្រៃដើមថ្នឹង | ព្រៃទឹង | រំលេច | ឫស្សីសាញ់ | សរុប គំរោង | ថវិកាប៉ាន់ស្មាន |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | សាងសង់ស្ពាន | | | ១០ ម | | | | ៤០ម | | ០១កន្លែង | | | ០៣ | ២៥៨,២៣៦,០០០ រ |
| ២ | គំរោងសាងសង់លូកាត់ផ្លូវ | ១៥ កន្លែង | ២ កន្លែង | ២ កន្លែង | ២ កន្លែង | ០១ កន្លែង | ២ កន្លែង | | | ៣ កន្លែង | | ៥ កន្លែង | ០៨ | ៥០,២២៩,០០០ រ |
| ៣ | ជីក និងស្តារប្រឡាយស្រោចស្រព | ៣១០០ម | ២៧០០ម | ៥៤០ម | ២២៧០ម | ១៦០០ម | ១៣០០ម | ៤០០ម | ១៦៤០ម | ៧៥០ម | ១០០០ម | ២៥៦០ម | ១១ | ២០០,៤៩៨,៥០០ រ |
| ៤ | ជួសជុលទំនប់ទឹក | ៥០០ម | ១២៥០ម | ៧១៥ម | ១៣៥០ម | ៦០០០ម | ១០០០ម | ៤២៥ម | ១៣០ម | | ១១៥ម | ២១៦០ម | ១០ | ២៤០,៩០៩,៣៧៥ រ |
| ៥ | សង់ទ្វារទឹក | | | | ១ កន្លែង | | | | | ១ កន្លែង | | ១ កន្លែង | ០៣ | ៤៤,៣៣៤,០០០ រ |
| ៦ | ដាក់លូស្រោចស្រព | | | | | | ១ កន្លែង | | | ១ កន្លែង | | ១ កន្លែង | ០៣ | ៦,១៧៥,០៩៤ រ |
| ៧ | ស្តារអាងស្តុកទឹក | | | | | | ១ កន្លែង | | | | | ២ កន្លែង | ០២ | ១០៨,០០០,០០០ រ |
| ៨ | ស្តារស្រះប្រភពទឹកស្រោចស្រព | ៤ កន្លែង | | | | | | | | | | | ០១ | ២៤,០០០,០០០ រ |
| ៩ | ផ្តល់មធ្យោបាយចំរោះទឹកស្អាត | | | | | | | ៥០ធុង | | | | | ០១ | ៤,០០០,០០០ រ |
| ១០ | សាងសង់អណ្តូងទឹកស្អាត | | | ១៤០ | | ៨ | | ១១២ | | ១: លើទួល | | | ០៤ | ៨៨៤,៤៥១,០០០ រ |
| ១១ | សង់បង្គន់អនាម័យ | ១០០បន្ទប់ | ៧ បង្គន់ | ១៤០០ បន្ទប់ | | ៤ បន្ទប់ | ៣៣ បង្គន់ | ១៦០ បង្គន់ | | ៥០ បង្គន់ (០២: ទីទួល) | ៣០០ បង្គន់ | | ០៩ | ១,៧០០,១៦០,០០០ រ |
| ១២ | ផ្តល់សំភារៈសង្គ្រោះ | | | | | | | ០៥ កំប្លេ | | | | | ០១ | ១០,០០០,០០០ រ |
| ១៣ | លើកទីទួលសុវត្ថិភាព/ជំរកបណ្តោះអាសន្ន | | | | | ០១ | | ០៥ | | ០១ | | | ០៣ | ៣៣,២០០,០០០ រ |
| ១៤ | ផ្តល់មធ្យោបាយជន្លៀសដល់គ្រួសារក្រីក្រ | | | ១២គ្រឿង | | | | ៥ គ្រឿង | | | ៦ គ្រឿង | | ០៦ | ១៤១,០០០,០០០ រ |

## ២. អនុសាសន៍ផ្សេងៗ លើការធ្វើសមាហរណកម្ម:

ការបញ្ចូលគ្នានៃផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ជាមួយផែនការរួមកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ និង ការអភិវឌ្ឍន៍ គឺមិនមែនជាដំណើរការសមាហរណកម្មល្អទេ នៅបណ្តាប្រទេសកំពុងអភិវឌ្ឍន៍។ វត្តមាននៃភាពមិនស៊ីគ្នារបស់ស្ថាប័ននៅក្នុងចំណោមការធ្វើការងាររបស់មន្ទីរពាក់ព័ន្ធខុសៗគ្នា បានក្លាយទៅជាឧបសគ្គចំបង ហើយបរិយាកាសពហុវិស័យ ត្រូវតែបង្កើតឡើងនៅពេលដែលការកិច្ចសហការមានភាពអវត្តមាន។

ខាងក្រោមនេះ គឺជាការប្រឈមចម្បងៗ ដែលអ្នកធ្វើផែនការនិងអ្នកអនុវត្តការគ្រប់គ្រងគ្រោះមហន្ត-រាយអាចប្រឈមក្នុងពេលធ្វើសមាហរណកម្មផែនការខុសៗគ្នា និងមើលឃើញផែនការត្រៀមបង្ការគ្រោះទឹកជំនន់ត្រូវបានអនុវត្តមានប្រសិទ្ធិភាព:

### i. ចំណេះដឹងអំពីនីតិវិធីធ្វើផែនការអភិវឌ្ឍន៍ និង ការតាមដាន:

វាតំរូវឱ្យអ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ និងអ្នកអនុវត្តការគ្រប់គ្រងគ្រោះមហន្តរាយ បានដឹងច្បាស់ពីនីតិវិធីធ្វើផែនការ អភិវឌ្ឍន៍ នៅក្នុងតំបន់របស់ពួកគេ និង អាចវាស់ស្ទង់វាបាន។ ការនេះ នឹងតំរូវឱ្យមានការពិចារណា អំពី :

- តើប្រព័ន្ធផែនការអភិវឌ្ឍ មានដំណើរការយ៉ាងដូចម្តេចនៅតាមខេត្តឬស្រុក ។
- តើអ្វីខ្លះជាពេលវេលាជាក់លាក់ សំរាប់ធ្វើផែនការអភិវឌ្ឍ និង ស្នើឱ្យមានសំណើរសកម្មភាពអភិវឌ្ឍដែលទាក់ទង (ពីស្ថាប័នធ្វើផែនការថ្នាក់ មូលដ្ឋាន) ដើម្បីបានបញ្ចូលទៅក្នុងផែនការ។
- តើនរណាជាអ្នកតាមមើល និង តើអ្វីជាកំរិតនៃអំណាចក្នុងការធ្វើផែនការអភិវឌ្ឍ។
- តើមន្ទីរពាក់ព័ន្ធ មានផែនការអភិវឌ្ឍដាច់ដោយឡែកពីគ្នា សំរាប់ច្របាច់បញ្ចូលទៅក្នុងផែន ការរួម ឬ ខេត្ត-ស្រុក មានមន្ទីរផែនការរបស់ខ្លួន ដែលស្នើសុំមន្ទីរពាក់ព័ន្ធឱ្យដាក់ផែនការ សំណើរដែរឬទេ។

ចំណេះដឹងអំពីនីតិវិធីទាំងនេះ នឹងអាចធ្វើឱ្យអ្នកធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ មានគំនិតល្អប្រសើរ ថានៅពេលណាត្រូវតាមរកកិច្ចខិតខំប្រឹងប្រែងធ្វើសមាហរណកម្ម និងលើកផែនការត្រៀមបង្ការដើម្បីឱ្យស៊ីគ្នាជាមួយនឹងវដ្តផែនការអភិវឌ្ឍន៍។

### ii. ការយល់ដឹងពីយន្តការថវិកាជាផ្លូវការ :

វាជាការសំខាន់ ដែលអ្នកធ្វើផែនការ និង អ្នកអនុវត្តការ គ្រប់គ្រងគ្រោះមហន្តរាយ ដឹងពីយន្តការដែលបានយកមកចំណាត់ថវិកាសំរាប់ផែនការនៅតាមតំបន់។ ការនេះ នឹងវាស់កំរិតអ្នកធ្វើផែនការត្រៀម បង្ការគ្រោះ

ទឹកជំនន់ ដើម្បីដាក់ជូនផែនការត្រៀមបង្ការ គ្រោះទឹកជំនន់ សំរាប់ការធ្វើសមាហរណកម្ម និង ចំណាត់ធនធាន បានទាន់ពេលវេលា ។

### iii. ការសហការជាពហុវិស័យ

- ផ្តល់និងចងក្រងទុកជាឯកសារនូវគំរោងការណ៍សហការតែមួយ ។ វានឹងធានាពីភាពស៊ីគ្នា ការសហការ ការទំនាក់ទំនង និង ការកំណត់ច្បាស់លាស់នូវការទទួលខុសត្រូវនៅក្នុងវិស័យ ខុស១គ្នា ។
- ចាត់តាំងជនបង្គោលសំរាប់ការធ្វើសមាហរណកម្ម ។
- ធ្វើគំរោងសំណើ គោលគំនិត របៀបវារៈការងារដើម្បីសំរបសំរួលការចូលរួម និងការអនុវត្តន៍ នៅគ្រប់វិស័យ ។ វាអាចនាំអោយមន្ទីរពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធជាច្រើនធ្វើការសហការ និង ជួយបង្កើតយន្តការ និងលើកកម្មវិធី ដែលអាចធ្វើការរួមគ្នាបាន ។ ត្រូវផ្តល់ការថែទាំ ជាពិសេស ចំពោះការសហការគ្រប់វិស័យគ្រប់កំរិត ។
- ធានាការចូលរួមរបស់សហគមន៍ នៅក្នុងការធ្វើផែនការត្រៀមបង្ការគ្រោះទឹកជំនន់ ។ ជាមួយការ យល់ដឹងពិសេសចំពោះក្រុមដែលងាយរងគ្រោះ វានឹងស្តែងឱ្យឃើញនូវតំរូវការរបស់សហគមន៍ បង្កើតភាពជាម្ចាស់ការ និង ការទាមទារមកលើអាជ្ញាធរដែនដី ដើម្បីធ្វើការងារក្នុងសក្ខណៈបែប សហការគ្នា ។
- គាំទ្រការទទួលខុសត្រូវតាមបែបវិមជ្ឈការក្នុងរចនាសម្ព័ន ដើម្បីធានាថាគោលនយោបាយត្រូវបាន អនុវត្ត និងមានភាពបត់បែនក្នុងយុទ្ធវិធីស្របតាមការផ្លាស់ប្តូរនៅពេលអនាគត ។

ជារួម ប្រសិនបើអ្នកអនុវត្តចង់បញ្ចូលកម្មវិធីត្រៀមបង្ការគ្រោះមហន្តរាយទឹកជំនន់ ទៅក្នុងកម្មវិធីវិនិយោគរបស់ឃុំ/សង្កាត់ គឺត្រូវទៅចូលរួមក្នុងកិច្ចប្រជុំជំហានទី១ នៅថ្នាក់ឃុំ (ជំរាបដល់ឃុំពីគំរោងរបស់ខ្លួន ដែលចង់ដាក់បញ្ចូល) ។ ក្រៅពីការខកខានមិនបានចូលរួមក្នុងជំហានទី១នេះ អ្នកអនុវត្តក៏នៅមានឱកាសសំរាប់ បញ្ចូលវានៅក្នុងជំហានទី២បាននៅឡើយដែរ តាមរយៈធ្វើការជាមួយក្រុមប្រឹក្សាឃុំ ដើម្បីបញ្ចូលគំរោងរបស់ខ្លួន ។ អ្នកអនុវត្តត្រូវចងចាំថា មានឱកាសសំរាប់តែពីរជំហានខាងលើដូចបានរៀបរាប់ខាងលើប៉ុណ្ណោះ សំរាប់ការបញ្ចូលគំរោងទៅក្នុងគំរោងផែនការនេះ ។

រីឯជំហានទី៣ គឺជាដំណើរការសិក្ខាសាលាសមាហរកម្មផែនការឃុំ/សង្កាត់នៅថ្នាក់ស្រុក/ខណ្ឌ ។ ប្រសិនបើអ្នកអនុវត្តទៅចូលរួមគាំទ្រគំរោង គឺជាការគាំទ្រមួយបែបក្រៅគំរោងផែនការ ។ ក្នុងជំហាននេះ ជួនកាល ក្រុមប្រឹក្សាឃុំ/សង្កាត់នឹងមិនអនុញ្ញាត ឬពុំទទួលគំរោងស្នើសុំទៀតទេ ។ ដូចនេះ គឺមានតែពីរជំហានខាងលើទេ ដែលអ្នកអនុវត្តយល់ដឹង និង ប្រតិបត្តិ ។

**គណៈកម្មការទន្លេមេគង្គ (MRC)**

គណៈកម្មការទន្លេមេគង្គ (MRC) ជាអង្គការអន្តររដ្ឋាភិបាល បានបង្កើតឡើងនៅឆ្នាំ ១៩៩៥ ដើម្បីលើកស្ទួយ និងសំរបសំរួលការងារគ្រប់គ្រង និងការអភិវឌ្ឍន៍ទឹក និងធនធានផ្សេងៗប្រកបដោយនិរន្តភាពចំពោះប្រទេសដែលមានផលប្រយោជន៍ទៅវិញទៅមកនិងសុខមាល ភាពរបស់ប្រជាជនដោយអនុវត្តន៍កម្មវិធីយុទ្ធសាស្រ្ត និងផ្តល់អោយនូវពត៌មានដែលមាន លក្ខណៈវិទ្យាសាស្រ្ត និងគោលការណ៍នានា។ ប្រទេសសមាជិករបស់គណៈកម្មការទន្លេមេគង្គ មានប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ គណៈកម្មាធិការទន្លេមេគង្គធ្វើការលើវិស័យ សំខាន់ៗដូចជា និរន្តភាពកសិកម្ម លើកស្ទួយសុវត្ថិភាពនាវាចរ ការអភិវឌ្ឍន៍ជលផល និងគ្រប់ គ្រងគ្រោះមហន្តរាយទឹកជំនន់។ កម្មវិធីរបស់គណៈកម្មការទន្លេមេគង្គ មានដូចជា : ការអភិវឌ្ឍន៍អាងទឹក ការប្រើប្រាស់ទឹក បរិស្ថាន ការគ្រប់គ្រងគ្រោះមហន្តរាយទឹកជំនន់ និងការកាត់បន្ថយផលប៉ះពាល់ កម្មវិធីពង្រឹងសមត្ថភាពជលផល ធារាសាស្រ្តកសិកម្មនិងព្រៃឈើ ធនធានទឹក និងជលសាស្រ្ត និងនាវាចរណ៍។ ពត៌មានលំអិតសូមចូលមើលគេហទំព័រ www.mrcmekong.org ។

**នាយកដ្ឋានជំនួយមនុស្សធម៌គណៈកម្មការអឺរ៉ុប (ECHO)**

ចាប់តាំងពីបង្កើតឡើងនៅក្នុងឆ្នាំ ១៩៩២ ECHO បានផ្តល់មូលនិធិជំនួយសង្គ្រោះបន្ទាន់ និង ជំនួយដល់ជនរងគ្រោះដោយគ្រោះមហន្តរាយធម្មជាតិ និងដោយកត្តាមនុស្សនៅក្រៅសហគមន៍អឺរ៉ុប។ ជំនួយបានផ្តល់ដោយផ្ទាល់ទៅដល់ជនរងគ្រោះដែលកំពុងមានសេចក្តីត្រូវការយ៉ាងខ្លាំង ដោយមិនប្រកាន់ពូជសាសន៍ សាសនា ឬក៏នយោបាយ។ ជារៀងរាល់ឆ្នាំប្រជាជនប្រមាណ១៨លាននាក់ត្រូវបានគាំទ្រក្នុងប្រទេសជាង៦0 តាមរយៈដៃគូរអនុវត្តចំនួន ២00 នៅជុំវិញ។ នៅក្នុងឆ្នាំ២00៦ ECHO បានផ្តល់ជំនួយមនុស្សធម៌ ៦៧១លានអឺរ៉ូ សំរាប់គ្រោះមហន្តរាយ ជុំវិញពិភពលោក។

កម្មិវធី DIPECHO (ត្រៀមបង្ការគ្រោះមហន្តរាយ ECHO) បានបង្កើតនៅក្នុងឆ្នាំ ១៩៩៦ ដើម្បីអភិវឌ្ឍន៍សមត្ថភាពសហគមន៍អោយមានការរៀបចំ និង ការពារដោយខ្លួនឯងអោយ បានប្រសើរប្រឆាំងនឹងគ្រោះមហន្តរាយធម្មជាតិ។ ក្នុងការផ្សព្វផ្សាយយុទ្ធសាស្ត្រកាត់បន្ថយ គ្រោះភ័យអោយមានប្រសិទ្ធភាព វិស្វករទាំងឡាយរបស់ DIPECHO គឺជាអ្នកសំរបសំរួល ជាមួយដៃគូរកាត់បន្ថយគ្រោះភ័យដោយគ្រោះមហន្តរាយទាំងឡាយនៅគ្រប់លំដាប់ថ្នាក់។ ក្នុងឆ្នាំ ២00៦ មូលនិធិ៧លានអឺរ៉ូ ត្រូវបានបែងចែកទៅកាន់ផែនការសកម្មភាពទី៥សំរាប់ តំបន់អាស៊ីអគ្នេយ៍របស់ DIPECHO។ សំរាប់ពត៌មានលំអិតសូមចូលមើលគេហទំព័រ http://ec.europa.eu/echo/field/dipecho/index_en.htm ឬក៏ទំនាក់ទំនង ការិយាល័យពត៌មានប្រចាំតំបន់របស់ ECHO ក្នុងក្រុងបាងកកតាមរយៈ rio@echo-bangkok.org

**មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC)**

មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) ជាអង្គការឯករាជ្យ មិនសំដៅប្រាក់ ចំណេញ និងជាអន្តររបាលភិបាលមានការិយាល័យនៅទីក្រុងបាងកក ប្រទេសថៃ។ មជ្ឈមណ្ឌលនេះបានបង្កើតឡើងនៅឆ្នាំ ១៩៨៦។ មជ្ឈមណ្ឌលត្រៀមបង្ការគ្រោះមហន្តរាយអាស៊ី (ADPC) ជាមជ្ឈមណ្ឌលធនធានឈានមុខគេនៅក្នុងតំបន់ ដែលធ្វើការសំដៅរៀបចំសហគមន៍ អោយមានសុវត្ថិភាព និងការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពតាមរយៈការងារកាត់បន្ថយ គ្រោះមហន្តរាយ។ កម្មវិធីរបស់មជ្ឈមណ្ឌលមានការអនុវត្តន៍ផ្សេងៗគ្នា ដើម្បីដោយស្រាយ បញ្ហាគ្រោះមហន្តរាយគ្រប់ប្រភេទ និងគ្របដណ្តប់លើផ្នែកនានានៃការងារគ្រប់គ្រងគ្រោះមហន្តរាយ ដូចជា ការពារនិងកាត់បន្ថយតាមរយៈការត្រៀមបង្ការ ការឆ្លើយតបចំពោះការខូចខាត និងការងារស្តារឡើងវិញជាដើម។ កម្មវិធីផ្សេងៗរបស់មជ្ឈមណ្ឌលត្រូវបានអនុវត្តដោយ ៤ក្រុមផ្សេងៗគ្នាដូចជា ក្រុមប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយតាមទីក្រុង ក្រុមគ្រប់គ្រងគ្រោះភ័យនៃអាកាសធាតុ និងក្រុមទទួលបន្ទុកផ្នែកសុខភាពនិងសង្គ្រោះបន្ទាន់។ ពត៌មានលំអិតបន្ថែមទៀតអំពីកម្មវិធីសូមចូលមើលគេហទំព័រ www.adpc.net ។